ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 08-Jun-2012, 15:42
CMS/CFO: Sann Rada

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២**

**ម៉ោង ០៩:០១ នាទី**

**សវនាការលើកទី៧១**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍

*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc LAVERGNE)*

ចៅក្រម ធួ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)

*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោកស្រី ណាតាចា វិស៊ែល រីស៊ើ

*(Ms. Natacha WEXELS-RISER)*

លោក ដាវ អានសាន

លោក ម៉ាតេអូ គ្រីប៉ា

*(Mr. Matteo Crippa)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារាស្មី

លោក សេង ប៊ុនឃាង

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល

*(Mr. Vincent de wilde d'ESTMAEL)*

លោក ឌេល លីសាក់ (*Mr. Dale LYSAK*)

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន

*(Mr. Michiel PESTMAN)*

លោក ហ្សាស្ពើ ប៉ៅ*(Mr Jasper PAUW)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកគែន

*(Mr. Arthur VERCKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ទី ស្រីនណា

លោក ហុង គឹមសួន

លោក បាណាបេ ណេគុី

*(Mr. Barnabé NEKUIE)*

លោក គឹម ម៉េងឃី

លោក ឡោ ជុនធី

លោក វ៉ែន ពៅ

លោក សំ សុគង់

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ខេល លីសាក់ | អង់គ្លេស |
| លោក សេង ប៊ុនឃាង | ខ្មែរ |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក អាកទួរ វែកគែន | បារាំង |
| លោក ហ្សាស្តើ ប៉ៅ | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោក ម៉ម រិទ្ធា (មេធាវីប្រឹក្សាសាក្សី) | ខ្មែរ |
| លោក សៅ សារុន (TCW-604) | ខ្មែរ |
| លោក ខឹម ងន (TCW-323) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក សៅ សារុន** (TCW-604)

សួរបន្តដោយលោក ខេល លីសាក់ ផ្ដើមពី៖ ........ ទំព័រ ៣

**ការសួរសំណួរទៅសាក្សី៖ លោក ខឹម ខន** (TCW-323)

សួរដោយប្រធានអង្គជំនុំជម្រះ ផ្ដើមពី៖ ........ ទំព័រ ៥៤

សួរដោយលោក ច័ន្ទ តារាស្មី ផ្ដើមពី៖ ........ ទំព័រ ៥៩

សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល ផ្ដើមពី៖ ........ ទំព័រ ៨០

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:០៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយមុននឹងបន្តកិច្ចដំណើរការសវនាការ ថ្ងៃនេះ អង្គជំនុំជម្រះសូមជម្រាបជូនដំណឹងដល់ភាគីនៃសំណុំរឿងក្តី ០០២ ទាំងអស់ថា នៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ អវត្តមានចៅក្រម យូរ ឧត្តរា ដែលជាចៅក្រមជាតិ ដែលគាត់មានធុរៈចាំបាច់ គាត់មិនអាចចូលរួមនៅក្នុងកិច្ចដំណើរការសវនាការបាន។ បន្ទាប់ពីយើងខ្ញុំបានពិគ្រោះយោបល់ជាមួយនឹងបណ្តាចៅក្រមពេញសិទ្ធិនៃអង្គជំនុំជម្រះសាលាដំបូង យើងបានសម្រេចតែងតាំងលោកចៅក្រម ធូ មណី ដែលជាចៅក្រមបម្រុងខាងភាគីជាតិ ជំនួសកន្លែងចៅក្រមយូរ ឧត្តរា ដែលបានអវត្តមានរហូតដល់ពេលណា ដែលលោកចៅក្រម យូរ ឧត្តរា មានវត្តមាន និងមានលទ្ធភាពអាចបំពេញការងារក្នុងការចូលរួមក្នុងកិច្ចដំណើរការសវនាការ នៅអង្គជំនុំជម្រះសាលាដំបូងវិញបាន។ ការសម្រេចនេះដោយផ្អែកតាមបទប្បញ្ញត្តិនៃវិធាន ៧៩(៤) នៃវិធានផ្ទៃក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

[០៩:០២:២៥]

លោកស្រី សែ កុលវុឌ្ឍីឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះអញ្ជើញចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន។ គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន លើកលែងតែជនជាប់ចោទ អៀង សារី មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមបន្ទប់សវនាការនេះ ដោយជនជាប់ចោទបានស្នើសុំលះបង់សិទ្ធិតាមរយៈមេធាវីរបស់ខ្លួន ក្នុងការចូលរួមដំណើរការនីតិវិធីសវនាការ ដោយផ្ទាល់ពីបន្ទប់សវនាការនេះ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទបានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ដោយឡែកសាក្សីបម្រុងដែលត្រូវមកផ្តល់សក្ខីកម្មបន្ទាប់ពីសាក្សី សៅ សារុន នេះគឺសាក្សី TCW-323 នឹងមានវត្តមាននៅម៉ោងដប់សាមសិបនាទីព្រឹកនេះ។ សាក្សីរូបនេះបានធ្វើសម្បថនៅចំពោះមុខអ្នកតា

ដំបងដែកកាលពីម្សិលមិញ។

[០៩:០៣:២២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ផ្តល់ឯកសារមកឲ្យខ្ញុំ។

អង្គជំនុំជម្រះសាលាដំបូងបានទទួលពាក្យសុំរបស់ជនជាប់ចោទ អៀង សារី ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ តាមរយៈមេធាវីការពារក្តីរបស់គាត់ សុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ដោយគាត់សុំនៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់រយៈពេលដំណើរការសវនាការពេញមួយថ្ងៃនេះ ដោយមូលហេតុបញ្ហាសុខភាពមិនអាចអង្គុយតាមដានស្តាប់ក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់បាន។

អង្គជំនុំជម្រះយល់ឃើញថា ពេលនេះជនជាប់ចោទ អៀង សារី បានសុំលះបង់សិទ្ធិមានវត្តមានក្នុងបន្ទប់សវនាការដោយផ្ទាល់ តែគាត់មានលទ្ធភាពអាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ និងអាចសម្រួលទំនាក់ទំនងរវាងគាត់ជាមួយនឹងក្រុមមេធាវីរបស់គាត់បានផង។ អង្គជំនុំជម្រះសម្រេចយល់ព្រមតាមពាក្យសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមក្នុងកិច្ចសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ឲ្យគាត់នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលដំណើរការសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ អៀង សារី អាចមានលទ្ធភាពតាមដានកិច្ចដំណើរការសវនការពីចម្ងាយ សម្រាប់កិច្ចដំណើរការសវនាការពេញមួយថ្ងៃនេះ។

[០៩:០៥:១៤]

អរុណសួស្តីលោក សៅ សារុន យ៉ាងម៉េចទៅលោក សៅ សារុន សុខភាពនៅថ្ងៃនេះ ល្អប្រសើរទេ?

**លោក សៅ សារុន៖**

បាទ សុខភាពខ្ញុំថ្ងៃនេះ ខ្ញុំក៏មិនសូវស្រួលខ្លួនដែរ។ ខ្ញុំសូមធ្វើតែមួយព្រឹកបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ដែលលោកបានផ្តល់ព័ត៌មាននេះមកអង្គជំនុំជម្រះ ដើម្បីឱ្យអង្គជំនុំជម្រះមានមូលដ្ឋាននៅក្នុងការបន្តកិច្ចដំណើរការសវនាការ។ ដូច្នេះភាគីដែលពាក់ព័ន្ធនៅក្នុងរឿងក្តីជ្រាបហើយ អង្គជំនុំជម្រះបានជម្រាបជូនអំពីលទ្ធភាពនៃកិច្ចដំណើរការសវនាការនៅចុងសប្តាហ៍នេះ គឺនៅថ្ងៃនេះ ហើយនិងសប្តាហ៍ក្រោយដែលលទ្ធភាពនឹងអាចធ្វើឆ្លាស់គ្នារវាងសាក្សី សៅ សារុន ហើយនិងសាក្សីដែលមានរហស្សនាម TCW-323។

[០៩:០៦:១២]

ដោយមូលហេតុបញ្ហាវ័យចាស់ជរា ចាស់របស់លោក សៅ សារុន ហើយនិងបញ្ហាសុខភាពរបស់គាត់។ អ៊ីចឹងគឺយើងនឹងអាចដំណើរការ មានលទ្ធភាពដំណើរការឆ្លាស់គ្នាដើម្បីបន្ធូរស្ថានភាពសុខភាពរបស់គាត់ ដើម្បីឱ្យគាត់មានលទ្ធភាពនឹងសុខភាពសមល្មមអាចផ្តល់សក្ខីកម្មជូនដល់អង្គជំនុំជម្រះបាន។

បាទ ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម ហើយនិងភាគីទាំងអស់។

[០៩:០៦:៥៨]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក ឌេល លីសាក់៖**

**ស៖** ជម្រាបសួរលោកសាក្សី សារុន ។ ម្សិលមិញយើងបានបញ្ឈប់ត្រង់កន្លែងមួយដែលយើងនិយាយអំពីដំណើរ ដែលលោក ហើយនិង ជួន បានធ្វើដំណើរតាមយន្តហោះទៅភ្នំពេញ បន្ទាប់ពី ខាំ ភួន ហើយនិងសមាជិក និងលេខាស្រុក១០៥ បានសម្លាប់ ឡេង នោះបាទ។ ហើយលោកបាននិយាយអំពីការប្រជុំជាមួយ ប៉ុល ពត, នួន ជា ហើយនិង សុន សេន ហើយគាត់បាននិយាយអំពីហេតុការណ៍នោះ ហើយគាត់ក៏បានស្នើឱ្យលោកធ្វើជាលេខាតំបន់១០៥ បន្តទៅទៀត។ លោកសាក្សី នៅពេលដែលលោកនៅភ្នំពេញ តើលោកបានទៅទីតាំងដែល ឡាំង ហើយនិង ខាំ ភួន បានស្លាប់នោះដែរឬទេ?

**លោក សៅ សារុនៈ**

**ឆៈ** បាទ ខ្ញុំបានទៅមើលកន្លែងគាត់ស្លាប់ម្តងបាទ។

**សៈ** តើកន្លែងនោះ នៅកន្លែងណា? ហើយហេតុការណ៍នោះកើតនៅកន្លែងចំណុចណាដែរ?

**ឆៈ** កន្លែងហ្នឹង គឺជាកន្លែងផ្ទះសំណាក់ដែលខាងភ្នំពេញផ្តល់ឲ្យខាងមណ្ឌលគិរីអី។ ចំណុចអី ខ្ញុំអត់ស្គាល់ទេ បាទ។

**សៈ** តើលោកបានឃើញអ្វីខ្លះនៅពេលដែលទៅកាន់ទីកន្លែងដែល ឡាំង ហើយនិង ខាំ ភួន បាន ស្លាប់នោះ លោកបានឃើញអ្វីខ្លះនៅទីនោះ?

**ឆៈ** បាទ ខ្ញុំឃើញគេបង្ហាញថា ដែកចន្ទាសឡានមួយ ប្រហែលប្រវែងមួយហត្ថ អាហ្នឹងគេវៃ តា ឡាំង រួច ខាំ ភួន បាញ់ខ្លួនឯងខ្ញុំឃើញគ្រាប់វាធ្លាយ។ អាហ្នឹងទ្វារហ្នឹងពីរគ្រាប់។

[០៩:១០:០០]

**សៈ** តើលោកនៅភ្នំពេញអស់រយៈពេលប៉ុនណា ដែលមុនលោកត្រឡប់ទៅមណ្ឌលគិរីវិញ?

**ឆៈ** បាទ ខ្ញុំនៅតែមួយថ្ងៃ ខ្ញុំត្រឡប់ទៅមណ្ឌលគិរីវិញ។

**សៈ** នៅពេលដែលលោកត្រឡប់ទៅវិញ តើលោកយកអដ្ឋិធាតុ ឬក៏ឆ្អឹងរបស់ ឡាំង ជាអតីត លេខាស្រុកទៅជាមួយទេ លេខាតំបន់ទៅជាមួយទេ?

**ឆៈ** បាទ ខ្ញុំបានយកតែធាតុហ្នឹងទៅ ទៅជូនឲ្យបងប្អូនគេធ្វើបុណ្យបាទ។

**សៈ** តើអ្នកណាជាអ្នកឲ្យអដ្ឋិធាតុ ឡាំង ឲ្យលោកយកទៅមណ្ឌលគិរី?

**ឆៈ** បាទ ខ្ញុំឃើញគេយកមកឲ្យពួកគេអ្នកប្រចាំការនៅភ្នំពេញ។

**សៈ** តើគេបានផ្តល់អដ្ឋិធាតុ ឬក៏ឆ្អឹងរបស់ ខាំ ភួន ប្រគល់ឲ្យលោកយកទៅជាមួយដែរទេ ថ្ងៃ នោះ?

[០៩:១១:៤៤]

**ឆៈ** បាទ អត់មាន អត់ឃើញទេ ឃើញតែធាតុ តាឡាំង។

**សៈ** តើ ប៉ុល ពត ជាអ្នកបង្គាប់ឲ្យគេយកអដ្ឋិធាតុ ឡាំង មកប្រគល់ឲ្យលោក ឬក៏អ្នកណា?

**ឆៈ** បញ្ហាហ្នឹងខ្ញុំអត់ស្គាល់ទេ ឃើញតែគេអ្នកប្រចាំការហ្នឹង យកតែធាតុហ្នឹងមកឲ្យខ្ញុំបាទ។

**សៈ** ដើម្បីសួរសំណួរពីរបីទៀតទៅលោកអំពីការប្រជុំរបស់លោកជាមួយ ប៉ុល ពត, នួន ជា ហើយនិង សុន សេន នៅពេលដែលលោកនៅភ្នំពេញកាលនោះ។ ដោយហេតុថា សមាជិកម្នាក់នៃតំបន់

១០៥ ខាំ ភួន ទើបតែត្រូវបាន-- ទើបតែសម្លាប់លេខាស្រុក តើគាត់បានសួរលោកអំពី ខាំ ភួន ដែលថា មូលហេតុអីបានជា ខាំ ភួន អាចនឹងសម្លាប់លោក ឡាំង ហ្នឹងដែរទេ?

**ធ៖** បាទ មិនឃើញគាត់សួរអីទេ បាទ។

**ស៖** តើពួកគាត់មានការព្រួយបារម្ភ ឬក៏ពួកគាត់ខឹងពួកកម្មាភិបាលនៅក្នុងមណ្ឌលគិរីដែរឬទេ ដែលអាចនឹងនាំឲ្យមានហេតុការណ៍នេះកើតឡើងនោះ?

**ធ៖** អត់យល់ ដឹងគាត់-- អត់យល់ទេបាទ។

**ស៖** នៅពេលដែលលោកជិះយន្តហោះមកភ្នំពេញ មកជួបជាមួយមេដឹកនាំទាំងអស់នោះ តើលោកកាន់អាវុធមកជាមួយលោកនៅលើយន្តហោះទេ មានអាវុធ មានអ្វីទេបាទ?

[០៩:១៥:០៩]

**ធ៖** បាទ អត់មានទេ។

**ស៖** នៅពេលដែលលោកបានជួបប្រជុំជាមួយ ប៉ុល ពត, នួន ជា និង សុន សេន តើមានការពិភាក្សាថា ខាំ ភួន បានកាំភ្លើងមកពីណាយកមកបាញ់ខ្លួនឯងសម្លាប់ហ្នឹងដែរឬទេ? តើគាត់និយាយពីរឿងហ្នឹងទេ?

**ធ៖** បាទ ខ្ញុំមិនៗយល់ មិនដឹងគេយកកាំភ្លើងមកពីណា អត់យល់ អត់ដឹង។

**ស៖** នៅក្នុងកិច្ចប្រជុំជាមួយ ប៉ុល ពត, នួន ជា និង សុន សេន នោះ តើពួកគាត់បានសួរយោបល់លោក ថាតើ ខាំ ភួន ជាជនក្បត់ ហើយនិងមនុស្សផ្សេងទៀតអាចជាអ្នកជាប់ខ្សែជាមួយ ខាំ ភួន ឬក៏ជាមួយកម្មាភិបាលផ្សេងដែរឬទេ?

[០៩:១៥:១៧]

**ធ៖** បាទ មិនឃើញគាត់ពន្យល់អ្វីសោះ។ បាទ អស់។

**ស៖** តើគាត់សួរលោកអ្វី អំពីបុគ្គលណានៅមណ្ឌលគិរី ដែលជាប់ខ្សែជាមួយ ខាំ ភួន ដែរឬទេ?

**ធ៖** អត់ អត់ឃើញគាត់សួរអីទេបាទ។

**ស៖** លោកសាក្សីបន្ទាប់ពីការសម្លាប់ ឡាំង ហើយលោកបានជួបប្រជុំជាមួយ ប៉ុល ពត, នួន ជា និង សុន សេន តើមានការចាប់ខ្លួនកម្មាភិបាលមកពី ក-១៦ ជាមន្ទីរពាណិជ្ជកម្ម ដែល ខាំ ភួន ជាប្រធាន ជាលេខានៅទីនោះទេ?

[០៩:១៦:១៧]

**ឆ៖** អត់មានទេបាទ។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតអានផ្នែកមួយជូនសាក្សីស្ដាប់ គឺជាសំណួរចេញពីឯកសារ E3/367 ជាបទសម្ភាសន៍ជាមួយសហចៅក្រមស៊ើបអង្កេត របស់សាក្សីនេះ។ ERN ខ្មែរ 00251440 អង់គ្លេស ERN 00278697 ហើយបារាំង ERN 00486031 បាទ 013 បាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! ហើយអនុញ្ញាតទាំងបុគ្គលិកពាក់ព័ន្ធនឹង-- មានភារកិច្ចពាក់ព័ន្ធនឹង-- សូមបង្ហាញឯកសារនេះនៅលើអេក្រង់កុំព្យូទ័រ ហើយនិងអេក្រង់ទូរទស្សន៍ផង។

[០៩:១៧:៤៣]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី នៅក្នុងការសម្ភាសទីមួយរបស់លោកជាមួយសហចៅក្រមស៊ើបអង្កេតនោះ លោកបានឆ្លើយដូចខាងក្រោមនេះ សេចក្ដីដកស្រង់៖ "ក្រោយពេល តាឡាំង ស្លាប់ទៅ ខ្ញុំដឹងថាមានកម្មាភិបាលខាងពាណិជ្ជកម្មត្រូវបានចាប់ខ្លួន"។ តើនេះជាចម្លើយត្រឹមត្រូវ ហើយនិងដោយស្មោះត្រង់របស់រូប-- របស់លោកដែរឬទេ?

**លោក សៅ សារុន៖**

**ឆ៖** បាទ ត្រឹមត្រូវ។ សូមអស់។

**ស៖** ថាតើការចាប់ខ្លួនកម្មាភិបាលពាណិជ្ជកម្មនោះ គឺធ្វើឡើងក្រោយការសម្លាប់ តាឡាំង ឬ? តើ ជួន ជាប្រធានពាណិជ្ជកម្មតំបន់នោះ ដែលធ្វើដំណើរទៅភ្នំពេញជាមួយលោកនោះ ជួន ទៅភ្នំពេញក្រោយមកគាត់មានបញ្ហាអ្វីទៀតដែរឬទេ?

[០៩:១៨:៥៦]

**ឆ៖** បញ្ហាហ្នឹង ខ្ញុំអត់យល់ទេ គឺសូមអស់ប៉ុណ្ណឹង។

**ស៖** លោកសាក្សី តើ ប៉ុល ពត មិនប្រាប់លោកដោយផ្ទាល់ទេនៅពេលមួយថា ជួន នោះ គេហៅ ជួន មកភ្នំពេញ ដើម្បីឲ្យមកអប់រំឡើងវិញ ឬក៏មកលត់ដំដែរឬទេ?

**ឆ៖** បាទ គេមិនឃើញប្រាប់ខ្ញុំទេ ឃើញតែបាត់មនុស្សទៅបាទ។

**ស៖** តើលោកបានដឹងថា ការបាត់ខ្លួនរបស់ ជួន នោះ លោកបានដឹងពីអ្វីទេ? ពីរឿងការបាត់ខ្លួន

គាត់នោះ?

**ឆ៖** បាទ ខ្ញុំអត់ដឹងទេ។

[០៩:២០:០៦]

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតសួរសាក្សីអំពីសេចក្ដីដកស្រង់នៅក្នុងចម្លើយបទសម្ភាសន៍ទីបីជាមួយសហចៅក្រមស៊ើបអង្កេត។ ឯកសារ E3/384 ខ្មែរផេក ERN 00345904 អង់គ្លេស ERN 00348373 ហើយបារាំង ERN 00354237 ហើយនិងខ្ញុំសូមអនុញ្ញាតសូមតុលាការបង្ហាញឯកសារលើអេក្រង់ផងដែរបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សីនៅក្នុងបទសម្ភាសន៍ជាមួយសហចៅក្រមស៊ើបអង្កេតរបស់លោក លោកបានឆ្លើយដូចខាងក្រោមនេះ៖ ដកស្រង់ "ខ្ញុំបានទទួលទូរលេខផ្ទាល់ពី ប៉ុល ពត ប្រាប់ថាឈ្មោះ ជួន ត្រូវបានហៅទៅអប់រំកែប្រែនៅភ្នំពេញ តាំងពី១០ថ្ងៃមុន គឺហៅទៅព្រឹក ហៅទៅពីក្រចេះ"។ តើលោកអាចបញ្ជាក់ថានេះជាចម្លើយត្រឹមត្រូវរបស់លោកដែរឬទេ លោកសាក្សី?

[០៩:២១:៣៧]

**លោក សៅ សារុន៖**

**ឆ៖** បាទ ជាត្រឹមត្រូវ។ គេហៅ ខ្ញុំអត់ដឹង។

**លោក ឌេល លីសាក់៖**

លោកប្រធាន យើងខ្ញុំមានបញ្ជីអ្នកទោស ស-២១ ដែលមានចំណងជើងថា "បញ្ជីអ្នកទោស" គឺចុះថ្ងៃទី២៣ វិច្ឆិកា ឆ្នាំ១៩៧៧ គឺឯកសារ D-- E107/1.31 ដែលនិយាយថា កម្មាភិបាល១០០នាក់ជាងមកពីមណ្ឌលគិរីគឺនៅតំបន់១០៥ គឺបានចូលមកដល់ ស-២១ នៅថ្ងៃនោះជាមួយគ្នា ដែលមានឈ្មោះ ខាំ ភាន់ ហៅ ជួន ហើយមានកម្មាភិបាលនារីមកពីគណៈសេដ្ឋកិច្ច-- ពាណិជ្ជកម្ម ក-១៦ មណ្ឌលគិរីផងដែរ។ ខ្ញុំសូមអនុញ្ញាតប្រើឯកសារនេះដើម្បីសួរសាក្សី ដើម្បីឲ្យគាត់រំឭកឡើងវិញអំពីកាលបរិច្ឆេទនៃកាលបរិច្ឆេទនោះ ហើយនិងតើកម្មាភិបាលណាខ្លះដែលអាចនឹងមកពីមណ្ឌលគិរី។

ខ្ញុំសូមអនុញ្ញាតតុលាការ លោកប្រធានដើម្បីបង្ហាញឯកសារលើអេក្រង់ ហើយខ្ញុំនឹងសួរសំណួរជាបឋមទៅសាក្សីផងដែរ។ ដូច្នេះ ខ្ញុំសូមការអនុញ្ញាតបែបនេះ លោកប្រធានបាទ។

[០៩:២៣:៣៤]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី យើងមានកំណត់ត្រាឯកសារមកពី ស-២១ ដែលចង្អុលបង្ហាញថា នៅថ្ងៃទី២៣ វិច្ឆិកា ឆ្នាំ១៩៧៧ គឺចុងឆ្នាំ៧៧ នោះ ជួន ក៏មានឈ្មោះថា ផាន ឃោន ផងដែរ-- បាទ ផាន ឃួន ដែលធ្វើដំណើរមកជាមួយលោកមកភ្នំពេញនោះ នៅក្នុងកំណត់ត្រានេះគឺថាគាត់នៅក្នុងលេខ១២៨ នៅក្នុងបញ្ជីអ្នកទោស ស-២១។ ហើយខ្ញុំបានជម្រាបតុលាការ ហើយគេៗកំណត់នូវបញ្ជីនេះថាមានកម្មាភិបាលនារី១២នាក់ក៏មកពី ក-១៦ មន្ទីរពាណិជ្ជកម្មនោះដែរ។ ហើយអ្នកទាំងនោះ ខ្ញុំយល់ថាស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ផាន ឃួន បាទ។ គឺអ្នកទាំងអស់នោះមកដល់ ស-២១ នៅថ្ងៃទី២៣ វិច្ឆិកា ឆ្នាំ១៩៧៧។ បាទ ហើយនេះជាបញ្ជីអ្នកដែលគេចាប់មកពីយ-- មកពីមណ្ឌលគិរីមក ស-២១ ហើយកម្មាភិបាលនារីនោះ ក៏មានប្រពន្ធរបស់ ស្វាយ ផងដែរ។ គាត់ឈ្មោះ ស៊ីវ ខន ហៅ លី។ គាត់នៅលេខ ១២៩ នៅក្នុងបញ្ជីនេះ។

ផ្អែកទៅលើសក្ខីកម្មរបស់លោកនោះ គឺថា ជួន បានរួមដំណើរជាមួយលោកមកភ្នំពេញ បន្ទាប់ពី ឡាំង ស្លាប់នោះ ថាតើអ្វីដែលខ្ញុំនិយាយនោះ គឺអាចធ្វើឲ្យលោកនឹកឃើញឡើងវិញទេ គឺកាលបរិច្ឆេទដែល ឡាំង ស្លាប់ ហើយនិងកាលបរិច្ឆេទដែលលោកមកភ្នំពេញនោះ គឺមុនថ្ងៃទី២៣ ខែ១១ ឆ្នាំ ១៩៧៧ ដែរឬទេ?

**លោក សៅ សារុន៖**

**ឆ៖** បាទ គឺខ្ញុំអត់ដឹងទេ។ កាលពី៧៧ ហ្នឹង គឺខ្ញុំនៅស្រុកនៅឡើយទេ ខ្ញុំអត់ដឹងគេចាប់ពីណាពីណាជូនមក ស-- ទេ អត់ដឹង។ អាហ្នឹង គឺខ្ញុំអត់យល់ អត់ដឹងសោះ។ អាហ្នឹង ខ្ញុំសូមបដិសេធ។

**ស៖** លោក សៅ សារុន គឺថាការចងមានលំបាក គឺជាការពិតហើយ លោកមានការពិបាកចងចាំកាលបរិច្ឆេទ ប៉ុន្តែគឺអាចមុនខែហ្នឹង ឆ្នាំហ្នឹងទេ ដែលថា ឡាំង និង ជួន ហើយនិងកម្មាភិបាលមួយទៀតនោះត្រូវបានស្លាប់នៅភ្នំពេញ។ អ៊ីចឹងមិនឲ្យលោកចាំជាក់លាក់ទេ គ្រាន់តែថា តើការដែល ឡាំង

ស្លាប់ហ្នឹង មុនពេលហ្នឹង ឬពេលណា?

**ឆ៖** បាទ ឡាំង ស្លាប់ គឺឆ្នាំ១៩៧៨ ជូនអ្នកទោស អ្នកអីហ្នឹងតាំងពី៧៧ គឺខ្ញុំអត់យល់ទេ អត់យល់ អត់ដឹងសោះ ខ្ញុំអត់មានការពាក់ព័ន្ធពីរឿងជាប់មនុស្សអីទេបាទ។

[០៩:២៧:២០]

**ស៖** សំណួរដែលខ្ញុំចង់សួរលោកនោះ លោកសាក្សី គឺសួរថា តើអ្នកណាជាអ្នកសម្រេចចាប់ ជួន ហើយនិងកម្មាភិបាលផ្សេងៗទៀតមកពីមន្ទីរពាណិជ្ជកម្មរបស់តំបន់១០៥ គឺដែលពួកនោះចូលមកដល់មន្ទីរ ស-២១ នៅថ្ងៃទី២៣ វិច្ឆិកា ឆ្នាំ១៩៧៧ ដែលលោកជាលេខាស្រុកហ្នឹង ថាតើលោកបានឮអ្នកណាម្នាក់ប្រាប់ថា គេទទួលការណែនាំ ឬក៏បញ្ជាមកពីលើ ដើម្បីឲ្យចាប់កម្មាភិបាលហ្នឹង បញ្ជូនមក ស-២១ ឬក៏លោកបានដឹងដោយខ្លួនឯងពីរឿងហ្នឹង។ តើលោកអាចប្រាប់ខ្ញុំ និងតុលាការបានទេ ពីរឿងនេះ?

**ឆ៖** បាទ ខ្ញុំអត់យល់ទេ ពីព្រោះគេឃើញហៅទៅ ហៅបាត់ៗ គឺម្នាក់ៗ គឺចេះតែភ័យ ចេះតែព្រួយទៅ។ បាទ ខ្ញុំអត់យល់។

**ស៖** តើលោកជឿថា ជួន គឺជាជនក្បត់ដែលត្រូវតែអង្គការចាប់ខ្លួនទេ?

**ឆ៖** អត់យល់ទេ មិនដឹងថា ក្បត់ មិនក្បត់ ខ្ញុំអត់យល់សោះបញ្ហានេះ។

[០៩:២៩:០២]

**ស៖** តើលោកបានស្គាល់កម្មាភិបាលនារី ដែលធ្វើការនៅ ក-១៦ ជាមន្ទីរពាណិជ្ជកម្មតំបន់ដែរឬទេ?

**ឆ៖** អត់ស្គាល់សោះបាទ។

**ស៖** តើតំបន់១០៥ លេខាតំបន់ហ្នឹងមានសិទ្ធិអំណាចក្នុងការបញ្ជាឲ្យគេចាប់កម្មាភិបាលទាំងអស់នោះ ហើយបញ្ជូនពួកគេមកភ្នំពេញដែរឬទេ?

**ឆ៖** អត់យល់ ពីព្រោះខ្ញុំនៅស្រុក ក្របខ័ណ្ឌគេតំបន់ ខ្ញុំអត់យល់ កិច្ចការគេ ខ្ញុំអត់យល់សោះ។ ខ្ញុំយល់តែការងារខ្ញុំក្នុងស្រុកតែមួយគត់។

[០៩:៣០:០០]

**លោក ខេល លីសាក់៖**

លោកប្រធាន ឥឡូវនេះ ខ្ញុំសូមអនុញ្ញាតយោងទៅរកចម្លើយទីមួយរបស់សាក្សីនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត គឺE3/367។ ERN ជាភាសាខ្មែរ គឺ00251440 ហើយភាសាអង់គ្លេស គឺ

ERN គឺ00278697 បារាំង ERN គឺ00486013។ ហើយសូមអនុញ្ញាតបង្ហាញឯកសារនេះ នៅលើអេក្រង់ផងដែរបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី នៅក្នុងចម្លើយរបស់លោកដំបូងទៅនឹងសហចៅក្រមស៊ើបអង្កេត លោកបាននិយាយដូចតទៅនេះ គឺថា "ខ្ញុំដឹងថា មនុស្សមួយចំនួនត្រូវបានគេបញ្ជូនមកភ្នំពេញ ប៉ុន្តែខ្ញុំមិនដឹងថាតើគេបញ្ជូនទៅទីណាទេ។ ហើយនេះជាបញ្ហារបស់អង្គការដោយ តាសាន"។ តើលោកអាចបញ្ជាក់បានដែរឬទេ ថាតើនេះជាចម្លើយដែលត្រឹមត្រូវ ដែលពិតប្រាកដ?

[០៩:៣១:៣៥]

**លោក សៅ សារុន៖**

**ឆ៖** ទេ បាទ ខ្ញុំអត់យល់ទេ គេជូនទៅប៉ុន្មានៗ ខ្ញុំអត់យល់ទេ បាទ។ អាហ្នឹងគឺខ្ញុំអត់យល់សោះ គេជូនចំនួនប៉ុន្មាន អត់ដឹង។

**ស៖** ថាតើអ្នកណាជាអ្នកដែលត្រូវគេចាប់ឃុំឃាំង ហើយបញ្ជូនមកភ្នំពេញហ្នឹង តើអ្នកណាខ្លះ?

**ឆ៖** បាទ អត់ដឹង ពីព្រោះកិច្ចការងារគេ ខ្ញុំអត់ដឹង។

**ស៖** តើធ្វើយ៉ាងដូចម្តេចទើបលោកដឹងថាអ្នកត្រូវបានគេឃុំឃាំងហ្នឹង ត្រូវបានគេបញ្ជូនពីមណ្ឌលគិរី មកភ្នំពេញ តើលោកធ្វើយ៉ាងម៉េចទើបដឹង?

**ឆ៖** អត់ដឹងទេ គឺខ្ញុំដូចខ្ញុំជម្រាបខាងលើ។

**ស៖** នៅក្នុងចម្លើយរបស់លោក លោកនិយាយថា ការបញ្ជូនមនុស្សហ្នឹង គឺត្រូវធ្វើឡើងដោយបញ្ហារបស់អង្គការ គឺតាសាន។ តើលោកអាចជម្រាបបានដែរឬទេ ថាតើអ្នកណាជាតាសាន នោះ?

**ឆ៖** បាទ ខ្ញុំអត់ជម្រាបអត់បានទេ ពីព្រោះខ្ញុំនៅក្នុងក្របខ័ណ្ឌស្រុក។ គាត់មកនែ៎ ការងារក្នុងតំបន់ហ្នឹង គឺខ្ញុំអត់យល់។ មិនដឹងពីណាបញ្ហា មិនដឹងពីណាអី អត់យល់ទេ។

**ស៖** បុគ្គលដែលលោកហៅថា តាសាន ហ្នឹង តើតាសាន ហ្នឹង គឺជាអនុលេខាកងពល៩២០ តើគឺ តាសាន ហ្នឹង មែន ឬក៏មិនមែន?

**ឆ៖** គឺមែន។ បាទ មែន អាហ្នឹងជាកងពល៩២០ មែន។

**ស៖** ហើយនេះគឺជាបុគ្គលតែមួយ ដែលលោកបានជម្រាបយើងពីម្សិលមិញហ្នឹង ដែលថាប៉ុល ពត បានស្នើឱ្យលោកទទួលខុសត្រូវទៅតំបន់១០៥។ តើនេះគឺជាមនុស្សតែមួយ ដែលប៉ុល ពត ប្រាប់ថា ឱ្យជួយលោក ក្នុងការកាន់តួនាទីហ្នឹង តើមែនទេ?

**ឆ៖** បាទអ៊ីចឹងហើយ។ គាត់ឱ្យខ្ញុំធ្វើការងារនៅក្នុងតំបន់១០៥ ខ្ញុំដូចខ្ញុំជម្រាបម្សិលមិញ ខ្ញុំអត់ធ្វើ។

**ស៖** នៅពេលដែលលោកត្រឡប់មកមណ្ឌលគិរី បន្ទាប់ពីប្រជុំជាមួយប៉ុល ពត, នួន ជា និង សុន សេន នោះ តើលោកមានប្រជុំជាមួយ តាសាន ដែរឬទេ? តើនៅក្នុង-- តើមានកិច្ចប្រជុំណាហ្នឹង ដែលតាសាន គាត់រៀបរាប់ពីមនុស្សដែលត្រូវចាប់ខ្លួនពីមណ្ឌលគិរី តើមានដែរឬទេ?

[០៩:៣៥:០០]

**ឆ៖** បាទ អត់ទេ។ មកពីមណ្ឌល-- អំ! ពីភ្នំពេញទៅ ខ្ញុំក៏ទៅស្រុកខ្ញុំបាទ។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំចង់ដកស្រង់នូវកិច្ចសម្ភាសទីមួយរបស់សាក្សីហ្នឹង គឺឯកសារដែលមាន E3/267 ហើយ ERN ខ្មែរគឺ 00251440 ដល់ 251441 ហើយភាសាអង់គ្លេសគឺ 00278697 ហើយ ភាសាបារាំងគឺ 0048610013 ហើយខ្ញុំសូមបង្ហាញនៅលើអេក្រង់ទូរទស្សន៍ និងកុំព្យូទ័រ។ សូមលោក ប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! ប៉ុន្តែអ្នកបកប្រែភាសាខ្មែរទំនងជាអាចជាខុសឯកសារ។ មិនមែន E3/267 ទេ 367 ណា!

[០៩:៣៦:៣៣]

**លោក ឌេល លីសាក់៖**

បាទ លោកប្រធាន គឺជាការត្រឹមត្រូវហើយ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ហើយលោកសាក្សីនៅក្នុងចម្លើយរបស់លោកជាមួយនឹងសហចៅក្រមស៊ើបអង្កេត លោកនិយាយដូចតទៅនេះ។ ហើយខ្ញុំសូមដកស្រង់ "តាសាន មកពីខាងកងពល៩២០ បានជួបប្រជុំ

ជាមួយ តាសុភា ហើយនិងខ្ញុំ ហើយបាននិយាយផ្ទាល់មាត់អំពីការចាប់ខ្លួន។ ឧទាហរណ៍ ដូចជាករណីចាប់ខ្លួន ណេត ថា ពោលគឺ តាសាន បានកាន់បញ្ជីមករួចជាស្រេច ហើយខ្ញុំមិនអាចបដិសេធ"។ តើលោកអាចបញ្ជាក់បានដែរឬទេថា ចម្លើយដែលលោកផ្តល់ជាមួយនឹងសហចៅក្រមស៊ើបអង្កេតហ្នឹង គឺជាចម្លើយដែលត្រឹមត្រូវ?

**លោក សៅ សារុន៖**

**ឆ៖** បាទ អាហ្នឹងគឺជាចម្លើយ អាហ្នឹងគឺត្រឹមត្រូវ ពីព្រោះគេខាងលើបញ្ជាហើយ គឺខ្ញុំក៏មិនប៊ានតវ៉ាជាមួយគេដែរបាទ។

[០៩:៣៧:៣៨]

**ស៖** តើនៅពេលណាដែលលោកមានប្រជុំជាមួយនឹង តាសុភា ហើយនិង តាសាន នៅកងពលហ្នឹង? តើកិច្ចប្រជុំហ្នឹងធ្វើឡើងនៅពេលណា? តើលោកអាចប្រៀបធៀបបានដែរឬទេ តើមានរយៈពេលប៉ុន្មានបន្ទាប់លោកត្រឡប់ពីភ្នំពេញមកមណ្ឌលគិរីវិញ? តើប្រហែលជាប៉ុន្មានដែរ?

**ឆ៖** បញ្ហានេះខ្ញុំអត់យល់ទេ។ ភ្លេចអស់ ពីព្រោះខ្ញុំតាំងពីឈឺនេះ ខ្ញុំដូចជម្រាបលោក ភ្លេចការចងចាំ បាទ អស់។

[០៩:៣៨:២២]

**ស៖** តើលោកចាំដែរឬទេ តើនៅពេលណាដែលលោកជួបជាមួយ តាសុភា និងតាសាន? តើនៅទីណាដែរ តើលោកជួបហ្នឹងនៅទីណាដែរ?

**ឆ៖** បាទ ខ្ញុំអត់ស្គាល់ ជួបដឹងថ្ងៃណាខែណាទេ។ ខ្ញុំនៅឯស្រុកហ្នឹងគេទៅហៅមក។ ជួបដឹងថ្ងៃខែខ្ញុំអត់ដឹង ភ្លេចអស់ហើយ បាត់ការចងចាំ។

**ស៖** តើលោកចាំបានដែរឬទេ តើមានមនុស្សប៉ុន្មាននាក់នៅក្នុងបញ្ជី? តើមានឈ្មោះមនុស្សប៉ុន្មាននាក់នៅក្នុងបញ្ជីដែលគេយកមកនោះ?

**ឆ៖** អត់ដឹង ក្តាប់អត់បាន វាស្រេចតែគេខាងលើ។

**ស៖** ហើយបុគ្គលដែលលោកបានបង្ហាញនៅក្នុងចម្លើយរបស់លោកឈ្មោះ ណេត ថា ហ្នឹងតើជានរណាដែរ? លោកអាចប្រាប់បានទេ?

**ឆ៖** បាទ ខ្ញុំ-- ណេត ថា ហ្នឹងខ្ញុំដូចអត់សូវយល់ អត់យល់ទេ។ ដឹងខ្ញុំ--

**ស៖** តើលោកចាំដែរឬទេថា ណេត ថា ហ្នឹងគឺជាអនុលេខាខាងសេដ្ឋកិច្ច ដែលនៅក្រោម ខាំ

ភួន នុំង តើលោកចាំដែរឬទេ?

[០៩:៤០:១១]

**ឆ៖** បញ្ហាហ្នឹងខ្ញុំអត់ចាំទេ។ គេកិច្ចការក្នុងតំបន់គេចាត់តាំងអ្នកណាៗ ខ្ញុំអត់យល់។ ខ្ញុំការងារខ្ញុំយល់តែការងារស្រុកខ្ញុំតែមួយបាទ។

**ស៖** ឥឡូវនេះ ខ្ញុំចង់លើកប្រធានបទផ្សេងមួយទៀតមកនិយាយ គឺទាក់ទងទៅនឹងរបាយការណ៍ រួមទាំងទូរលេខ ដែលលោកបានបញ្ជូនមកភ្នំពេញនៅក្នុងឆ្នាំ៧៨។ តើលោកចាំដែរឬទេថា នៅក្នុងការផ្ដល់ចម្លើយជាមួយសហចៅក្រមស៊ើបអង្កេតនុំង គឺ គេបានបង្ហាញ ហើយនិងចោទសួរអំពីទូរលេខមួយចំនួនដែលលោកបានបញ្ជូនមកភ្នំពេញ? តើលោកចាំដែរឬទេ?

[០៩:៤១:២១]

**ឆ៖** បាទ ខ្ញុំចាំ។

**ស៖** ទូរលេខទីមួយ ដែលគេលើកនុំង គឺឯកសារដែលមានលេខ E3/248 គឺចុះថ្ងៃ០១ មករា ឆ្នាំ១៩៧៨។ ខ្ញុំនឹងលើកយកបញ្ហាមួយចំនួននៅក្នុងឯកសារនេះ។ ដូច្នេះ អ្វីដែលខ្ញុំចង់សួរលោកដំបូង គឺថា តើវាអាចធ្វើឲ្យលោកនឹកឃើញដែរឬទេថា នៅថ្ងៃ០១ មករា ឆ្នាំ៧៨ នុំង លោកបានបញ្ជូននូវរបាយការណ៍ជាលាយលក្ខណ៍អក្សរ ឬក៏ជាទូរលេខមួយហ្នឹងមកមេដឹកនាំនៅក្នុងទីក្រុងភ្នំពេញ? តើលោកនឹកឃើញដែរឬទេ?

**ឆ៖** បាទ ខ្ញុំនឹកអត់ឃើញទេ។ ពីព្រោះខ្ញុំបាត់ការចងចាំ ដូចខ្ញុំជម្រាបខាងលើ តាំងពីឈឺមក។ បាត់ និយាយហើយក៏ភ្លេចមុខភ្លេចក្រោយបាទ។

[០៩:៤២:៤៨]

**ស៖** ដូច្នេះឥឡូវនេះ ខ្ញុំចាប់ផ្ដើមពីសំណួរទូទៅមួយចំនួន ថាតើលោកបញ្ជូនរបាយការណ៍ ឬក៏បញ្ជូនទូរលេខហ្នឹងតាមរបៀបណា? ហើយលោកធ្វើយ៉ាងណា? តើលោកអាចជម្រាបយើងបានដែរឬទេថា តើៗលោកវ៉ៃអង្គុលីលេខនៅលើទូរលេខហ្នឹង ឬមួយក៏លោកសរសេរដៃនៅពេលដែលលោកបញ្ជូនទូរលេខនុំងមកមេដឹកនាំនៅទីក្រុងភ្នំពេញនោះ? តើលោកសរសេរផ្ទាល់ដៃ ឬក៏វ៉ៃអង្គុលីលេខ?

**ឆ៖** បាទ អាហ្នឹងគឺការគេ-- គេអ្នកសរសេរ។ បាទ សូមអស់។

**លោក ខេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមលើកយកនូវឯកសារនៃកិច្ចសម្ភាសទីបី ជាមួយនឹងសហចៅក្រមស៊ើប

អង្កេត គឺកិច្ចសម្ភាសដែលមានលេខ E3/384 នៅ ERN ខ្មែរ 00345905 ភាសាអង់គ្លេសគឺ 00348374 ហើយភាសាបារាំងគឺ 00354231--238។ ហើយខ្ញុំក៏សូមអនុញ្ញាតដាក់បង្ហាញនៅលើអេក្រង់ទូរទស្សន៍ និងកុំព្យូទ័រផងដែរលោកប្រធាន។

[០៩:៤៤:៣៦]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី នៅក្នុងកិច្ចសម្ភាសជាមួយនឹងសហចៅក្រមស៊ើបអង្កេត នៅពេលដែលគេសួរលោកអំពីទូរលេខ ដែលជាទូរលេខ លេខ៥៤ នោះ គេបានចោទសួរនូវសំណួរដូចតទៅ៖ “តើលោកសរសេរទូរលេខហ្នឹងដោយផ្ទាល់ដៃ ឬក៏លោកវាយអង្គុលីលេខ? តើលោកសរសេរទូរលេខនេះដោយដៃ ឬហៅផ្ទាល់ឲ្យអ្នកវាយអង្គុលីលេខវាយ? ខ្ញុំសរសេរអក្សរដោយដៃ រួចហើយយកទៅឲ្យអ្នកបកប្រែឲ្យចេញជាលេខ បន្ទាប់មកអ្នកប្រែយកទៅឲ្យអ្នកវាយទូរលេខ”។ តើនេះជាចម្លើយដែលត្រឹមត្រូវនៃការបញ្ជូនទូរលេខ គឺជាដំណើរការដែលលោករៀបចំ ក្នុងការបញ្ជូនទូរលេខ តើវាត្រឹមត្រូវដែរឬទេ?

**លោក សៅ សារុន៖**

**ឆ៖** បាទ អាហ្នឹង គឺត្រឹមត្រូវ។

**ស៖** តើមន្ទីរទូរលេខហ្នឹង ៗ នៅកន្លែងណាដែរក្នុងមណ្ឌលគិរីនោះ?

**ឆ៖** បាទ នៅក្នុង ក-១៧ កន្លែងតំបន់។

**ស៖** ចាតើអ្នកណាខ្លះដែលនៅមន្ទីរទូរលេខហ្នឹង ដែលបានជួយលោកក្នុងការបញ្ជូនទូរលេខហ្នឹង តើពួកគាត់ជានរណា?

**ឆ៖** បាទ គេ-- ខ្ញុំអត់ស្គាល់អ្នកណាទេ។ ខ្ញុំស្គាល់តែម្នាក់ដែលអ្នកបកសារណាហ្នឹង ពីព្រោះខ្ញុំទើបមកកាន់កាប់ការងារថ្មី ខ្ញុំនៅមិនទាន់ស្គាល់ពីណា។ ស្គាល់តែអ្នកបកសារតែមួយគត់បាទ។

[០៩:៤៦:៤៩]

**ស៖** តើលោកផ្ញើទូរលេខមកមេដឹកនាំមកភ្នំពេញហ្នឹងញឹកញាប់ប៉ុនណាដែរ?

**ឆ៖** បាទ អត់មានញឹកញាប់ទេ ជួនកាលមួយអាទិត្យ ជួនកាលក៏ពីរអាទិត្យទៅម្ដងក៏មានទៅ។

**លោក ខេល លីសាក់៖**

លោកប្រធាន ខ្ញុំចង់ស្នើសុំដាក់សំណួរទៅលើសាក្សីទាក់ទងទៅនឹងចម្លើយកាលពីលើកមុន គឺជាកិច្ចសម្ភាសលើកទីពីរ ជាមួយនឹងសហចៅក្រមស៊ើបអង្កេត គឺឯកសារដែលមានលេខ E3/383 ខ្មែរ ERN គឺ 00345913, ភាសាអង់គ្លេសគឺលេខ 00350264 និងភាសាបារាំងគឺមានលេខ 00361761--764 ហើយខ្ញុំសូមបង្ហាញនៅលើអេក្រង់ទូរទស្សន៍ និងកុំព្យូទ័រ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

[០៩:៤៨:២១]

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោកសាក្សីនៅក្នុងចម្លើយដែលលោកផ្តល់ទៅសហចៅក្រមស៊ើបអង្កេតនេះ គឺលោកបាននិយាយដូចតទៅ ខ្ញុំសូមដកស្រង់៖ "ខ្ញុំត្រូវរាយការណ៍ប្រចាំថ្ងៃ យ៉ាងហោចណាស់ក៏អំពីការផលិតស្រូវ ធាតុអាកាស ដាំបានតិច ឬបានច្រើន"។ តើលោកបញ្ជាក់បានទេថា នេះជាចម្លើយដែលត្រឹមត្រូវ? តើលោកសាក្សីអាចបញ្ជាក់បានទេថា វាជាចម្លើយដែលត្រឹមត្រូវ?

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាង-- អ៎! លោកមេធាវីការពារក្តី នួន ជា!

[០៩:៤៩:០៥]

**លោក ហ្សាស្តេី ប៉ៅ៖**

សូមអរគុណលោកប្រធាន ហើយខ្ញុំសូមទោសដែលខ្ញុំត្រូវរំខាន។ ការជំទាស់របស់ខ្ញុំគឺ មិនពាក់ព័ន្ធសំខាន់ទៅលើប្រធានបទនោះទេ ប៉ុន្តែអ្វីដែលខ្ញុំចោទនិយាយគឺពីបច្ចេកទេសនៃការចោទសួរដែលផ្អែកទៅលើចម្លើយដែលផ្តល់ឲ្យសហចៅក្រមស៊ើបអង្កេត។ ហើយខាងព្រះរាជអាជ្ញាបានដាក់នូវសំណួរមួយចំនួនដោយអាននូវចម្លើយដែលសាក្សីផ្តល់ទៅសហចៅក្រមស៊ើបអង្កេត ហើយបន្ទាប់មកសួរសាក្សីថា តើវាត្រឹមត្រូវឬក៏អត់? ហើយខ្ញុំគិតថា ការធ្វើបែបនេះ គឺមិនបានប្រាប់អ្វីឲ្យបានច្រើនដល់យើងទេ ព្រោះថាតាំងពីដើមមកគឺសាក្សីគាត់តែងបញ្ជាក់រួចទៅហើយថា ចម្លើយរបស់គាត់ជាមួយសហចៅក្រមស៊ើបអង្កេតហ្នឹងគឺជាចម្លើយដែលត្រឹមត្រូវពិតប្រាកដ។ ខ្ញុំគិតថា វាមានប្រយោជន៍ជាង បើសិនបើយើងចោទសួរសំណួរ ឬក៏យើងនិយាយថា តើលោកចាំដែរឬទេថា ការនេះៗ ឬក៏ការនោះៗ វាកើតឡើងនៅពេល

ណា? បែបណា? ឬក៏យ៉ាងបែបណា? ជាជាងការដែលចោទសួរថា ចម្លើយចំពោះសហចៅក្រមស៊ើបអង្កេតត្រូវ ឬក៏មិនត្រូវ។

ដូច្នេះ ខ្ញុំគិតថា វាមិនពាក់ព័ន្ធទៅលើប្រធានបទនេះទេ ប៉ុន្តែព្រះរាជអាជ្ញាគាត់នឹងធ្វើបែបនេះដដែលៗ ឡើងវិញ។ ដូច្នេះខ្ញុំគិតថា ស្នើឲ្យខាងសហព្រះរាជអាជ្ញាគាត់ធ្វើការចោទសួរសំណួរដែលមានលក្ខណៈប្លែក ឬក៏ខុសពីនេះបន្តិចទៅ។ សូមអរគុណ។

[០៩:៥០:៣៨]

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំទទួលស្គាល់នូវអ្វីដែលលោកបានលើកឡើង ប៉ុន្តែខ្ញុំគិតថា ខ្ញុំនឹងបន្ត បន្ទាប់មកខ្ញុំនឹងធ្វើដដែល-- ធ្វើដូចគ្នានេះ គឺថាខ្ញុំនឹងសួរថា ត្រូវ ឬមិនត្រូវ? បន្ទាប់មកខ្ញុំនឹងដាក់សំណួរបំពេញបន្ថែមទៀត។ ដូច្នេះអានេះ គឺជាមធ្យោបាយមួយដ៏ល្អ។ ប្រសិនបើលោកប្រធានអនុញ្ញាត ខ្ញុំនឹងបន្តទៅមុខទៀត។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញបន្តទៅមុខទៀតចុះ!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោក សៅ សារុន ចម្លើយដែលលោកផ្តល់ជាមួយនឹងសហចៅក្រមស៊ើបអង្កេត បានបង្ហាញថា លោកបញ្ជូនទូរលេខ និងរបាយការណ៍ហ្នឹងជារៀងរាល់ថ្ងៃ។ តើនេះជាចម្លើយត្រឹមត្រូវដែរឬទេ? តើវាធ្វើឲ្យលោកនឹកឃើញដែរឬទេ ថានៅក្នុងឆ្នាំ១៩៧៨ ហ្នឹងលោកបញ្ជូនទូរលេខជារៀងថ្ងៃទៅឲ្យមេ ទៅឲ្យមេដឹកនាំ?

[០៩:៥១:៤៩]

**លោក សៅ សារុន៖**

**ឆ៖** បាទ អាហ្នឹងគឺពិត។ ជួនកាលក៏រាល់ថ្ងៃ ជួនកាលក៏ពីរបីថ្ងៃ ឬក៏មួយអាទិត្យម្តងក៏មានអាហ្នឹង បាទ។

**ស៖** នៅពេលដែលលោកបញ្ជូនទូរលេខទៅទីក្រុងភ្នំពេញ តើលោកបញ្ជូនទូរលេខហ្នឹងដោយផ្ញើជូនអ្នកណាដែរ ពេលដែលលោកបញ្ជូនទៅភ្នំពេញនោះ?

**ឆ៖** បាទ ជូនទៅលោក ប៉ុល ពត។

**សៈ** តើលោកចាំដែរឬទេថា លោកធ្លាប់បញ្ជូនទូរលេខទៅមន្ទីរ៨៧០? តើលោកធ្លាប់ចាំដែរឬទេ?

**ឆៈ** បាទ បញ្ហាហ្នឹងអត់ចាំទេ តាំងពីខ្ញុំឈឺខ្លួនមកខ្ញុំភ្លេចការចងចាំអស់។

[០៩:៥៣:១៧]

**សៈ** តើលោកធ្លាប់ទទួលបានចម្លើយតបទៅនឹងទូរលេខ ដែលលោកបានបញ្ជូនទៅភ្នំពេញដែរឬទេ?

**ឆៈ** បាទ បានទទួលការណែនាំ គឺសំខាន់គឺធ្វើស្រែ ធ្វើចម្ការប៉ុណ្ណឹងបាទ។

**សៈ** នៅពេលដែលលោកទទួលបានចម្លើយតប ដែលមានការណែនាំ តើអ្នកណាជាអ្នកផ្ញើនូវការណែនាំ គឺផ្ញើនូវចម្លើយតបដែលជាការណែនាំមកលោកវិញ តើអ្នកណាដែរ?

**ឆៈ** បាទ គេណែនាំតាមទូរលេខដដែល។

**សៈ** តើលោកចាំដែរឬទេថា តើអ្នកណាជាអ្នកបញ្ជូននូវទូរលេខ ឬក៏បញ្ជូននូវការណែនាំ ដែលជាការឆ្លើយតបទៅនឹងទូរលេខរបស់លោក? តើអ្នកណាដែរ ដែលជាអ្នកផ្ញើមកវិញ?

**ឆៈ** បាទ ហ្នឹងខ្ញុំអត់ស្គាល់ទេ។ ដឹងពីណាៗ គេសម្គាល់តែអ្នកគេខាងទូរលេខទេបាទ។

[០៩:៥៥:០២]

**លោក ខេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមដកស្រង់នូវកិច្ចសម្ភាសដដែលនេះ គឺឯកសារដែលមានលេខ E3/383 ហើយ ERN សម្រាប់ចំណុចនេះ គឺភាសាខ្មែរមានលេខ 00345912 ភាសាអង់គ្លេសគឺមានលេខ 00350263 ហើយនិងភាសាបារាំងគឺមានលេខ 003616-- 763។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតលោកប្រធានដាក់បង្ហាញនៅលើអេក្រង់។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**លោក ខេល លីសាក់៖**

សូមអរគុណ។

**សួរដោយលោក ខេល លីសាក់៖**

**សៈ** លោកសាក្សីនៅក្នុងកិច្ចសម្ភាសទីបីរបស់លោកជាមួយសហចៅក្រមស៊ើបអង្កេតគឺគេចោទសួរថា៖ “តើលោកបានទទួលនូវទូរលេខឆ្លើយតប ដែលជាការឆ្លើយតបទៅនឹងទូរលេខរបស់លោកដែរ

ឬទេ?" គឺលោកបានឆ្លើយថា៖ "អ្នកផ្ញើហ្នឹង គឺផ្ញើមកពីមន្ទីរ៨៧០ គឺមានពី នួន ជា និង ប៉ុល ពត។ ពេលខ្លះគេបង្ហាញថា-- ពេលខ្លះដាក់ថា ម-៨៧០ ពេលខ្លះដាក់ថា ប៉ុល ពត ហើយពេលខ្លះដាក់ថា នួន ជា ឬ ប៉ុល ពត តែម្តង"។ តើលោកអាចបញ្ជាក់បានដែរទេ ថានេះជាចម្លើយដែលត្រឹមត្រូវ លោកសាក្សី?

[០៩:៥៦:៤៤]

**លោក សៅ សារុន៖**

**ឆ៖** បាទ ខ្ញុំអត់បានបញ្ជាក់ទេ គឺអាហ្នឹង ចម្លើយហ្នឹងគឺជាវាការត្រឹមត្រូវហើយ។

**ស៖** ដូច្នេះ ចម្លើយរបស់លោកគឺលោកចង់និយាយថា ពេលខ្លះលោកទទួលទូរលេខមកពី ប៉ុល ពត ពេលខ្លះមកពី នួន ជា ហើយពេលខ្លះមកពីមន្ទីរ៨៧០ តើលោកចង់និយាយបែបនេះមែនទេ?

**ឆ៖** បាទ មែន ពិតមែនអ៊ីចឹងបាទ។

**ស៖** នៅក្នុងចម្លើយដែលខ្ញុំទើបតែនឹងអានជូនលោកហ្នឹង គឺនិយាយអំពីម-៨៧០ ហ្នឹង តើលោកអាចប្រាប់បានទេថា ម-៨៧០ ហ្នឹង គឺជាអ្វី?

**ឆ៖** បាទ ខ្ញុំអត់យល់ទេ ឮតែថាម១-៨៧០ ហ្នឹង ជាដឹងកន្លែងស្អី១របស់គេ ខ្ញុំអត់យល់។ ដឹងតែថា ម-៨៧០១។ យល់តែប៉ុណ្ណឹង។

**ស៖** ឥឡូវនេះខ្ញុំចង់លើកយកនូវទូរលេខទីមួយដែលខ្ញុំចង់សួរលោក។

**លោក ឌេល លីសាក់៖**

លោកប្រធានខ្ញុំសូមបង្ហាញឯកសារ E3/284-- 248 គឺនៅថ្ងៃ០១ មករា ឆ្នាំ១៩៧៨ ហើយជាទូរលេខមកពីលោក សារុន៖ "ផ្ញើជូនបងជាទីគោរព និងស្នេហា ៨៧០"។ ហើយខ្ញុំសូមអនុញ្ញាតដាក់បង្ហាញនៅលើអេក្រង់ទូរទស្សន៍។ ហើយបន្ទាប់មក ខ្ញុំនឹងអាននូវផ្នែកមួយចំនួននៃទូរលេខនេះឲ្យសាក្សីស្តាប់ ហើយខ្ញុំនឹងចោទសំណួរទៅគាត់។ សូមលោកប្រធានអនុញ្ញាត។

[០៩:៥៩:០៣]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោក សារុន នៅក្នុងទូរលេខមួយនេះ គឺមានដាក់ឈ្មោះរបស់លោក ព្រមទាំងកាល

បរិច្ឆេទ គឺថ្ងៃ០១ ខែមករា ឆ្នាំ១៩៧៨។ ហើយៗឯក-- ហើយទូរលេខនេះគឺបង្ហាញថា៖ "គោរពជូនបង ម-៨៧០ ជាទីគោរពស្នេហា"។ ឥឡូវនេះ ខ្ញុំចង់សួរលោកថា នៅពេលដែលលោកផ្ញើនូវទូរលេខទៅមន្ទីរ ៨៧០ តើលោកដឹងថា តើលោកផ្ញើទៅអ្នកណាទេ នៅពេលដែលលោកសរសេរថា "ជូនមន្ទីរ៨៧០" ហ្នឹង?

[១០:០០:១២]

**ឆ៖** បាទ គឺ៨៧០ ហ្នឹង គឺថាលោក ប៉ុល ពត។

**លោក ខេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមអាននូវចម្លើយដែលសាក្សីផ្តល់នៅក្នុងកិច្ចសម្ភាសន៍ទីពីរ គឺឯកសារដែលមានលេខ E3/383 ហើយ ERN ភាសាខ្មែរ គឺមានលេខ 00345912, ភាសាអង់គ្លេស គឺមានលេខ 00350263 ហើយភាសាបារាំង គឺ 00361763។ ហើយខ្ញុំសូមអនុញ្ញាតលោកប្រធានដាក់បង្ហាញនៅលើអេក្រង់។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

[១០:០១:២៨]

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោកសាក្សីនៅពេលដែលគេសួរលោកអំពីទូរលេខ នៅពេលដែលសហចៅក្រមស៊ើបអង្កេតសួរលោកនូវសំណួរដែលថា ពេលដែលដាក់ថា ម-៧៨ តើម-៧៨ ហ្នឹងសំដៅទៅលើអ្វី គឺលោកបានបញ្ជាក់ដូចតទៅ៖ "ម-៧៨ មានន័យថា ជាគណៈមជ្ឈិម ក្នុងនោះតាមខ្ញុំចាំ ប៉ុល ពត, នួន ជា, ខៀវ សំផន, សុន សេន និងតាម៉ុក"។ តើលោកអាចបញ្ជាក់បានទេ ថានេះជាចម្លើយដែលត្រឹមត្រូវ ដែលស្មោះត្រង់ ដែលលោកបានផ្តល់ឲ្យ?

**លោក សៅ សារុន៖**

**ឆ៖** អាហ្នឹង គឺជាការស្មោះត្រង់ បានដូច បានដូចជម្រាបជូន លោកសហចៅក្រមបាទ។ សូមអស់។

**លោក ខេល លីសាក់៖**

ដើម្បីកត់ត្រាឲ្យបានត្រឹមត្រូវ សហសេវិករបស់ខ្ញុំថា ការបកប្រែដូចល្បៀងបន្តិច គឺដូចថា ម-៧៨

តែតាមពិត គឺកែតម្រូវគឺ ម-៨៧០ វិញទេ បាទដែលត្រូវ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** តើខ្ញុំយល់ត្រឹមត្រូវដែរឬទេ អ្វីដែលលោកបានយល់នោះ គឺម-៨៧០ នោះ គឺដាក់មានបញ្ចូលមេដឹកនាំមួយចំនួន ដែលជាគណៈមជ្ឈិមរបស់បក្សកុម្មុយនីស្តកម្ពុជា តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ ខ្ញុំបញ្ហាហ្នឹង ខ្ញុំអត់យល់ទេបាទ។

[១០:០៣:៣១]

**ស៖** តើលោកនៅចាំទេ ថាតើអ្នកណាខ្លះស្ថិតនៅក្នុងគណៈមជ្ឈិមរបស់បក្សនៅឆ្នាំ១៩៧៨នោះ?

**ឆ៖** បាទ ខ្ញុំអត់យល់ អាហ្នឹងការងារខាងលើ ខ្ញុំអត់យល់ទេ។

**ស៖** តេឡេក្រាមលេខ ទូរលេខដែលបានចុះថ្ងៃទី០១ មករា ឆ្នាំ១៩៧៨ បានដាក់ខាងលើហ្នឹង គេថាជាតេឡេក្រាមលេខ៤៧ តើលោកអាចជម្រាបតុលាការបានទេ ថាតើលេខ៤៧នេះ មានន័យដូចម្តេចនៅក្នុងការបញ្ជាក់លេខនៅលើទូរលេខហ្នឹង តើលេខហ្នឹងសម្គាល់អ្វីបាទ?

**ឆ៖** បាទ ខ្ញុំអត់ស្គាល់ទេ។ គេចេះតែដាក់លេខ ដាក់លេខអ៊ីចឹង ពីព្រោះខ្ញុំ ពីខាងបច្ចេកទេស ខ្ញុំអត់យល់សោះបាទ។

[១០:០៤:៥២]

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតអានចម្លើយរបស់សាក្សីនៅក្នុង E3/383 ហើយនៅក្នុងការសម្ភាសទីពីរជូនទៅសហចៅក្រមស៊ើបអង្កេត ខ្មែរ ERN 00345910 រហូតដល់ 345911, អង់គ្លេស ERN 00350262 ហើយបារាំង ERN 00361762 ហើយសូមអនុញ្ញាតលោកប្រធាន ដើម្បីបង្ហាញឯកសារនេះនៅលើអេក្រង់ និងទូរទស្សន៍ផងដែរ បាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោក សៅ សារុន នៅក្នុងបទសម្ភាសន៍ជាមួយសហចៅក្រមស៊ើបអង្កេត នៅពេលដែលគេសួរលោកអំពីទូរលេខ គេសួរថា “តើនៅក្នុងទូរលេខ៤៧ នោះ បាននិយាយពីអ្វីខ្លះ?” ហើយលោកបានឆ្លើយដូចខាងក្រោមនេះ ហើយគឺជាលេខរៀង ដើម្បីពន្យល់ឲ្យអ្នកទទួលដឹង ដើម្បីឲ្យយើងងាយ

ស្រួលក្នុងការ-- សំណួរថាតើលេខរៀងនោះ ត្រូវដាក់តាមថ្ងៃនីមួយៗ ឬយ៉ាងដូចម្ដេច? ចម្លើយថា "លេខរៀងនោះ គឺពី១ ដល់១០០ ហើយលេខនោះ ត្រូវត្រឡប់មក១ វិញ បើសិនជាមិន វាច្រើនជាង ១០០ នោះ"។ តើលោកនៅចាំទេ អំពីចម្លើយដែលលោកបានផ្ដល់ទៅសហចៅក្រមស៊ើបអង្កេតបែបនេះនោះ បាទ?

[១០:០៦:៥៥]

**លោក សៅ សារុន៖**

**ឆ៖** បាទ គឺត្រឹមត្រូវ ដូចខ្ញុំបានជម្រាបជូនលោកសហចៅក្រមរួចហើយស្រេចបាទ។

**ស៖** តើត្រូវដែរឬទេ នៅពេលដែលគេបញ្ជូនទូរលេខចេញទៅ គេចុះលេខរៀងបន្តបន្ទាប់ ហើយកាលណាដល់លេខ១០០ ហើយត្រូវចាប់ពីមួយមកវិញ បើសិនជាដល់១០០ហើយ តើអ៊ីចឹងត្រូវដែរឬទេ?

**ឆ៖** បាទ គឺត្រឹមត្រូវហើយ អ៊ីចឹង។

**ស៖** ឥឡូវនេះ ត្រឡប់ទៅទូរលេខចុះថ្ងៃទី០១ មករា ឆ្នាំ១៩៧៨ គឺE3/248 ហើយខ្ញុំនឹងអានជូនលោកស្ដាប់អំពីកថាខណ្ឌទីមួយនៃទូរលេខដែលបានលោកបញ្ជូនទៅមន្ទីរ៨៧០ គឺនៅថ្ងៃទី០១ មករា ឆ្នាំ១៩៧៨។ កថាខណ្ឌទីមួយ នៃទូរលេខនោះ និយាយដូចខាងក្រោយនេះ "យើងខ្ញុំសូមរាយការណ៍អំពីស្រុកប្រជាជនយួន រត់មកចំនួន៩នាក់ តាមការសួរចម្លើយរបស់វា គឺវាថាយួន ចាត់ចែងឲ្យមកវាមកស៊ើបការណ៍នៅក្នុងប្រទេសកម្ពុជា ដើម្បីមករស់នៅនឹងប្រជាជនកម្ពុជា ដើម្បីក្ដាប់ប្រជាជនកម្ពុជា។ ឥឡូវនេះ បានបោសសម្អាតវាហើយ"។

សំណួរទីមួយរបស់ខ្ញុំចំពោះលោកនោះ គឺថាអ្នកណាជាអ្នកផ្ដល់ព័ត៌មានឲ្យលោកអំពីមនុស្សប្រាំបួននាក់ដែលលោករាយការណ៍ទៅមន្ទីរ៨៧០ ពីមនុស្សប្រាំបួននាក់នេះ ពួកយួន ប្រជាជនយួននេះ?

[១០:០៩:០២]

**ឆ៖** បាទ បញ្ហាហ្នឹង គឺខ្ញុំអត់យល់ ដូចខ្ញុំជម្រាបលោកសហចៅក្រមហើយ ខ្ញុំបដិសេធ។ ខ្ញុំអត់យល់។

**ស៖** តើលោកបានទទួលរបាយការណ៍មកពីយោធាតំបន់ ដែលក្រោយមកលោកបញ្ជូនរបាយ-ការណ៍ទៅមន្ទីរ៨៧០ ហ្នឹង មែនឬទេ លោកសាក្សី?

**ឆ៖** បាទ បញ្ហាហ្នឹង ខ្ញុំអត់យល់ដែរ។ ជូន ធ្លាប់រាយការណ៍ អត់មានរឿងថាចាប់ឃុំន ចាប់អីទេ។ រាយការណ៍ គ្រាន់តែថាធ្វើស្រែ ធ្វើចម្ការប៉ុណ្ណឹងឯង។

[១០:១០:០៩]

**លោក ឌេល លីសាក់៖**

លោកប្រធាន ឥឡូវនេះខ្ញុំសូមអនុញ្ញាតត្រឡប់ទៅកំណត់ហេតុស្តាប់ចម្លើយសាក្សីជាមួយសហចៅក្រមស៊ើបអង្កេត ហើយឯកសារ E3/383 សេចក្តីដកស្រង់ដែលខ្ញុំចង់អាននោះ គឺខ្មែរ ERN 00345912, អង់គ្លេស ERN 00350263 ហើយបារាំង ERN 00361763 សូមអនុញ្ញាតតុលាការដើម្បីបន្តអនុវត្តដូចនីតិវិធីធម្មតាបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី នៅពេលដែលគេសួរលោកអំពីទូរលេខនេះ ដែលសហចៅក្រមស៊ើបអង្កេតបានសួរលោក។ លោកបានឆ្លើយចម្លើយដូចខាងក្រោមនេះ៖

"សំណួរ៖ នៅក្នុងទូរលេខលេខ ៤៧ តើស្ថានភាព *(ឮមិនច្បាស់)* ហើយនិងតំបន់មួយនោះ នៅពេលនោះ"។ ហើចម្លើយរបស់លោក លោកឆ្លើយថា៖ នៅពេលនោះ ខ្ញុំបានទទួលរបាយការណ៍មកពីយោធាតំបន់។ ប៉ុន្តែខ្ញុំមិនបានដឹងស្ថានភាពនោះទេ"។ សំណួរថា៖ តើអង្គភាពយោធាណាមួយ ដែលរាយការណ៍ពីសភាពការណ៍នេះ? ចម្លើយ៖ យោធាតំបន់មានសិទ្ធិរាយការណ៍មកតែគណ:តំបន់ ចំណែកឯកងពលមជ្ឈិមត្រូវរាយការណ៍ទៅមជ្ឈិមផ្ទាល់"។ តើលោកអាចបញ្ជាក់ថា ចម្លើយដែលលោកបានផ្តល់ទៅសហចៅក្រមស៊ើបអង្កេតហ្នឹង តើជាការពិតដែរឬទេបាទ ដែលនិយាយពីសភាពការណ៍នៅក្រង់តេះ និងក្រុងតេះនោះបាទ?

[១០:១២:១៣]

**ឆ៖** បាទ បញ្ហាហ្នឹងគឺពិតប្រាកដ។ យោធាតំបន់រាយការណ៍មកតំបន់ ដូចកងពលគេមានសិទ្ធិរាយការណ៍ទៅខាងមជ្ឈិមហើយ។

**ស៖** ដូច្នេះតាមដែលខ្ញុំយល់ត្រឹមត្រូវ គឺលោកខ្លួនឯងមិនមានការពាក់ព័ន្ធផ្ទាល់អ្វីជាមួយនឹងបញ្ហាទាក់ទងទៅនឹងប្រជាជនយួន ប្រាំបួននាក់នេះទេ។ ហើយលោកបានរបាយការណ៍ហ្នឹងមកពីយោធាតំបន់

តើត្រូវដែរឬទេ?

**ឆ៖** បាទ ខ្ញុំចំពោះយួនប្រាំបួននាក់ហ្នឹង គឺដូចខ្ញុំជម្រាបខាងលើ ខ្ញុំអត់មានការពាក់ព័ន្ធ អាហ្នឹង ខ្ញុំបានជូនទៅសហចៅក្រមហើយ ខ្ញុំបដិសេធ ខ្ញុំអត់ដឹង។

[១០:១៣:២៣]

**ស៖** ថាតើអ្នកណាដែលស្ថិតនៅក្នុងយោធាតំបន់នោះ ដែលរាយការណ៍មកឲ្យលោកនោះ តើយោធាតំបន់ឈ្មោះ តាសុភា ហ្នឹងឬ?

**ឆ៖** បាទបញ្ហារាយការណ៍ហ្នឹង រាយការណ៍ពីសភាពការណ៍អីផ្សេងៗ ពីព្រោះបញ្ហារាយការណ៍ថា ចាប់ជនជាតិយួនប្រាំបួននាក់ហ្នឹង គឺខ្ញុំអត់យល់។ ដូចខ្ញុំជម្រាបលោកចៅក្រមហើយ ខ្ញុំបដិសេធតាំងពីលោកចៅក្រមគាត់សួរខ្ញុំបាទ។

**លោក ខេល លីសាក់៖**

ឥឡូវនេះ ខ្ញុំសូមលោកប្រធានដើម្បីអនុញ្ញាតបន្តទៅទូរលេខមួយទៀត។ ទូរលេខមួយនេះគឺជាឯកសារ E3/1078 ហើយវាជាទូរលេខចុះថ្ងៃទី០៩ មេសា ឆ្នាំ១៩៧៨ មកពី សារុន គឺ*តេឡេក្រាម* លេខ៤៦ គឺផ្ញើជូនទៅមន្ទីរ ៨៧០ ជាទីគោរព។ ហើយនិងសូមអនុញ្ញាតលោកប្រធាន ដើម្បីបង្ហាញឯកសារនេះលើអេក្រង់ និងកុំព្យូទ័រ ហើយនិងខ្ញុំអនុញ្ញាតសួរទៅសាក្សីផងដែរបាទ។

[១០:១៥:០៤]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោក សៅ សារុន ខ្ញុំនឹងសួរសំណួរលោកអំពីទូរលេខមួយទៀតដើម្បីឲ្យ ខ្ញុំអាចសួរបានខ្ញុំនឹងសួរលោក-- ដំបូងខ្ញុំនឹងអានជូនលោកស្តាប់អំពីខ្លឹមសារទូរលេខ ហើយខ្ញុំនឹងអាន-- នឹងសួរពេលក្រោយ។ នេះគឺជាទូរលេខ "គោរពជូនមន្ទីរ៨៧០ ដែលមានឈ្មោះលោកនៅខាងក្រោមថា សារុន" ហើយទូរលេខ លេខ៤៦ ហើយទូរលេខនោះ គឺនិយាយថា "នៅ-- បាទ នៅយប់ថ្ងៃទី០៧ ខែ៤ ឆ្នាំ៧៨ នេះមានភ្លើងឆេះកាណូតអស់ពីរគ្រឿង សាំង៥២ធុង និងម៉ាស៊ូត៨ធុង និងសម្ភារៈមួយចំនួនច្រើនឆេះអស់។

[១០:១៦:២០]

បញ្ហាភ្លើងឆេះនេះ គឺកាណូតខូចមកដល់កំពង់ចាម មិត្តយើងស្នើកាណូតគេទៅកំពង់ចាមដល់ព្រែកប្រសព្វមិត្តយើងម្ចាស់កាណូតនៅខាងកំពង់ចាម ឡើងទៅភូមិប្រជាជន ដើម្បីរកប្រជាជនចុះទៅក្រោមវិញ។ ហើយនៅកាណូតបីនាក់នោះ ម្នាក់ឈ្មោះ សាង យាមនៅលើក្បាលកាណូត ខ្លាចប្រជាជនចុះ កេះដែកកេះវាសឆេះ។ ពីរនាក់នៅក្នុងកាណូតឈ្មោះ អង់តាត់ ប៊ុនសា ហើយក៏ដុតចង្កៀង ហើយមិត្តអ្នកយាមនោះស្រែកប្រាប់ថា មិត្តឯងកុំដុតភ្លើងក្រែងវាឆេះសាំង មួយភ្លែតក៏ឃើញភ្លើងឆេះសាំងមែន។ ពួកវាកាន់កាប់-- ពួកវាកាន់ភ្លើងនោះក៏ត្រូវរបួសដែរ។" ដូច្នេះ ខ្ញុំសូមផ្អាកត្រឹមនេះ។ តើលោកនៅចាំហេតុការណ៍នេះទេ អំពីការឆេះគេដុតទូកនោះទេ គឺជាកម្មវត្ថុនៃរបាយការណ៍តាមទូរលេខរបស់លោក គឺលោករាយការណ៍ពីការដុតកាណូតមួយដែលមានសម្ភារៈហ្នឹងបាទ?

[១០:១៧:៤១]

**លោក សៅ សារុន៖**

**ឆ៖** បាទ អាហ្នឹងគឺ ខ្ញុំចាំ។ ឆេះអស់មែន អត់មានសល់ទេបាទ។ សូមអស់។

**ស៖** ខ្ញុំសូមអនុញ្ញាតអានបន្តទៀតនូវទូរលេខនេះរហូតដល់ផ្នែកផ្សេងទៀតហ្នឹង គឺ-- ហើយតទៅទៀតសូមដកស្រង់៖ "តាមការពិនិត្យរបស់តំបន់ និងរាយការណ៍របស់សមមិត្ត សាង គឺពួកពីរនាក់ដុត។ វិធានការរបស់តំបន់ ១. គឺត្រូវចាប់ពួកពីរនាក់ហ្នឹង។ ២. គឺត្រូវចាប់ អាលាន តាមការពិនិត្យគឺមានការចាត់តាំងពី អាលាន ទៅថ្ងៃទី០៩ នេះបានអនុវត្តការចាប់ពួកទាំងនេះ ដោយភាតរភាពបដិវត្តន៍យ៉ាងកក់ក្តៅបំផុត សារុន ថ្ងៃទី០៩ ខែ៤ ឆ្នាំ១៩៧៨"។ ទូរលេខនេះ ចង្អុលបង្ហាញថា តំបន់បានធ្វើការពិនិត្យនូវបញ្ហានេះ ថាតើអ្នកណាជាអ្នកធ្វើការពិនិត្យហេតុការណ៍នេះ តើលោកចាំទេ?

**ឆ៖** បាទ ខ្ញុំអត់ចាំទេ ពីព្រោះអ្នកនៅក្នុងកាណូតហ្នឹងគឺមិនបានចាប់ម្នាក់ទេបាទ។ សូមអស់។

[១០:១៩:២០]

**ស៖** នៅពេលដែលលោកបានសរសេរទូរលេខនេះ ហើយបញ្ជូនទៅមន្ទីរ៨៧០ ដែលបង្ហាញថាជាវិធានការរបស់តំបន់ គឺត្រូវចាប់បុរសពីរនាក់ហ្នឹង ហើយត្រូវចាប់អា លាន នោះតើលោកសុំមេដឹកនាំបក្សដើម្បីការសម្រេច ដើម្បីត្រូវធ្វើយ៉ាងណា ឬក៏គ្រាន់តែជូនដំណឹងពួកគាត់ថា លោកបានចាប់អ្នកទាំងពីរនាក់ហ្នឹងហើយ?

**ឆ៖** បាទ បញ្ហាហ្នឹងគឺមិនបានចាប់ទេ ពួកពីរនាក់ហ្នឹង គឺនៅរស់ទាំងអស់ដល់សព្វថ្ងៃនេះ។ មិនដែលបានចាប់អ្នកណាម្នាក់សោះ។ សូមអស់។

**សៈ** ហេតុអ្វីបានជាលោកបញ្ជូនទូរលេខនេះមកមន្ទីរ៨៧០? ហើយស្នើវិធានការទាក់ទងទៅនឹងការចាប់អ្នកទាំងពីរនាក់។ តើមូលហេតុដែលលោកបញ្ជូន-- មូលហេតុនៃការបញ្ជូនទូរលេខនេះមក។៨៧០ ហ្នឹង សំអាងលើមូលហេតុអ្វី បើដូច្នេះនោះ?

**ឆៈ** បាទ គឺមានការខូចខាតអីចឹងហើយ រាយការណ៍ ប៉ុន្តែមិនបានចាប់បាទ ពីព្រោះវាសម្ភារៈក៏អស់ បើចាប់មនុស្សទៀតកាន់តែខាតទៀតបាទ។

**សៈ** លោកសាក្សី តើអ្នកណាជាអ្នកមានអំណាចក្នុងការសម្រេចថា តើត្រូវចាប់អ្នកទាំងនេះថាតើលោក ឬក៏មនុស្សដែលនៅៗក្នុងមន្ទីរ៨៧០ ដែលលោកផ្ញើទូរលេខទៅឲ្យ?

**ឆៈ** បាទ អត់មានទេ ខ្ញុំអត់ដឹងថាពីណាមានអំណាចទេ ពីព្រោះជនទាំងអស់ហ្នឹងគឺមិនដែលបានចាប់ នៅរស់ដល់សព្វថ្ងៃនេះបាទ។

[១០:២១:៥៣]

**សៈ** តើលោកបានទទួលការឆ្លើយតបមកវិញទៅនឹងទូរលេខរបស់លោកទេ ពេលដែលលោកផ្ញើទៅភ្នំពេញហើយ?

**ឆៈ** បាទ បើផ្ញើហើយ គឺគេបានទទួលហើយ គេតបមកវិញបាទ។

**សៈ** តើអ្នកណាជាអ្នកឆ្លើយតបមកវិញនោះ?

**ឆៈ** បាទ លោក ប៉ុល ពត។

**សៈ** តើគាត់បានផ្តល់ការណែនាំដល់លោកថា តើត្រូវធ្វើដូចម្តេចទេ ទាក់ទងទៅនឹងមនុស្សពីរនាក់នេះនៅក្នុងដីកាឆ្លើយតបមកលោកវិញនោះ?

**ឆៈ** បញ្ហាហ្នឹងដូចមិនឃើញមានសេចក្តីណែនាំអីទេ ពីព្រោះមនុស្សដែលឆេះ-- ភ្លើងឆេះកាណូតហ្នឹងមិនដែលបានចាប់ចងគេ។ អីចឹងសម្ភារៈវាខូចខាតហើយក៏យើងមិនដែលណែនាំថាចាប់មិនដែលណែនាំចងទេ។ បាទ អស់។

[១០:២៣:២៣]

**លោក ឌេល លីសាក់៖**

លោកប្រធាន សូមអនុញ្ញាត ហើយខ្ញុំសូមអានសេចក្តីដកស្រង់អំពីកំណត់ហេតុស្តាប់ចម្លើយទីពីររបស់សាក្សីគឺ E3/388 ខ្មែរ ERN 00345914, អង់គ្លេស ERN 00350265, បារាំង ERN 0036 1765។ បាទ សូមអនុញ្ញាតតុលាការដើម្បីបង្ហាញលើអេក្រង់ផងដែរបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** នៅក្នុងចម្លើយរបស់លោកជូនទៅសហចៅក្រមស៊ើបអង្កេតនោះ លោកសាក្សី លោកបានឆ្លើយទាក់ទងទៅនឹងទូរលេខនេះ លោកឆ្លើយថា លោកបានឆ្លើយ សូមដកស្រង់៖ "ប៉ុល ពត បានណែនាំថាមិនឲ្យចាប់អ្នកទាំងនេះទេ។ ហើយខ្ញុំខ្លួនឯងទទួលទូរលេខពី ប៉ុល ពត ផ្ទាល់។ ប៉ុល ពត ណែនាំឲ្យខ្ញុំប្រាប់អ្នកទាំងបីនាក់នេះថា កុំភ័យខ្លាច"។ ចប់សេចក្តីដកស្រង់។ តើនេះជាចម្លើយត្រឹមត្រូវ ហើយនិងដោយស្មោះត្រង់របស់លោកទេ លោកសាក្សី?

**លោក សៅ សារុន៖**

**ឆ៖** បាទ អាហ្នឹងជាចម្លើយហ្នឹង ជាការស្មោះត្រង់។

[១០:២៥:០៤]

**ស៖** តើត្រូវដែរឬទេ ជាការឆ្លើយតបទៅនឹងទូរលេខរបស់លោក គឺលោកទទួលការណែនាំពី ប៉ុល ពត ទាក់ទងថា តើត្រូវធ្វើដូចម្តេចចំពោះមនុស្សទាំងប៉ុន្មាននាក់ហ្នឹង? តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ត្រឹមត្រូវ។ បាទ ត្រឹមត្រូវហើយ ណែនាំ ពីព្រោះថាមិនឲ្យចាប់ មិនឲ្យចង គឺឲ្យណែនាំគេ ឲ្យគេរស់នៅដោយសុវត្ថិភាពបាទ។

**ស៖** លោក សៅ សារុន យើងមានបញ្ជីរាយឈ្មោះអ្នកទោស ស-២១ គឺមនុស្សមកពីតំបន់ ១០៥។ ឯកសារ D175/3.15 ដែលនិយាយថា កង លើន ជាជំនួយការរបស់លេខាពាណិជ្ជកម្ម ហើយគាត់ក៏នៅ-- បញ្ជូនមកដល់ថ្ងៃទី១០ មិថុនា ឆ្នាំ១៩៧៨ ហើយក៏មានសេចក្តីចម្លើយរបស់បងរបស់ កង លើន ដែលបញ្ជាក់ថា គាត់បានធ្វើការនៅក្នុងមន្ទីរពាណិជ្ជកម្មជាមួយ ជួន ហើយគេចាប់ខ្លួនគាត់ ក្រោយពីមានហេតុការណ៍ឆេះកាណូតនោះ ហើយក្រោយពីមានទូរលេខមកមន្ទីរ៨៧០។ តើត្រូវដែរឬទេ គឺថាចងចាំរបស់លោកមិនត្រឹមត្រូវ ដែលតាមការពិតនោះគឺការឆ្លើយតបទៅនឹងទូរលេខនោះ អង្គការបានសម្រេចចាប់ លើន ហើយបញ្ជូន-- បានចាប់ លាន ហើយបញ្ជូនមក ស-២១? តើអាចថាការចងចាំរបស់លោកហ្នឹងខុសដែរឬទេបាទ?

[១០:២៧:១៤]

**ឆ៖** បាទ គឺអត់មានទេ កង លីន, កង លាន គឺនៅទាំងអស់។ នៅភូមិ នៅរស់ នៅទល់សព្វថ្ងៃ បាទ។ ខ្ញុំអត់ដឹងរឿងហ្នឹង។

**លោក ខេល លីសាក់៖**

ឥឡូវនេះ ខ្ញុំចង់ចូលទៅដល់ទូរលេខមួយទៀត ដែល E3/156 គឺជាទូរលេខដែលនិយាយអំពី-- ចុះថ្ងៃទី២៣ មេសា ឆ្នាំ១៩៧៨ ផ្ញើមកពី សារុន ជូនបងជាទីគោរព។ ហើយសូមអនុញ្ញាតតុលាការដើម្បី បង្ហាញឯកសារនេះលើអេក្រង់ផង គឺឯកសារ E3/165 ហើយនិង ខ្ញុំសូមអនុញ្ញាតអានសេចក្ដីដកស្រង់ ហ្នឹងជូនលោកសាក្សីស្ដាប់ផងដែរបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

[១០:២៨:៥៦]

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោក សៅ សារុន នេះជាទូរលេខដែលមានចុះថ្ងៃទី២៣ មេសា ឆ្នាំ១៩៧៨ មានកថាខណ្ឌចំនួនបី។ ខ្ញុំផ្ដោតសំណួររបស់ខ្ញុំទៅលើកថាខណ្ឌពីរខាងលើនៅក្នុងទូរលេខនេះ ដែលថាទូរលេខ លេខ៥៤។ នៅក្នុងកថាខណ្ឌទីពីរ ខ្ញុំអានជូនលោកស្ដាប់ មុននឹងខ្ញុំសួរសំណួរទៅលោកមួយចំនួននោះ។ ដកស្រង់--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណ លោកប្រធាន សូមជម្រាបសួរផងដែរ។ ប្រហែលជាយើងអាចសួរសំណួរមុន ហើយសូមឱ្យសាក្សីបញ្ជាក់យថាភាពមុននឹងពេលដកស្រង់-- មុននឹងអានសេចក្ដីដកស្រង់ទូរលេខនេះ លោកប្រធាន។

**លោក ខេល លីសាក់៖**

លោកប្រធាន ប្រហែលជាលោក ផេសមិន មិនបាននៅទីនេះទេ ហើយលោកមិនបានដឹងថាៗ សាក្សីមិនអាចអានបានទេ គាត់ភ្នែកអន់ ងងឹត ហើយគាត់នៅពេលសម្ភាស ក្នុងពេលសម្ភាសនោះ គាត់ អាចកំណត់បាន ដូច្នេះហើយយើងមិនអាចឱ្យគាត់មើលបញ្ជាក់ទេ។

[១០:៣០:២៨]

**លោក ម៉ែខល ផេសមិន៖**

សូមអភ័យទោសលោកប្រធាន ខ្ញុំមិនបានដឹងពីបញ្ហានេះ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាបន្តកិច្ចការរបស់ខ្លួន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** កថាខណ្ឌទីពីរនៃទូរលេខនេះ ដែលលោកបានបញ្ជូនទៅថ្នាក់លើនៅពេលនោះ គឺសូមដកស្រង់៖ "តាមកាលវិភាគ គឺតាម-- គឺជាមួយខាងកងពលឯកភាពគ្នា ហើយចង់បើកការ-- បើកប្រដាប់អាវុធឱ្យកងតំបន់វាយ បើបងមានមតិយ៉ាងម៉េច សូមជួយយោបល់ផង ពីព្រោះកាលមុននោះ វាមានសភាពការណ៍ស្មុគស្មាញនៅក្នុងតំបន់ក៏ដកអាវុធទាំងអស់។ ប្រសិនបើបងមានមតិយ៉ាងណាសូមរាយ-ការណ៍ជាប្រញាប់ផង"។ តើលោកបានស្នើសុំយោបល់ថា តើត្រូវផ្តល់អាវុធទៅឱ្យមនុស្សមួយចំនួននៅក្នុងតំបន់ដែរឬទេ?

**លោក សៅ សារុន៖**

**ឆ៖** បាទ អាហ្នឹងមែន។ កាលមុនគេដកអស់ ដល់មានសភាពអ៊ីចឹង គេសុំប្រដាប់អាវុធហ្នឹង គឺមែនអាហ្នឹង។ សូមអស់។

[១០:៣២:០៥]

**ប្រធានអង្គជំនុំ៖**

អរគុណលោកតំណាងសហព្រះរាជអាជ្ញា។ អរគុណសាក្សី។ ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទីចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកដល់សាក្សី និងទីប្រឹក្សាសាក្សីនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងឱ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មវិញនៅវេលាម៉ោងដប់មួយខ្វះដប់នាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣២ នាទី ដល់ម៉ោង ១០:៥១ នាទី)*

[១០:៥១:៥៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោក សារុន យើងបានពិភាក្សាគ្នាអំពីទូរលេខដែលបានបញ្ជូននៅថ្ងៃ២៣ មេសា ឆ្នាំ ១៩៧៨ ដែលនៅក្នុងទូរលេខនេះស្នើសុំនូវមតិយោបល់ "ជូនចំពោះបង" ដែលថាសំណើសុំហ្នឹង គឺស្នើសុំបំពាក់អាវុធទៅដល់ទាហាននោះ ថាតើលោកបញ្ជូនទូរលេខហ្នឹង ដើម្បីសុំយោបល់ពីបងណា? តើបងមួយណាដែលលោកស្នើសុំយោបល់នោះ?

**លោក សៅ សារុន៖**

**ឆ៖** បាទ សុំយោបល់ហ្នឹង គឺសុំជាមួយលោក ប៉ុល ពត បាទ។

[១០:៥៣:២៤]

**ស៖** ហើយរាយការណ៍នូវព័ត៌មានជូនទៅខាង ប៉ុល ពត គឺលោកបាននិយាយថា គឺមាននូវបញ្ហាស្មុគស្មាញជាច្រើននៅក្នុងផ្នែកតំបន់ហ្នឹង។ ដូច្នេះ ហើយទើបគេដកអាវុធចេញ ដូច្នេះតើលោកអាចពន្យល់បានទេ ថាតើសមាសភាពស្មុគស្មាញហ្នឹង គឺសមាសភាពស្មុគស្មាញអីដែលនាំទៅដល់ការដកអាវុធទាំងអស់ចេញពីក្នុងតំបន់នោះ?

**ឆ៖** បាទ អ៊ីចេះ ខ្ញុំសូមជម្រាបអស់លោក ពីព្រោះធម្មតាទាហានចូលក្នុងបន្ទាយហើយ គឺអត់ឲ្យមានអាវុធទេបាទ ដកទាំងអស់ ដូចយើងសព្វថ្ងៃហ្នឹងដែរ មិនឲ្យកាន់ច្រេងងច្រងាងតាមភូមិទេ បាទ។

**ស៖** ថាតើលោកនិយាយសំដៅលើអ្នកណា ទៅលើអ្នកណានៅពេលដែលលោកនិយាយថា គឺកាលពីមុនមកហ្នឹង គឺថាវាមានសភាពការណ៍ស្មុគស្មាញ។ តើលោកចង់សំដៅទៅលើអ្នកណាដែលនៅពេលដែលនិយាយថា វាមានសភាពការណ៍ស្មុគស្មាញនៅក្នុងតំបន់នោះ?

**ឆ៖** គឺបញ្ហាហ្នឹង គឺខ្ញុំអត់សូវយល់ទេ ដូចវាស្មុគស្មាញ។ វាមានបញ្ហាអី ខ្ញុំអត់យល់។

[១០:៥៥:១១]

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំស្នើសុំអនុញ្ញាតអានទូវកិច្ចសម្ភាសន៍លើកទី៣ ជាមួយសហព្រះរាជអាជ្ញា គឺ E3/384 ហើយខ្ញុំចង់ដកស្រង់នូវ ERN ខ្មែរដែលមានលេខ 00345905 ហើយភាសាអង់គ្លេស គឺមានលេខ 00348374 ហើយភាសាបារាំងគឺមានលេខ 00354238 ហើយខ្ញុំសូមអនុញ្ញាតដាក់បង្ហាញនៅលើអេក្រង់ទូរទស្សន៍ និងកុំព្យូទ័រ។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី នៅពេលដែលគេសួរលោកអំពីទូរលេខមួយនេះ គឺនៅពេលដែលសហចៅក្រមស៊ើបអង្កេតបានសួរលោកអំពីផ្នែកនៅក្នុងទូរលេខមួយនេះ លោកបាននិយាយដូចតទៅ។ ខ្ញុំសូមដកស្រង់៖ "នៅចុងឆ្នាំ១៩៧៧ នៅពេលដែលខ្ញុំធ្វើការនៅស្រុកពេជ្រចិន្តា ខ្ញុំបានឮថា មានបុគ្គលិក ក-១៦ នាំគ្នារត់។ មុនការរត់នេះ មានការដកអាវុធខ្លះៗ ដោយសារស្រុកសន្តិភាព ប៉ុន្តែក្រោយការរត់នេះ អាវុធត្រូវបានដកទាំងស្រុង"។ ខ្ញុំសូមបញ្ចប់។

តើលោកអាចបញ្ជាក់បានដែរឬទេ ថាចម្លើយហ្នឹង គឺមានភាពត្រឹមត្រូវ និងស្មោះត្រង់។ តើលោកអាចបញ្ជាក់បានទេ?

[១០:៥៦:៥៤]

**លោក សៅ សារុន៖**

**ឆ៖** បាទ គឺបញ្ហាហ្នឹងគឺជាក់ស្តែង ដូចខ្ញុំបានជម្រាបលោកសហចៅក្រមរួចស្រេចហើយបាទ។

**ស៖** តើវាត្រឹមត្រូវដែរឬទេ ដែលនិយាយថាសមាសភាពស្មុគស្មាញនោះ គឺសមាសភាពស្មុគស្មាញនៅក្នុងតំបន់ ហើយនាំដល់ការដកអាវុធហ្នឹង គឺពាក់ព័ន្ធទៅនឹងអ្វី ដែលយើងបាននិយាយពីម្សិលមិញហ្នឹង ដែលថាមានបុគ្គលិកមន្ទីរក-១៦ នាំគ្នារត់ទៅវៀតណាម។ តើវាជាការត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ គឺត្រឹមត្រូវ រត់មែន ដូចខ្ញុំជម្រាបជូនលោកសហចៅក្រមរួចស្រេចហើយបាទ។

**ស៖** នៅពេលដែលលោកផ្តល់ចម្លើយថា បន្ទាប់ពីមានការរត់ហ្នឹង គេដកយកអាវុធចេញទាំងអស់ ថាតើវាមានតែនៅក្នុងស្រុកតែមួយ ឬមួយក៏យ៉ាងម៉េចដែរ? តើលោកអាចបញ្ជាក់ឲ្យបានច្បាស់ទេ ពីចំណុចទាំងអស់នេះ?

[១០:៥៨:២២]

**ឆ៖** បាទ ខ្ញុំមិនបានបញ្ជាក់ទាំងអស់ទេ។ អាច ខ្ញុំយល់តែប៉ុណ្ណឹងបាទ។

**ស៖** សូមអរគុណលោកសាក្សី។ តើលោកអាចប្រាប់បានទេ ថាតើលោកមានបានទទួលចម្លើយតបពី ប៉ុល ពត ទេ ទាក់ទងទៅនឹងបញ្ហាដែលលោកបានផ្ញើទៅនេះ?

**ឆ៖** ហើយសំណួរហ្នឹង គឺខ្ញុំមិនសូវយល់ សូមឲ្យអានម្តងទៀតបាទ។

**ស៖** ខ្ញុំនឹងសួរលោកមួយសាទៀត។ តើលោកចាំដែរឬទេ ថាតើប៉ុល ពត មានឆ្លើយតបទៅនឹងសំណួរពាក់ព័ន្ធទៅនឹងការបំពាក់អាវុធដល់ទាហាននៅក្នុងតំបន់។ តើ ប៉ុល ពត គាត់មានឆ្លើយតបមកវិញទេ ទៅលើបញ្ហានេះ?

**ឆ៖** បាទ បញ្ហាហ្នឹង គាត់បានតបមែន បាទ។

**ស៖** តើគាត់ឆ្លើយតបមកវិញ ថាយ៉ាងម៉េចដែរ?

**ឆ៖** បាទ គាត់ថា បំពាក់ចុះ តែប៉ុណ្ណឹងបាទ។

[១១:០០:០០]

**ស៖** តើគាត់មានប្រាប់លោកអ្វីបន្ថែមទៀត អំពីការត្រួតពិនិត្យទៅលើទាហានដែលត្រូវបំពាក់អាវុធហ្នឹងទេ? តើគាត់មានប្រាប់លោកអីបន្ថែមទៀតទេ?

**ឆ៖** បាទ អត់មានបញ្ជាក់អីទៀតទេបាទ។ សូមអស់។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមដកស្រង់នូវកិច្ចសម្ភាសន៍ទីបី ជាមួយនឹងសហព្រះរាជអាជ្ញា គឺមានលេខ E3/384 ហើយខ្ញុំសូមដកស្រង់នូវ ERN ភាសាខ្មែរ ដែលមានលេខ 00345905, ភាសាអង់គ្លេស គឺមានលេខ 00348374, 00354238។ ខ្ញុំសូមអនុញ្ញាតដាក់បង្ហាញនៅលើអេក្រង់ទូរទស្សន៍ និងអេក្រង់កុំព្យូទ័រ។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

[១១:០១:២៥]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** នៅពេលដែលគេចោទសួរលោកអំពីកថាខណ្ឌពីរ នៅក្នុងទូរលេខមួយនេះ នេះគឺជាសក្ខីកម្មដែលលោកបានផ្តល់ឲ្យ។ ក្នុងសំណួរគេថា៖ “ចុះក្នុងចំណុចទីពីរនៃទូរលេខ ៥៤ ដូចម្តេចដែរ?” ហើយលោកឆ្លើយថា៖ “ក្នុងការណែនាំឆ្លើយតបរបស់ ប៉ុល ពត គឺក្រោយពីបំពាក់អាវុធហើយ ត្រូវតាមដាន។ ហើយបើជួបប្រទះវៀតណាម គឺបើកការប្រយុទ្ធតែម្តង”។ តើនេះគឺជាចម្លើយដែលត្រឹមត្រូវដែរឬទេលោកសាក្សី?

**លោក សៅ សារុន៖**

**ឆ៖** បាទ គឺត្រឹមត្រូវ។ បើប៉ះគឺប្រយុទ្ធគ្នា។

**ស៖** តើ ប៉ុល ពត បញ្ជូននូវសេចក្តីណែនាំមក-- សេចក្តីណែនាំនេះមកលោកតាមរបៀបណាដែរ?

**ឆ៖** បាទបញ្ហាហ្នឹងខ្ញុំភ្លេចអស់ហើយ វាយូរហើយ ម្យ៉ាងឈឺខ្លួនទៀត វាអស់ការចងចាំហើយ។

**ស៖** ឥឡូវនេះខ្ញុំនឹងលើកនូវកថាខណ្ឌផ្សេងមួយទៀត ប្រសិនបើលោកមានអារម្មណ៍ថា មានសុខភាពមិនល្អ មិនអាចផ្តល់សក្ខីកម្មបាន សូមលោកជម្រាបទៅដល់លោកប្រធានទៅ ដើម្បីឲ្យលោកប្រធានធ្វើការសម្រេចអំពីស្ថានភាព ឬមួយក៏លោកអាចជម្រាបទៅដល់មេធាវីរបស់លោក តើលោកអាចមាន-- តើលោកមានអារម្មណ៍ មានបញ្ហាយ៉ាងម៉េចដែរជាមួយសុខភាពលោកឥឡូវនេះ?

[១១:០៣:៣៥]

**ឆ៖** បាទ អឺចឹងហើយ ពីព្រោះខ្ញុំតាំងពីឈឺមក ខ្ញុំបាត់ការចងចាំគឺវាយការណ៍ដូចលោកសហចៅក្រមបានគាត់សាកសួរហើយ អាហ្នឹងបានខ្ញុំថា ខ្ញុំ-- ដល់លើកសំណួរមក ខ្ញុំវាបាត់ការចងចាំបាទ។ ម្តុំៗណ៎ា ពេលណាខ្ញុំនឹកឃើញ នឹកឃើញ ពីព្រោះវាឈឺហ្នឹងវាឈឺខ្លាំងមែនបាទ។

**ស៖** លោកសាក្សី ឥឡូវនេះខ្ញុំនឹងបន្តទៅចំណុចចុងក្រោយនៃទូរលេខរបស់លោក ហើយខ្ញុំសូមអាននូវផ្នែក-- នៅកថាខណ្ឌទីមួយនៃផ្នែកទីបីរបស់ទូរលេខលោក។ ខ្ញុំសូមអានដូចតទៅ កថាខណ្ឌទីបី៖ “បញ្ហាសកម្មភាពផ្ទៃក្នុងបក្ស គឺមានសមមិត្ត សុទ ប្រធានរោងចក្រជួសជុល បានប៉ះពាល់សីលធម៌

ជាមួយនារី។ ឥឡូវនេះគឺបានចាប់ហើយ គឺចាប់ទាំងបុរស ចាប់ទាំងនារី។ មិត្តនេះកាលមុនមានជាប់ចម្លើយពួកអាក្បត់ អាជួន។ ក្នុងតំបន់ពេលនោះនៅតាមដានសកម្មភាពវាថែមទៀត តែឥឡូវវាមានប៉ះពាល់សីលធម៌យ៉ាងមនេះ បានចាប់ឃុំឃាំងទុកហើយ"។ ខ្ញុំសូមបញ្ចប់ត្រឹមចំណុចនេះ ហើយខ្ញុំសូមសួរលោកថា ជាដំបូងតើលោកមានចាំអំពីហេតុការណ៍ពាក់ព័ន្ធទៅនឹងសមមិត្ត សុទ ដែលប៉ះពាល់សីលធម៌ជាមួយសមមិត្តនារីផ្សេងទៀតដែរឬទេ? តើលោកមានចាំអំពីហេតុការណ៍នេះទេ?

**ឆ៖** បាទ គឺចាំ។ បានឃាត់ខ្លួនហើយ ក៏សាកសួរគាត់ វាអត់មានការពាក់ព័ន្ធអ្វីទាំងអស់ គ្រាន់តែថា ខុសខាងសីលធម៌ទៅ ក៏បានអប់រំណែនាំគាត់ លែងគាត់វិញ។

[១១:០៦:១៨]

**ស៖** ឥឡូវនេះ ខ្ញុំសូមចាប់ផ្តើមនិយាយយោងទៅលើឯកសារមួយ នៅក្នុងកថាខណ្ឌ ដែលថា សមមិត្ត សុទ ត្រូវបានគេឆ្លើយដាក់នៅក្នុងចម្លើយសារភាពរបស់សមមិត្ត ជួន។ តើ ជួន ហ្នឹងគឺជានរណាដែរ? តើជួនហ្នឹង គឺជាបុគ្គលដែលយើងបាននិយាយតាំងពីដើម តាំងពីព្រឹកមក? តើ ជួន ហ្នឹងគឺ ជួន តែមួយដែលយើងនិយាយពីដើមមក ដែលជាប្រធានមន្ទីរពាណិជ្ជកម្ម ដែលត្រូវបានគេចាប់ខ្លួន។ តើ ជួន ហ្នឹងជាមនុស្សតែមួយមែនទេ?

**ឆ៖** បាទ មនុស្សតែមួយ។

**ស៖** នៅក្នុងទូរលេខរបស់លោក លោកបានបញ្ជាក់ថា សមមិត្ត សុទ ត្រូវបានគេឆ្លើយដាក់ដោយសមមិត្ត ជួន។ តើលោកធ្វើដូចម្តេចបានដឹងថា ជួន ឆ្លើយដាក់ សុទ នៅក្នុងចម្លើយសារភាពរបស់ ជួន នោះ។ តើលោកធ្វើយ៉ាងម៉េចបានដឹង?

**ឆ៖** បាទ ពេលឃាត់ សុទ ហ្នឹង គឺបានសាកសួរគាត់ គាត់ថា ខ្ញុំវាជាប់ចម្លើយគេ។ ដល់សួរពិនិត្យទៅវាអត់មានរឿងរ៉ាវអីនឹងជាប់ជំពាក់ជំពិនជាមួយ ជួន ទេ វាជំពាក់ជំពិនតែរឿងនារី។ អ៊ីចឹងបាន យើងខ្ញុំ ក៏បានលែងគាត់ ឲ្យគាត់រស់នៅដោយសុវត្ថិភាព។

**ស៖** ថាតើហេតុអ្វីបានជានៅក្នុងទូរលេខរបស់លោកហ្នឹង លោកហៅ ជួន ហ្នឹងថា ពួកអាក្បត់ តើហេតុអ្វីបានលោកហៅថា "អាក្បត់" អ៊ីចឹង?

**ឆ៖** ព្រោះអីពេលហ្នឹងគឺខ្ញុំថា អត់ដែលហៅអ៊ីចឹងទេ។ ខ្ញុំមិនដែលថា និយាយថា ពួកអាក្បត់ អ៊ីចេះអ៊ីចុះ គឺមិនដែលនិយាយទេ បាទ។

[១១:០៨:៤៤]

**សៈ** លោកសាក្សី មុនពេលដែលមានហេតុការណ៍នេះកើតឡើង គឺហេតុការណ៍សីលធម៍ សមមិត្ត សុទ និងសមមិត្តនារីមួយទៀតហ្នឹង តើលោកធ្លាប់ឃើញចម្លើយសារភាពរបស់ ជួន ឬមួយក៏លោកបានទទួលព័ត៌មានពីការឆ្លើយដាក់ នៅក្នុងចម្លើយសារភាពរបស់ ជួន។ តើលោកធ្លាប់ដែលឃើញដែរឬទេ?

**ឆៈ** បាទ ខ្ញុំអត់ដែលឃើញទេ។

**លោក ឌេល លីសាក់៖**

លោកប្រធាន។ ឥឡូវនេះ ខ្ញុំសូមដកស្រង់ នូវកិច្ចសម្ភាសលើកទីបីរបស់សាក្សី ជាមួយសហចៅក្រមស៊ើបអង្កេត គឺឯកសារដែលមាន លេខ E3/384 ដែលមាន ERN ខ្មែរ មានលេខ 00345903, ភាសាអង់គ្លេសគឺមាន 00348372 រហូតដល់ 373, ហើយភាសាបារាំងគឺមាន 00354236។ ហើយខ្ញុំសូមអនុញ្ញាត ដាក់បង្ហាញនៅលើអេក្រង់ទូរទស្សន៍ និងកុំព្យូទ័រ។ សូមអនុញ្ញាត។

[១១:១០:០៨]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក ឌេល លីសាក់៖**

**សៈ** លោក សារុន នៅក្នុងចម្លើយដែលលោកផ្តល់ទៅឲ្យសហចៅក្រមស៊ើបអង្កេតនុ៎ង គឺលោកបាននិយាយដូចតទៅនេះ៖ “សំណួរ៖ តើលោកធ្លាប់អានចម្លើយសារភាពរបស់ ជួន ទេ? ហើយលោកឆ្លើយថា៖ មិនដែលអានទេ។ សំណួរ៖ បើមិនដែលអាន តើដឹងដោយរបៀបណា? ចម្លើយ៖ ដឹងពី ប៉ុល ពត ទូរលេខមកខ្ញុំផ្ទាល់ថា សុទ ហ្នឹងជាប់នៅក្នុងចម្លើយរបស់ ជួន។ ពេលនោះ គឺប្រហែលជាដប់ថ្ងៃមុនខ្ញុំឃុំខ្លួន សុទ”។ តើនេះជាចម្លើយដែលត្រឹមត្រូវដែរឬទេ លោកសាក្សី?

[១១:១០:១៥]

**លោក សៅ សារុន៖**

**ឆៈ** បាទ គឺចម្លើយហ្នឹងគឺជាត្រឹមត្រូវ។ បាទអស់។

**សៈ** តើត្រឹមត្រូវដែរឬទេ ដែលថាលោកបានទទួលទូរសារផ្ទាល់ពី ប៉ុល ពត ដែលបង្ហាញថា សុទ ជាប់ក្នុងចម្លើយរបស់ ជួន។ តើនេះជាការត្រឹមត្រូវដែរឬទេ?

**ឆៈ** បាទ ត្រឹមត្រូវ។

**សៈ** លោកសាក្សី តើមានវិធានការ ឬក៏សកម្មភាពអ្វីដែលលោកត្រូវធ្វើនៅពេលដែលខាងមជ្ឈិមហ្នឹងបានបញ្ជូនព័ត៌មានមកលោកអំពី-- ព័ត៌មានទាក់ទងទៅនឹងជនក្បត់ តើគេរំពឹងថាលោកគួរធ្វើសកម្មភាពអ្វីមួយដែរទេ?

**ផៈ** អត់ទេ មិនដែលធ្វើសកម្មភាពអ្វីទាំងអស់បាទ។

**សៈ** ថាតើនៅក្នុងទូរលេខរបស់លោក លោកសាក្សីគឺថា បន្ទាប់ពីដឹងថា សមមិត្ត សុទ ត្រូវបានគេឆ្លើយដាក់ក្នុងចម្លើយសារភាពរបស់ ជួន ខាងតំបន់បានតាមដានសកម្មភាពរបស់គាត់។ ថាតើសកម្មភាពដែលតំបន់ធ្វើក្នុងការតាមដានសកម្មភាព សុទ ហ្នឹង ថាតើតំបន់ហ្នឹងធ្វើសកម្មភាពតាមដានបែបណា ឬក៏សកម្មភាពអ្វី?

[១១:១៣:០៩]

**ផៈ** បាទ អត់មានថាតាមដានអីទេ គឺគេគ្រាន់តែគេរាយការណ៍ទៅ ក៏ហៅគាត់មក សួរគាត់ពីរឿងការពាក់ព័ន្ធអីខ្លាំងទេ ខុសតែសីលធម៌តែមួយមុខហ្នឹង ក៏លែងគាត់ឲ្យរស់នៅដោយសុវត្ថិភាព អាហ្នឹងបាទ។

**សៈ** ថាតើលោកដឹងដោយរបៀបណា ដែលថាសមមិត្ត សុទ ហ្នឹងមានប៉ះពាល់សីលធម៌ តើលោកដឹងថាតើសមមិត្ត សុទ ហ្នឹងប៉ះពាល់សីលធម៌ជាមួយនឹងនារីហ្នឹងដោយរបៀបណា?

**ផៈ** បាទ អាហ្នឹងតាមក្រុមគេរាយការណ៍បានដឹងបាទ បើមិនអ៊ីចឹងក៏មិនដឹងដែរ បើគេមិនរាយការណ៍ក៏អត់ដឹង។ ដឹងហើយក៏ឃើញថា ដូចខ្ញុំជម្រាបខាងលើ អប់រំគាត់ មានការអ៊ីចឹង គឺលែងគាត់វិញទៅ។

**សៈ** បន្ទាប់ពីគេជម្រាបមកលោកអំពីសមមិត្ត សុទ ហើយនិងនារីហ្នឹងត្រូវបានគេឃុំខ្លួននោះ តើលោកមានចោទសួរទៅលើបញ្ហានេះទេ? តើលោកសួរទៅលើបញ្ហាហ្នឹងទេ?

[១១:១៤:៤៥]

**ផៈ** បាទ អត់មានសួរទេ។ អត់ដែលសួរអី បញ្ហាអីក្រៅពីបញ្ហាហ្នឹងទេបាទ។

**សៈ** ឥឡូវនេះដើម្បីបញ្ជាក់ឲ្យច្បាស់ តើលោកចោទសួរទៅលើបញ្ហាមួយហ្នឹង បញ្ហាអ្វី? បញ្ហាមួយហ្នឹង?

**ផៈ** ហ្នឹងហើយ ដូចខ្ញុំជម្រាបហ្នឹងហើយ មិនដែលសួរអារឿងបញ្ហាអីទាំងអស់ ចំពោះការងាររឿង សុទ ហ្នឹង គេសួរថា ដឹងតែថាគាត់ប៉ះពាល់សីសធម៌ មានចម្លើយអី សួរទៅវាអត់មាន។ ដល់អត់

មានទៅក៏លែងគាត់ពីរឿងសីលធម៌ហ្នឹង វាឥតមានជាបញ្ហារឿងអីធំដុំទេ ធម្មតាជាធម្មជាតិរបស់មនុស្សតែប៉ុណ្ណឹងទេបាទ។

**សៈ** ថាតើ-- ថាតើការប៉ះពាល់សីលធម៌ហ្នឹង តើប៉ះពាល់សីលធម៌បែបណា ដែលគេចោទប្រកាន់ទៅលើគាត់ហ្នឹង?

**ឆៈ** អត់ដឹងដែរ បញ្ហាហ្នឹង អត់ដឹងថារឿងហ្នឹងគេទាក់ទងរបៀបម៉េចៗ? អត់ដឹងទេ សូមជម្រាបដោយត្រង់អ៊ីចឹង។

[១១:១៦:១៨]

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតអានឆ្លើយសារភាពទីបី ដែលមានលេខ E3/384 ដែលខ្មែរ ERN គឺលេខ 00345904, ភាសាអង់គ្លេសគឺ 00348373 និងភាសាបារាំងគឺមានលេខ 00354237។ ហើយខ្ញុំសូមអនុញ្ញាតដាក់បង្ហាញនៅលើអេក្រង់ទូរទស្សន៍ និងកុំព្យូទ័រ។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក ឌេល លីសាក់៖**

**សៈ** សំណួរចម្លើយដែលខ្ញុំចង់សួរលោកគឺនៅលើទំព័រមួយនេះ គឺខ្ញុំសូមដកស្រង់៖ "សំណួរ៖ ហេតុអ្វីបានជា សុទ មានប៉ះពាល់ជាមួយនារីហ្នឹង ហើយត្រូវបានគេចាប់ខ្លួន? ព្រោះថា សុទ-- ចម្លើយ៖ គឺថា ព្រោះថា សុទ្ធ មានប្រពន្ធរួចទៅហើយ"។ ថាតើអំពើ ថាតើការខុសសីលធម៌ហ្នឹងគឺជាការចោទប្រកាន់ ដែលថាពួកគាត់មានការទំនាក់ទំនងផ្លូវភេទ។ តើត្រឹមត្រូវដែរឬទេ?

**លោក សៅ សារុន៖**

**ឆៈ** បាទ អាហ្នឹងគឺត្រឹមត្រូវហើយ។ គាត់មានប្រពន្ធមែនបាទ ប៉ុន្តែវាប៉ះពាល់ស្រលាញ់គេទៀត អាហ្នឹងជា-- ។ ខ្ញុំសូមជម្រាបអស់ប៉ុណ្ណឹង។

**សៈ** ថាតើអ្នកណាជាអ្នកណែនាំលោកដែលថាការមានទំនាក់ទំនងផ្លូវភេទហ្នឹង គឺជាការប៉ះពាល់សីលធម៌ ហើយត្រូវចាប់ខ្លួននោះ? ថាតើអ្នកណាជាប្រាប់លោកអំពីបញ្ហានេះ?

**ឆៈ** ទេបញ្ហាហ្នឹងខ្ញុំដូចភ្លេចអស់ហើយ វាយូរហើយ។ គ្រាន់តែថាដឹងថាគាត់ប៉ះពាល់សីលធម៌ដឹងប៉ុណ្ណឹងទេបាទ។

**ស៖** ឥឡូវលោកនិយាយថា សមមិត្ត សុទ ហើយនិងសមមិត្តនារីហ្នឹង ដែលគេចោទប្រកាន់អំពីអំពើប៉ះពាល់សីលធម៌ហ្នឹង ថាតើអ្នកណាជាអ្នកសួរចម្លើយពួកគាត់ទាំងពីរនាក់នោះ?

**ឆ៖** បាទ អាហ្នឹងជាក្រុមពួករបស់គេសួរ បាទ។

[១១:១៩:១២]

**ស៖** ថាតើក្រុមពួកគេហ្នឹង អ្នកណាដែរ?

**ឆ៖** ខ្ញុំអត់ស្គាល់ទេ ស្គាល់ជាអ្នកណាៗទេ ក្នុងក្រុមគេបាទ។ បានជាដឹងថា សុទ ហ្នឹងប៉ះពាល់សីលធម៌ គេប្រាប់តែខ្ញុំប៉ុណ្ណឹង។ ខ្ញុំគឺ-- ។

**ស៖** ថាតើសមមិត្ត សុទ ហ្នឹង គេចាប់នៅទីណាដែរ? គេចាប់ខ្លួននៅកន្លែងណាដែរ?

**ឆ៖** បាទនៅក្នុងតំបន់ហ្នឹង។ មិនមែនបានចាប់ចងអីទេ គ្រាន់តែថាឃាត់ខ្លួន បាទ។

**ស៖** តើគេឃុំខ្លួន សុទ ហ្នឹងនៅកន្លែងណា? ឃុំនៅ ក-១១ ដែលជាមន្ទីរសន្តិសុខដែលលោកបង្ហាញពីលើកមុន ឬមួយក៏នៅភ្នំក្រៀល មន្ទីរសន្តិសុខ ឬមួយក៏នៅមន្ទីរក-១៦ តើគេឃុំខ្លួន សុទ ហ្នឹងនៅកន្លែងណាដែរ?

**ឆ៖** បាទ គេមិនដែលបញ្ជូនមក ក-១១ ទេ ពីព្រោះគ្រាន់តែថា ឃាត់ខ្លួនមិនឲ្យទៅណាមកណានៅក្នុងកងរបស់គេបាទ។

**ស៖** ខ្ញុំចង់សួរលោកបន្តអំពីជួរបន្ទាប់នៅក្នុងទូរលេខរបស់លោក ហើយនៅក្នុងនោះលោករាយការណ៍អំពីស្ថានភាពរបស់សមមិត្ត សុទ ការបកប្រែជាភាសាបារាំង និងភាសាអង់គ្លេស គឺមានលក្ខណៈខុសគ្នា។

ដូច្នេះ ខ្ញុំសូមអនុញ្ញាតថា សូមឲ្យ-- សូមអនុញ្ញាតអានជាភាសាខ្មែរដើម្បីឲ្យសាក្សីស្ដាប់។ ដូច្នេះចំណុចដែលយើងចង់អាន គឺចំណុចដែលបន្ទាប់ពីកថាខណ្ឌទី៣ តើអាចបានដែរឬទេ លោកប្រធាន?

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត! សូមអញ្ជើញ!

[១១:២១:៤៩]

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន ហើយខ្ញុំសូមអាននូវអត្ថន័យដកស្រង់ដូចតទៅនេះ៖ “ឯបញ្ហានេះ សូមជួយយោបល់ ត្រូវទុកដាក់កម្រិតណា ឬក៏ឲ្យជូនទៅណោះ”។ បាទ សូមអរគុណ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ដូច្នេះ សំណួរដែលខ្ញុំចង់សួរលោក គឺហេតុអ្វីបានជាលោកសួរ ប៉ុល ពត ដើម្បីសុំយោបល់ត្រូវទុកដាក់កម្រិតណា ឬក៏ឲ្យជូនទៅណេះ? ដូច្នេះ ខ្ញុំចង់សួរថា ហេតុអ្វីបានជាលោកសួរ ប៉ុល ពត សុំឲ្យជូនយោបល់អំពីបញ្ហានេះទៅវិញ?

**លោក សៅ សារុន៖**

**ឆ៖** បាទ ខ្ញុំចង់សួរ អ៎! ខ្ញុំ បញ្ហាសំណួរហ្នឹង ខ្ញុំមិនច្បាស់ សូមអានម្តងទៀតបាទ។

**លោក សេង ប៊ុនឃាង៖**

បាទ ខ្ញុំសូមអានម្តងទៀត “ឯបញ្ហានេះសូមជួយយោបល់ ត្រូវទុកដាក់កម្រិតណា ឬក៏ឲ្យជូនទៅណេះ”។ បាទ សូមអរគុណ។

[១១:២៣:២៧]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ដូច្នេះ សំណួររបស់ខ្ញុំ គឺសាមញ្ញទេ ហេតុអ្វីបានជាលោកសួរ ប៉ុល ពត ពីបញ្ហាទាំងអស់នេះ? ហេតុអ្វីបានជាលោកឲ្យ ប៉ុល ពត សុំជួយយោបល់?

**លោក សៅ សារុន៖**

**ឆ៖** បាទ ខ្ញុំបានសួរមែន ពីព្រោះឃាត់ខ្លួនគេហើយ យើងមិនសួរទៅខាងលើ ក៏មិនបាន។ យើងចេះតែថាធ្វើតែផ្តេសផ្តាសមិនបាន។ ទាល់ខាងលើឯកភាពថា អើ ដោះលែង គឺដោះលែង។ គ្រាន់តែយើងឃាត់ខ្លួនគេ ឃុំឃាំងហ្នឹងមួយកន្លែងហើយ យើងមិនឲ្យគេទៅណា មកណា។ សួរគេខាងលើខាងលើគេថា យល់ឯកភាព លែងឲ្យគាត់មានសុវត្ថិភាព ក៏លែង វាមានបញ្ហាអី។ គ្រាន់តែប៉ះពាល់នារីបុរសហ្នឹង បាទ។

**ស៖** ហើយតើលោកទទួលបានសេចក្តីណែនាំពីថ្នាក់លើ អំពីអ្វីដែលលោកត្រូវធ្វើទេ ក្រោយពីលោកសុំយោបល់ហ្នឹងហើយ។ តើខាងលើមានផ្តល់ចម្លើយតបមកវិញទេ?

**ឆ៖** បាទ ដល់ខ្ញុំសួរយោបល់ទៅ ខាងលើគាត់តបទៅ ពីយើងទៅ បញ្ហារឿងសីលធម៌អីយើងអប់រំណែនាំគាត់ទៅ ឲ្យគាត់កែប្រែទៅ យើងក៏លែងឲ្យគាត់រស់នៅដោយសុវត្ថិភាពធម្មតា។

[១១:២៥:០៩]

**ស៖** តើថ្នាក់លើហ្នឹងអ្នកណា? តើលោកថាថ្នាក់លើផ្តល់យោបល់ហ្នឹង តើជាអ្នកណាដែល

ឆ្លើយតបទៅនឹងទូរលេខរបស់លោកនោះ?

**ឆ៖** បាទ លោក ប៉ុល ពត។

**ស៖** តើលោកចាំដែរឬទេ ថានៅពេលដែល ប៉ុល ពត បញ្ជូនទូរលេខមកលោកវិញ តើទូរលេខហ្នឹងគេចុះហត្ថលេខាដោយរបៀបណា? ដោយឈ្មោះគាត់ ឬក៏ដោយសរសេរជាលេខកូដ-- ជាលេខកូដ តើលោកចាំបានដែរឬទេ?

**ឆ៖** បាទ គាត់សរសេរឈ្មោះខ្លួនគាត់។

**ស៖** សូមអរគុណ។ ខ្ញុំចង់សួរលោកពីរបីសំណួរទៀតពាក់ព័ន្ធទៅនឹងបញ្ហាសមត្ថកិច្ច។ នៅក្នុងករណីដែលអ្នកជាប់ឃុំត្រូវបានគេឃុំឃាំង ឬក៏ត្រូវបានគេចោទប្រកាន់ថា ជាអ្នកក្បត់ ឬក៏ជាអ្នកប្រឆាំងបក្សនុំុង តើលោកមានសិទ្ធិអំណាចក្នុងការសម្រេច ថាតើត្រូវធ្វើយ៉ាងម៉េចជាមួយបុគ្គលទាំងនោះទេ? ឬមួយក៏លោកចាំបាច់ត្រូវតែស្វែងរកនូវការសម្រេចពីថ្នាក់លើនៅក្រុងភ្នំពេញ?

[១១:២៦:៥៨]

**ឆ៖** បាទ ពីព្រោះគេ កាលពីខ្ញុំនៅមិនមក កាន់កាប់ការងារនៅក្នុងតំបន់ ឃើញថាមានអ្នកត្រូវគេឃុំឃាំងហ្នឹង បួន-ប្រាំនាក់។ ខ្ញុំឱ្យគេហៅមកសាកសួរទៅ វាឥតមានការពាក់ព័ន្ធអីពីរឿងបញ្ហាអីគ្រាន់តែមានការឈ្លោះប្រកែកគ្នាក្នុងគ្រួសារអីបន្តិចបន្តួច ខ្ញុំទៅសួរយោបល់ខាងលើ មកខាងអ៊ំ-- តាលោក ប៉ុល ពត ថា សភាពការណ៍អ៊ីចឹង ត្រូវលែងគេទៅ។ យើងទៅឃុំឃាំងគេទៅអី នាំឱ្យតែខាត។ បាទ គឺប៉ុណ្ណឹង។ ខ្ញុំសូមអស់។

**ស៖** ក្នុងករណីដែលបុគ្គលត្រូវបានគេចោទប្រកាន់ថាជាខ្មាំងសត្រូវរបស់បក្ស ថាតើអ្នកណាមានសិទ្ធិអំណាចក្នុងការសម្រេចក្នុងការដោះលែង ឬក៏ឃុំឃាំង ឬមួយក៏កម្ទេច តើអ្នកណាជាអ្នកមានសិទ្ធិសម្រេច?

**ឆ៖** បាទ សួរទៅ វាអត់អ្នកណាហ្នឹង នៅត្រូវកម្ទេចហ្នឹងបាទ។ សួរទៅ វាគ្រាន់តែមូលបង្កាច់គ្នាតិចតួចទៅ ឈ្លោះគ្នាទៅ ចេះតែរាយការណ៍តែផ្ដេសផ្ដាស។ វាអត់មានរឿងសាច់រឿង វាក្បត់អី។ បាទខ្ញុំសូមបញ្ជាក់ ពន្យល់អ៊ីចឹងបាទ។

[១១:២៨:៤២]

**លោក ខេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតដកស្រង់នូវកិច្ចសម្ភាសន៍ទីបី របស់សាក្សីជាមួយនឹងសហចៅក្រម

សៀ៊ុបអង្កេតគឺ E3/384 ហើយខ្មែរគឺលេខ 00345904, ភាសាអង់គ្លេស គឺ 00348373 និងភាសាបារាំង គឺមានលេខ 00354237 ហើយខ្ញុំសូមអនុញ្ញាតបង្ហាញនៅលើអេក្រង់ទូរទស្សន៍ និងកុំព្យូទ័រ។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោកសាក្សី នៅក្នុងចម្លើយរបស់លោកជាមួយសហចៅក្រមស៊ើបអង្កេត លោកបានបង្ហាញ-- បាទ លោកបានឆ្លើយតបដូចតទៅ៖ "សំណួរ៖ តើករណីអ្វីខ្លះ ដែលលោកមានសិទ្ធិដោះលែងដោយខ្លួន?" ចម្លើយ៖ ករណីដែលទាក់ទងទៅនឹងការកាប់សម្លាប់កំប៉ិចកំប៉ុក ដូចជារឿងវាយគ្នា ឈ្លោះគ្នាក្នុងមូលដ្ឋាន ហើយជាករណីដែលមិនទាក់ទងនឹងនយោបាយ ឬក្បត់បក្ស។ សំណួរ៖ ករណីនយោបាយនិងក្បត់បក្សមានន័យដូចម្ដេច? ចម្លើយ៖ ដូចជាអ្នកចូលដៃចូលជើងជាមួយពួកឈ្លានពាន ឬពួកខ្មាំងគឺខ្មាំងយួន។" លោកសាក្សី តើនេះជាចម្លើយដែលត្រឹមត្រូវដែរឬទេ ពាក់ព័ន្ធទៅនឹងសិទ្ធិរបស់លោក និងសិទ្ធិរបស់មេដឹកនាំនៅក្នុងទីក្រុងភ្នំពេញ? តើជាចម្លើយត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ជាចម្លើយត្រឹមត្រូវ។

[១១:៣០:៥៣]

**ស៖** ហើយមូលហេតុដែលលោកផ្ញើទៅអង្គការអំពីបញ្ហាសមមិត្ត សុទ ហើយនិងស្នើសុំយោបល់នោះគឺថា ដោយសារតែគេឆ្លើយដាក់ថា គាត់ជាជនក្បត់ក្នុងចម្លើយសារភាពរបស់ ជួន តើមែនដែរឬទេ? ខ្ញុំចង់ដឹងថា ប្រសិនបើ សុទ ហ្នឹងមិនត្រូវបានគេឆ្លើយតប គេឆ្លើយដាក់ថា ជាជនក្បត់ទេ ហើយ សុទ ហ្នឹងគ្រាន់តែមានការប៉ះពាល់ផ្នែកសីលធម៌ហ្នឹង តើលោកនឹងផ្ញើទូរលេខទៅគាត់ដែរឬទេ? តើលោកអាចឆ្លើយបានដែរឬទេ?

[១១:៣១:៣៥]

**ឆ៖** បាទ សួរមែន ពីព្រោះសួរទៅវាអត់មានរឿងអីនឹងប៉ះពាល់ រឿងក្បត់ គ្រាន់តែប៉ះពាល់រឿងសីលធម៌ ស្រីញី បាទ។

**ស៖** សូមអរគុណលោក សៅ សារុន។ ឥឡូវនេះ ខ្ញុំចូលទៅដល់ប្រធានបទថ្មីមួយទៀត ដែលទាក់ទងទៅនឹងដំណើរ ហើយនិងការប្រជុំរបស់លោកនៅភ្នំពេញ បន្ទាប់ពីកើតឡើងនៅក្នុងឆ្នាំ១៩៧៨

លោកបាននិយាយអំពីរបាយការណ៍លាយលក្ខណ៍អក្សរ ហើយនិងទូរលេខបន្ទាប់ពីគេសួរលោក សូមឲ្យធ្វើជាលេខាតំបន់បន្ទាប់ពី ឡាំង។ ហើយលោកបាននិយាយអំពីដំណើរដែលលោកមកភ្នំពេញដែលគេដែល ប៉ុល ពត ស្នើឲ្យលោកទទួលតំណែងបន្តពី ឡាំង តើលោកនៅចាំដែរឬទេ? ថាតើបីបួនខែក្រោយមកគឺថា ធ្វើដំណើរម្តងទៀតមកភ្នំពេញនោះ នៅចាំទេ?

[១១:៣៣:០២]

**ឆ៖** បាទ គឺបញ្ហាហ្នឹង គឺយូរហើយ ខ្ញុំភ្លេចៗអស់ហើយ តាំងពីខ្ញុំមានជំងឺនេះ ខ្ញុំភ្លេចការចងចាំដែរ។

**ស៖** ខ្ញុំសូមអនុញ្ញាតដើម្បីជួយឲ្យលោកនឹកឡើងវិញ រំឭកឡើងវិញ គឺនៅក្នុងចម្លើយទីមួយរបស់លោកទៅសហចៅក្រមស៊ើបអង្កេតគឺ E3/367, ខ្មែរ ERN 00251439, អង់គ្លេស ERN 00278696 ហើយបារាំង ERN 00486011។

**លោក ខេល លីសាក់៖**

សូមអនុញ្ញាតលោកប្រធាន ដើម្បីបង្ហាញឯកសារដកស្រង់នេះនៅលើអេក្រង់ទូរទស្សន៍ ហើយនិងកុំព្យូទ័រផងដែរបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

[១១:៣៤:២៧]

**សួរដោយលោក ខេល លីសាក់៖**

**ស៖** នៅក្នុងការសម្ភាសទីមួយរបស់លោក លោកបានឆ្លើយដូចខាងក្រោមនេះលោកសាក្សីដកស្រង់៖ “ប្រហែលជាពីរបីខែក្រោយពី ឡាំង និង ខាំ ភួន ស្លាប់មក ខ្ញុំបានទទួលទូរលេខមួយមកពី ប៉ុល ពត ឲ្យកោះឲ្យកម្មាភិបាលចូលរួមប្រជុំ ហើយនៅក្នុងនោះកម្មាភិបាលប្រាំមួយនាក់មាន តារៀង, តាលក, តាគីម, តាឡាន់, តាសុភា ទាំងប្រាំមួយនាក់នេះត្រូវកោះហៅទៅប្រជុំនៅភ្នំពេញ។ បាទ តើនេះគឺជាចម្លើយត្រឹមត្រូវរបស់លោកកាលនោះទេ លោកសាក្សី?

**លោក សៅ សារុន៖**

**ឆ៖** បាទ បញ្ហាហ្នឹង គឺជាបញ្ហាត្រឹមត្រូវ ហៅទៅប្រជុំមែន។

**ស៖** នៅក្នុងពេលនោះ នៅពេលដែលលោកទៅភ្នំពេញជាមួយមនុស្សមួយក្រុមនេះ តើលោកធ្វើ

ដំណើរតាមអ្វីដែរ?

**ឆ៖** បញ្ហានេះ គឺខ្ញុំធ្វើដំណើរហ្នឹង ខ្ញុំចង់ភ្លេច សុំឲ្យ អឺ... សួរម្ដងទៀត។ សំណួរហ្នឹង គឺខ្ញុំមិនច្បាស់បាទ។

**ស៖** តើលោកធ្វើដំណើរទៅភ្នំពេញដោយវិធីណា? នៅដំណើរនេះ តើលោកជិះយន្តហោះទេកាលនោះនុះ?

**ឆ៖** កាលហ្នឹងដូច កាលហ្នឹងដូចខ្ញុំជាភ្លេច ដូចជិះយន្តហោះដឹង ឬក៏ជិះកប៉ាល់ ខ្ញុំសូមអភ័យទោសចុះ ខ្ញុំភ្លេច នឹកមិនឃើញបាទ។

**ស៖** ទូរលេខដែលលោកទទួលបានពី ប៉ុល ពត ហើយសូមឲ្យលោកប្រជុំនោះ តើគាត់បានបញ្ជាក់ថា ចង់ឲ្យយកអ្នកណាទៅជាមួយទេ? ឬក៏លោកជាអ្នកសម្រេច ថាតើត្រូវយកកម្មាភិបាលទៅប៉ុន្មាននាក់ទៅពីតំបន់ ដើម្បីទៅជាមួយលោក?

[១១:៣៦:៥៦]

**ឆ៖** បាទ អាហ្នឹងគឺបញ្ជាមកទេ លោក ប៉ុល ពត ខ្ញុំអត់មានសិទ្ធិអីសម្រេចថា យកអ្នកនេះ អ្នកនោះទេបាទ។

**ស៖** សំណួរមានមនុស្សមួយចំនួនដែលថាធ្វើដំណើរជាមួយលោក ដែលលោកបាននិយាយពីខាងដើមហ្នឹង គឺថាមានថ្មី ឈ្មោះថ្មីៗខ្លះដែលខ្ញុំចង់ជម្រាបជូនលោក ដែលលោកនិយាយថា អ្នកទាំងនោះគឺមាន ដែលឲ្យហៅទៅភ្នំពេញនោះគឺមានឈ្មោះ តាគីម តើតាគីម ហ្នឹងជាអ្នកណា?

**ឆ៖** បាទ តាគីម ហ្នឹងកងពល៩២០។

**ស៖** ថាតើគាត់គឺជាអនុលេខានៃកងពល៩២០ នៅក្រោម តាសាន ហ្នឹងឬ?

**ឆ៖** បាទ គាត់ជាអនុកងពល ក្រោម តាសាន មែនបាទ។

**ស៖** យើងបានឃើញឈ្មោះ តាវៀង តើ តាវៀង ហ្នឹងគាត់មានតំណែងជាអ្វីដែរ នៅក្នុងឆ្នាំ១៩៧៨?

**ឆ៖** បាទ គាត់ជាប្រធានវរសេនាតូច។

[១១:៣៨:៤៥]

**ស៖** តើត្រូវដែរឬទេ មនុស្សភាគច្រើន ដែលៗគេហៅឲ្យទៅជាមួយលោកក្នុងដំណើរនេះ គឺសុទ្ធតែមេដឹកនាំយោធា មកពីតំបន់១០៥ គឺមកពីកងពល៩២០ នោះ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** នៅពេលដែលលោកមកដល់ភ្នំពេញ តើលោកបានជួបជាមួយអ្នកណាខ្លះ?

**ឆ៖** បាទ ជួបជាមួយលោក ប៉ុល ពត។

**ស៖** តើនៅចាំថាបានជួបជាមួយមេដឹកនាំណាផ្សេងទៀត ក្រៅពី ប៉ុល ពត ដែរឬទេ?

**ឆ៖** ដូចអត់ឃើញ បាទ។

[១១:៤០:០០]

**លោក ខេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតអាននូវចម្លើយទីមួយរបស់សាក្សីនេះ គឺនៅក្នុងឯកសារ E3/367 ហើយនៅក្នុងសេចក្ដីដកស្រង់នៅក្នុងខ្មែរ ERN 00251439, អង់គ្លេស ERN 00278696 ហើយ បារាំង ERN 00486011 ហើយសូមអនុញ្ញាតបង្ហាញនៅលើអេក្រង់ផងដែរ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ខេល លីសាក់៖**

**ស៖** នៅពេលដែលលោកឆ្លើយជូនសហចៅក្រមស៊ើបអង្កេតនៅក្នុងរឿងប្រជុំនេះ លោកបាន និយាយថា សូមដកស្រង់៖ "ពួកខ្ញុំទាំង៦នាក់ បានជិះយន្តទៅមកជួប ខៀវ សំផន ហៅ ហែម, សុន សេន ហៅ ខៀវ, នួន ជា និង ប៉ុល ពត នៅមន្ទីររបស់ ប៉ុល ពត នៅក្រោយវាំងដដែល"។ បាទ តើនេះជាចម្លើយត្រឹមត្រូវរបស់លោក ដែលបានលោកជួបអ្នកទាំងនោះនៅភ្នំពេញឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ! ចាំស្ដាប់អង្គជំនុំជម្រះសម្រេចលើសេចក្ដីជំទាស់របស់មេធាវីសិន។

សូមអញ្ជើញលោកមេធាវី!

**លោក អាកឡូរ វែកគែន៖**

ខ្ញុំគិតថា មិនមែនជាការជំទាស់នោះទេ។ ក៏ប៉ុន្តែ ខ្ញុំគ្រាន់តែចង់បញ្ជាក់ដែលបានធ្វើដោយភាគី របស់ខ្ញុំ ខ្ញុំគិតថា នៅក្នុងវគ្គនេះ ហើយនិងវគ្គផ្សេងទៀតផងដែរ មានបញ្ហាប្រតិចារឹកនៃកំណត់ហេតុ ស្ដាប់ចម្លើយសាក្សីនេះ។ ខ្ញុំគិតថា នេះជាពេលដែលត្រូវជម្រាបជូនដល់អង្គជំនុំជម្រះហើយ អំពីការដាក់ ឈ្មោះបដិវត្តន៍នេះ ដែលទៅដល់បុគ្គលគ្រប់រូប។

[១១:៤២:០៨]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៤២:៥២]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកប្រធាន។ លោកមេធាវី វែកគែន តើលោកអាចបញ្ជាក់ឲ្យច្បាស់ទៅជូនអង្គជំនុំជម្រះបានដែរឬទេ? លោកកំពុងតែរៀបរាប់អំពីការលំបាក ឬក៏ភាពខុសគ្នា ធៀបទៅនឹងអ្វី? ធៀបទៅនឹងខ្សែអាត់សំឡេង? លោកអាចបញ្ជាក់ឲ្យបានច្បាស់លាស់បានដែរឬទេ ទាក់ទងនឹងភាពខុសគ្នានេះ អាខ្សែអាត់សំឡេងផ្សេងៗគ្នា ហើយនិងប្រតិចារឹកជាលាយលក្ខណ៍អក្សរ? អ៊ីចឹងសូមបញ្ជាក់អំពីភាពខុសគ្នានេះបានដែរឬទេ?

[១១:៤៣:៣៩]

**លោក អាកទូរ វែកគែន៖**

បាទ ភាពខុសគ្នា គឺរវាងខ្សែអាត់នៃកិច្ចសម្ភាសន៍របស់សាក្សីនេះ របស់សហចៅក្រមស៊ើបអង្កេតហើយ ហើយនិងប្រតិចារឹកដែលបានធ្វើនៅក្នុងកំណត់ហេតុស្តាប់ចម្លើយគាត់។ ខ្ញុំយល់ឃើញថា នៅក្នុងខ្សែអាត់នោះ អ្នកស៊ើបអង្កេតសួរទៅគាត់ ហើយនិងៗសួរនាំមុខ ហើយផ្តល់ឈ្មោះៗ ហៅក្រៅទៅសាក្សីនេះ ហើយនៅក្នុងខ្សែអាត់នោះខ្ញុំអាចឲ្យ-- ខ្ញុំមិនមានការបកប្រែមិនមានៗការ--ប្រតិចារឹកទាំងអស់នេះខ្សែអាត់នោះទេ។ ហើយខ្ញុំអាចធ្វើការ-- យើងអាចធ្វើការផ្ទៀងផ្ទាត់ចេញពីខ្សែអាត់ ហើយខ្ញុំសូមជូនជាព័ត៌មាន នៅខ្សែអាត់នៅវគ្គមួយនោះ គឺថាៗ មួយម៉ោងម្ភៃប្រាំមួយនាទី សាមសិបសីហ្កុងនៅនាទីនុ៎ងបាទ លោកចៅក្រម។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បើខ្ញុំមិនច្រឡំទេ គឺថាអ្វីដែលលោកចង់និយាយនោះគឺថា ឈ្មោះហៅក្រៅរបស់លោក ខៀវ សំផន គឺត្រូវផ្តល់ជូនទៅឲ្យសាក្សី ហើយសាក្សីមិនបាននឹកឃើញផ្តល់ឈ្មោះហៅក្រៅនេះ របស់លោក ខៀវ សំផន ដោយខ្លួនឯងនោះទេ។

**លោក អាកទូរ វែកគែន៖**

បាទ ពិតជាអ៊ីចឹងហើយលោកចៅក្រម។

[១១:៤៥:២៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ដោយហេតុថា ឈ្មោះក្រៅនោះគឺ ចោទជាបញ្ហា ខ្ញុំនឹងសួរសាក្សីតាមវិធីនេះវិញ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** នៅពេលដែលលោកជម្រាបសហចៅក្រមស៊ើបអង្កេត តើត្រឹមត្រូវដែរទេ នៅលោកប្រាំមួយនាក់បានទៅភ្នំពេញនោះ ហើយមេដឹកនាំដែលលោកបានជួបនោះ មាន ខៀវ សំផន, សុន សេន, នួន ជា ហើយនិង ប៉ុល ពត។ តើត្រឹមត្រូវដែរឬទេ?

**លោក សៅ សារុន៖**

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** តើការប្រជុំនោះប្រើរយៈពេលប៉ុន្មានដែរ ដែលលោកបានជួបជាមួយ ខៀវ សំផន, នួន ជា ហើយនិង សុន សេន និង ប៉ុល ពត នោះ?

[១១:៤៦:៣៩]

**ឆ៖** បាទ ប្រជុំតែមួយព្រឹក។

**ស៖** ដើម្បីបញ្ជាក់ តើទីកន្លែងនៃការប្រជុំនោះ តើនៅទីកន្លែងដដែល បន្ទប់ដដែល ដែលលោកបានជួបជាមួយ ប៉ុល ពត, នួន ជា និង សុន សេន ប្រហែលជាពីរបីខែមុនហ្នឹង បន្ទាប់ពី ឡាំង ស្លាប់។ តើហ្នឹងជាកន្លែងដែលប្រជុំហ្នឹងដដែលដូចគ្នាហ្នឹងឬ?

**ឆ៖** បាទ កន្លែងប្រជុំហ្នឹង គឺដដែល។

**ស៖** តើការពិភាក្សាក្នុងអង្គប្រជុំនោះ ដែលមានរូបលោក ហើយនិងកម្មាភិបាលប្រាំរូបទៀតមកពីតំបន់១០៥ ដែលមាននៅក្នុងនោះមាន ខៀវ សំផន, នួន ជា, សុន សេន និង ប៉ុល ពត។ តើការប្រជុំលើកនេះ និយាយអំពីអ្វី?

[១១:៤៧:៥៩]

**ឆ៖** បាទ និយាយអំពីបញ្ហា ទីមួយ គឺគ្រប់គ្រងកម្លាំងកងទ័ព គ្រប់គ្រងប្រជាជន ធ្វើយ៉ាងម៉េចឲ្យអប់រំគេឲ្យយល់ឲ្យជ្រួតជ្រាប អំពីមាគ៌ាសេដ្ឋកិច្ច ដើម្បីដោះស្រាយសេដ្ឋកិច្ចជីវភាព ខាងកងទ័ពគឺការពារព្រំដែនឲ្យបានល្អ អីចឹងបាទ។

**ស៖** នៅក្នុងការប្រជុំនេះ តើលោកបានរាយការណ៍ ទៅឲ្យមេដឹកនាំនៅភ្នំពេញអំពីសកម្មភាពនៅក្នុងតំបន់១០៥ ដែរឬទេ?

**ឆ៖** អត់ទេ។ បានតែរាយការណ៍ អំពីសភាពការណ៍កសាងសេដ្ឋកិច្ច ជីវភាពអីគឺអាហ្នឹងរាយការណ៍ បើសកម្មភាពអីផ្សេងៗមិនបានរាយការណ៍ទេបាទ ពីព្រោះវាអត់ឃើញ អត់ដឹង។

**ស៖** ខ្ញុំសូមឲ្យលោកបញ្ជាក់បន្ថែម តើលោកបានរាយការណ៍អំពីការងារខ្លះទាក់ទងនឹងតំបន់១០៥ ទេនៅក្នុងប្រជុំនេះ ឬក៏លោកមិនបានរាយការណ៍អ្វីទាំងអស់ បាទ អំពីអ្វីៗដែលកើតឡើងនៅតំបន់នោះ តើលោកមិនរាយការណ៍ទាំងអស់ ឬក៏បានរាយការណ៍ខ្លះដែរ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ! ចាំស្តាប់អង្គជំនុំជម្រះ សម្រេចលើសេចក្តីជំទាស់របស់មេធាវីការពារក្តីសិន។ សូមអញ្ជើញលោកមេធាវី!

[១១:៤៩:៥៥]

**លោក អាកឡូរ វែកគែន៖**

បាទ សូមអរគុណលោកប្រធាន។ សំណួរនេះគឺជាសំណួរដដែលៗ សាក្សីទើបតែនឹងឆ្លើយនឹងសំណួររបៀបហ្នឹងអម្បាញ់មិញហ្នឹងហើយៗ។

**លោក ឌេល លីសាក់៖**

ខ្ញុំឆ្លើយតប គឺថាគាត់ឆ្លើយមិនច្បាស់។ ដូច្នេះខ្ញុំសួរឲ្យគាត់បញ្ជាក់ថា តើគាត់បានរាយការណ៍អំពីសភាពការណ៍សកម្មភាពពីតំបន់ ឬអត់? អ្វីដែលជាក់លាក់តែប៉ុណ្ណោះបាទ។

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់គ្មានប្រសិទ្ធភាព។ អង្គជំនុំជម្រះត្រូវការស្តាប់ចម្លើយតបរបស់សាក្សីរូបនេះចំពោះសំណួរចុងក្រោយរបស់តំណាងសហព្រះរាជអាជ្ញា។ សាក្សីឆ្លើយតបនឹងសំណួរ!

**លោក សៅ សារុន៖**

**ឆ៖** បាទ ខ្ញុំឲ្យលោកសួរខ្ញុំម្ដងទៀតបាទ។ ខ្ញុំមិនសូវយល់ៗ។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** សំណួររបស់ខ្ញុំគឺសូមឲ្យលោកបំភ្លឺបន្ថែម ថាតើលោកបានរាយការណ៍ទៅក្នុងកិច្ចប្រជុំនេះ អំពីស្ថានការណ៍ សភាពការណ៍នៅក្នុងតំបន់៥០៥ (ស៊ីក) ដែរឬទេ?

**អ្នកបកប្រែ៖** បាទ តំបន់១០៥ ដែរឬទេ? សូមកែតម្រូវ។

**ឆ៖** បាទ គឺខ្ញុំបានប្រជុំហ្នឹងជារាយការណ៍ ទីមួយ គឺរាយការណ៍អំពីជីវភាពរបស់ប្រជាជន ជាបញ្ហាធ្វើស្រែ ធ្វើចម្ការ បានប៉ុន្មាន អីៗប៉ុន្មានក្នុងមួយឆ្នាំៗ អាចហូប ប្រជាពលរដ្ឋអាចហូបគ្រប់គ្រាន់យ៉ាងម៉េច អាហ្នឹងគឺរាយការណ៍ជូនគាត់ ដើម្បីគាត់ជួយយោបល់យ៉ាងម៉េចៗ អាហ្នឹងគឺរាយការណ៍មែន។ សំខាន់ គឺរាយការណ៍ជុំវិញពីជីវភាពប្រជាជន ប៉ុណ្ណឹងបាទ។

[១១:៥២:០៥]

**ស៖** សូមអរគុណលោកសាក្សី។ តើលោកអាចជម្រាបតុលាការបានទេនេះជាការប្រជុំដដែល ដែលគេកោះហៅលោកទៅដោយសារថាមានបញ្ហាមិនធម្មតា សភាពការណ៍ខុសធម្មតាកើតឡើង ឬក៏អាចនិយាយថា តើនេះជាការប្រជុំធម្មតាដែលមេដឹកនាំកោះហៅ ដើម្បីឲ្យទៅរាយការណ៍អំពីសភាពការណ៍។ តើនេះជាការប្រជុំដែលកើតឡើងទៅតាមកាលវេលាទៀងទាត់ ឬក៏ការប្រជុំនេះកើតឡើងដោយសារតែមានសភាពការណ៍ពិសេស ដែលកើតឡើងបានជាគេហៅទៅប្រជុំ?

[១១:៥២:៤៧]

**ឆ៖** បាទ គឺខ្ញុំ ចង់សួរអាហ្នឹងបញ្ហាសំណួរហ្នឹង ខ្ញុំអត់យល់ ដូចសួរសំដៅលើប្រជុំនៅណា គឺអាហ្នឹងខ្ញុំចង់ឲ្យលោកបញ្ជាក់សំណួរហ្នឹងឡើងវិញ ម្ដងទៀតបាទ។

**ស៖** សូមអរគុណបាទ។ សំណួរខ្ញុំថា តើមានការប្រជុំធម្មតាទេដែលលោកទៅភ្នំពេញជាទៀងទាត់ ហើយត្រូវរាយការណ៍ទៅមេដឹកនាំអំពីសភាពការណ៍នៅតំបន់របស់លោកនោះ?

**ឆ៖** បាទ ការប្រជុំហ្នឹងវា ជួនកាលចាប់ពីខ្ញុំមកកាន់ការងារនៅក្នុងតំបន់បានរយៈតែពីរខែ។ ប្រជុំជួនកាលមួយខែរាយការណ៍ សំខាន់គឺរាយការណ៍ជុំវិញអំពីជីវភាពប្រជាជន។ ការខ្វះខាតយ៉ាងម៉េច? ការហូបចុកយ៉ាងម៉េច? គ្រប់គ្រាន់ឬអត់? បាទ ខ្ញុំក៏បានរាយការណ៍ជូនគាត់ជាបន្តបន្ទាប់។ គឺការហូបចុកគឺ គ្រប់គ្រាន់។ ស្រូវ អង្ករ គឺកំណត់ថាហូបមួយថ្ងៃបីពេល បានរាយការណ៍ជូនគាត់ គឺរឿង

សេដ្ឋកិច្ចហ្នឹងតែម្តង គឺជីវភាព។ ឯក្រៅពីហ្នឹង ក៏មិនបានរាយការណ៍ ពីព្រោះវាអត់មានរឿងអី គាត់ក៏សួរដែរ វាអត់ដឹង ប្រាប់គាត់អត់ដឹង ប្រាប់ដឹងតែខាងសេដ្ឋកិច្ច។ ការងារអីក្រៅពីហ្នឹង មិនដែល-- អត់ដឹង។

[១១:៥៤:៤១]

**ស៖** សូមអរគុណ។ ពីម្សិលមិញលោកបានប្រាប់ទៅសហព្រះរាជអាជ្ញាជាតិថា លោកបានជួប ខៀវ សំផន នៅក្នុងពេលរបបកម្ពុជាប្រជាធិបតេយ្យ ហើយលោកបានរៀប ប្រាប់យើងថា នៅឱកាសមួយបានជួបគាត់។ តើលោកបាន-- លោកប្រាប់ទេថា តើនៅឱកាសណា គឺនៅក្នុងឆ្នាំ១៩៧៥ ខែមេសារហូតដល់ មករា ឆ្នាំ១៩៧៩ ថា ពេលណាដែលលោកបានឃើញលោក ខៀវ សំផន នោះ?

**ឆ៖** បាទ ឃើញពេលទៅប្រជុំហ្នឹង។ ខ្ញុំក៏មិនសូវស្គាល់គាត់ច្បាស់ដែរ។ បាទ អត់សូវស្គាល់គាត់ច្បាស់ទេ។ ដល់ទៅក៏បាន ហ្នឹងបានស្គាល់គាត់ពេលទៅប្រជុំហ្នឹងបាទ។

**ស៖** តើលោកធ្លាប់និយាយជាមួយលោក ខៀវ សំផន ពីបញ្ហាសេដ្ឋកិច្ចដែរឬទេ ក្នុងអំឡុងពេលដែលលោកតែងតែមកភ្នំពេញ ដើម្បីប្រជុំនោះ?

**ឆ៖** បាទ និយាយមែន គឺបញ្ហាសេដ្ឋកិច្ចហ្នឹង គឺសុំស្នើ សម្ភារៈដើម្បីទៅផ្គត់ផ្គង់ប្រជាពលរដ្ឋដូចជាក្រណាត់ ដូចជាអំបិល ដូចជាបញ្ហាអីត្រូវការ គឺស្នើ។ អាហ្នឹងបាន-- អាហ្នឹងសំណេះសំណាលគ្នាពីបញ្ហាហ្នឹងបាទ។

[១១:៥៦:៣៤]

**ស៖** ថាតើការប្រជុំដែលលោកបានឃើញលោក ខៀវ សំផន នោះ ហើយបានពិភាក្សាអំពីបញ្ហាសេដ្ឋកិច្ច ហើយបានដាក់សំណើឲ្យដាក់ ឲ្យគាត់ផ្គត់ផ្គង់អ្វីៗ ក្រណាត់អីផ្សេងហ្នឹង តើប្រជុំនៅពេលណា? បាទ នៅកន្លែងណាដែរ?

**ឆ៖** បាទ កន្លែងចាស់ដដែល ដូចខ្ញុំជម្រាបកាលពីខាងលើ។

**ស៖** នៅពេលដែលលោកនិយាយថា លោកបានធ្វើសំណើសុំក្រណាត់ ហើយនិងសម្ភារៈផ្សេងៗជូនទៅលោក ខៀវ សំផន នោះ តើជាសំណើសរសេរជាលាយលក្ខណ៍អក្សរ បានន័យសរសេរលើក្រដាសឬ?

**ឆ៖** បាទ ពេលសំណេះសំណាលគ្នាខ្ញុំមិនទាន់បានសរសេរអីទេ គ្រាន់តែមានសំណេះសំណាលរឿងការខ្វះខាតរបស់ប្រជាជន ដើម្បីជម្រាបឲ្យគាត់ដឹងឮ ។ បាទ ប៉ុណ្ណឹងទេបាទ។

**សះ** តើលោកបានដឹងដោយរបៀបណា ដែលថា ខៀវ សំផន គឺជាបុគ្គលដែលត្រូវ-- ដែលលោកត្រូវដាក់សំណើសុំសម្ភារៈផ្សេងៗនោះ?

**ឆះ** បាទ ពីព្រោះដឹងថា គាត់ជាប្រមុខរដ្ឋ។

**សះ** តើប៉ុន្មានដង លោកនៅចាំដែលថាគាត់បានជជែកលេង ឬក៏បានជជែកពិភាក្សាជាមួយលោក ខៀវ សំផន ឬក៏បានស្នើសម្ភារៈ ឧបករណ៍អីពីគាត់នោះ? បានឱកាសប៉ុន្មានដង ដែលលោកបានជជែកជាមួយ?

**ឆះ** បាទ តែម្តងទេ បានសំណេះសំណាលជាមួយគាត់ហ្នឹង។

[១១:៥៩:00]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អរគុណសាក្សី លោក សៅ សារុន ហើយតាមព័ត៌មានព្រឹកមិញ គឺលោកបានប្រាប់មកអង្គជំនុំជម្រះថាលោក តាមសុខភាពរបស់លោកហ្នឹង គឺអាចផ្តល់សក្ខីកម្មសម្រាប់ថ្ងៃនេះតែមួយព្រឹកនេះទេ ហើយនៅរសៀលនេះ គឺតាមលទ្ធភាពសុខភាពរបស់លោក មិនអាចដំណើរការចូលរួមផ្តល់សក្ខីកម្មបានទេ។ អ៊ីចឹងមែនទេ?

**លោក សៅ សារុន៖**

បាទ គឺអ៊ីចឹងមែន ខ្ញុំបានឆ្លើយអ៊ីចឹងមែន។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះលោក សៅ សារុន ដំណើរការពិភាក្សាដេញដោលស្តាប់សក្ខីកម្មរបស់លោកក្នុងនាមលោកជាសាក្សីនៅមិនទាន់ចប់នៅឡើយទេ ហើយដោយសារលោកមានបញ្ហាសុខភាព។ ដូច្នេះ នៅរសៀលនេះ អង្គជំនុំជម្រះមិនបន្តសវនាការដោយការស្តាប់សក្ខីកម្មរបស់លោកទេ។ ការស្តាប់សក្ខីកម្មរបស់លោក អង្គជំនុំជម្រះនឹងបន្តធ្វើនៅថ្ងៃចន្ទ ទី១១ ខែមិថុនា ឆ្នាំ២០១២។ ដូច្នេះ អង្គជំនុំជម្រះកោះអញ្ជើញឲ្យមកផ្តល់ បន្តផ្តល់សក្ខីកម្មនៅថ្ងៃចន្ទ ទី១១ ខែមិថុនា ឆ្នាំ២០១២ ទៀត ដែលនឹងចាប់ផ្តើមដំណើរការពីម៉ោងប្រាំបួនព្រឹក។

ដូច្នេះអង្គជំនុំជម្រះសូមអញ្ជើញមេធាវីប្រឹក្សាសាក្សីមកចូលរួមប្រឹក្សាសាក្សី នៅសវនាការដែលនឹងចាប់ផ្តើមធ្វើនៅថ្ងៃចន្ទ ទី១១ ខែមិថុនា ឆ្នាំ២០១២ និងថ្ងៃបន្តបន្ទាប់។

[១២:00:៤៩]

ហើយមន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការបញ្ជូនលោក សៅ សារុន វិលត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅ និងឲ្យនាំគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញ នៅថ្ងៃចន្ទ ទី១១ ខែមិថុនា ឆ្នាំ២០១២ នៅវេលាម៉ោងប្រាំបួនព្រឹក។

ហើយអង្គជំនុំជម្រះក៏សូមជម្រាបជូនភាគីផងដែរថា កិច្ចដំណើរការសវនាការនៅរសៀលនេះ ហើយយើងនឹងចាប់ផ្តើមបន្តស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-323 ដែលនឹងចាប់ផ្តើមដំបូងដោយតំណាងសហព្រះរាជអាជ្ញា បន្ទាប់ពីសំណួរបឋមដែលនឹងធ្វើឡើងដោយប្រធានសវនាការ។ ហើយដល់ពេលវេលាត្រូវសម្រាកហើយ ដើម្បីពិសារអាហារថ្ងៃត្រង់។ ដូច្នេះអង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសារអាហារថ្ងៃត្រង់ ហើយចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយកន្លះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សូមអញ្ជើញលោកមេធាវី!

[១២:០២:០៥]

**លោក អាកទួរ វែកគែន៖**

បាទ សូមអរគុណលោកប្រធាន។ បាទ ជាការបន្តនៃការបន្តនៃការកត់សម្គាល់របស់ខ្ញុំអម្បាញ់មិញនេះ ខ្ញុំចង់សុំឲ្យអង្គជំនុំជម្រះអនុញ្ញាតផ្តល់ទៅដល់ផ្នែកប្រតិចារឹកនូវវគ្គមួយចំនួននៃខ្សែអាត់ នៃកិច្ចសម្ភាសន៍ដែលធ្វើឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេតទៅលើសាក្សីនេះ។ ហើយយើងបានកត់សម្គាល់ឃើញជាច្រើនកន្លែង គឺថាមិនត្រូវបានធ្វើប្រតិចារឹកនៅក្នុងកំណត់ហេតុស្តាប់ចម្លើយ។ អ៊ីចឹងមានការប្រែប្រួលរវាងខ្សែអាត់ ហើយនិងកំណត់ហេតុស្តាប់ចម្លើយរបស់គាត់។ ហើយនៅ ដោយអនុលោមទៅតាមការ ឯកសារ E142 ខ្ញុំសូមការអនុញ្ញាតផ្តល់វគ្គដែលយើងបានកត់សម្គាល់ឃើញនេះទៅផ្នែកធ្វើប្រតិចារឹក លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

[១២:០៣:១៣]

**លោក ហ្សាស្តើ ប៉ោះ៖**

ខ្ញុំក្រោកឈរឡើងនេះ ដើម្បី-- ហើយយើងពិនិត្យឃើញថា កូនក្តីរបស់ខ្ញុំ សូមអនុញ្ញាតតុលាការ

ដើម្បីតាមដានមកពីបន្ទប់ខាងក្រោមល្ងាចនេះ។ ហើយយើងខ្ញុំនឹងផ្ញើ-- នឹងដាក់ជូននូវលិខិតលះបង់សិទ្ធិក្នុងការចូលរួមនេះ ជូនតុលាការបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បានស្តាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ ស្នើសុំទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយសម្រាប់រយៈពេលពេញមួយរសៀលនេះ ដោយគាត់លះបង់សិទ្ធិចូលរួមផ្ទាល់ក្នុងកិច្ចដំណើរការសវនាការក្នុងបន្ទប់សវនាការនេះ ដោយក្រុមមេធាវីការពារក្តីសន្យាថាខ្លួននឹងប្រគល់មកឲ្យអង្គជំនុំជម្រះនូវលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់របស់ជនជាប់ចោទ។

អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំតាមរយៈមេធាវីការពារក្តីរបស់គាត់ សុំបន្តតាមកិច្ចដំណើរការកិច្ចសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយ ស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយរសៀលនេះ ដោយគាត់លះបង់សិទ្ធិចូលរួមផ្ទាល់ក្នុងកិច្ចដំណើរការសវនាការក្នុងបន្ទប់សវនាការនេះ។

[១២:០៤:៣២]

អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា ប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាមនូវលិខិតលះបង់សិទ្ធិ ចូលរួមសវនាការដោយផ្ទាល់នៅក្នុងបន្ទប់សវនាការរបស់លោក នួន ជា ដោយមានចុះហត្ថលេខា ឬស្នាមផ្តិតស្នាមម្រាមដៃជាក់ច្បាស់ពីជនជាប់ចោទ នួន ជា ផង។

ហើយបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយ ស្ថិតនៅក្រោមសាលសវនាការនេះ ក្នុងរយៈពេលនៃដំណើរការសវនាការពេញមួយរសៀលនេះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់បន្ទប់ខាងក្រោមសាលសវនាការនេះ ដោយនៅរសៀលនេះ។ ដោយនៅរសៀលនេះ ទុកឲ្យលោក នួន ជា នៅក្នុងបន្ទប់ដែលរៀបចំទុកជាស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ ដោយឡែកលោក ខៀវ សំផន ឲ្យនាំខ្លួនគាត់មកកាន់សាលសវនាការនេះវិញឲ្យបានមុនម៉ោងមួយនិងសាមសិបនាទីរសៀល។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៥ នាទី ដល់ម៉ោង ១៣:៣៣ នាទី)*

[១៣:៣៣:២៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

លោកមេធាវីចង់និយាយអីទៅ សូមលោកឲ្យនូវប្រធានបទ ចំណងជើង នៃបញ្ហាដែលលោកចង់និយាយជាមុន ដើម្បីអង្គជំនុំជម្រះសម្រេចថា ឲ្យអនុញ្ញាតលោកនិយាយ ឬមិនឲ្យលោកនិយាយ ពីព្រោះពេលវេលានេះ ត្រូវសួរដេញដោលសក្ខីកម្មរបស់សាក្សីតាមកាលវិភាគដែលបានកំណត់។

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគ្រាន់តែចង់គាំទ្រទៅដល់សំណើសុំដែលធ្វើឡើងដោយ ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីទទួលការកត់ត្រាថតសំឡេងដែលនៅ-- ពីសាក្សីដែលយើងនឹងត្រូវស្តាប់សក្ខីកម្មនេះ។ ហើយខ្ញុំចង់ឃើញនូវប្រតិចារឹកផងដែរ គឺប្រតិចារឹកដែលយើងបាន-- សាក្សីដែលបានស្តាប់កាលពីព្រឹកមិញនេះ។ គឺលោក សៅ សារុន តាមរយៈសក្ខីកម្មរបស់គាត់នេះ គឺយើងបានទៅស្តាប់នូវថតជាខ្សែអាត់សំឡេង កាលពីសក្ខីកម្មកាលពីព្រឹកមិញនេះ។ ដូច្នេះ ប្រសិនណាជា អង្គជំនុំជម្រះអាចផ្តល់ជូននូវប្រតិចារឹកមកជាមួយផងដែរ រួមទាំងការថតសំឡេងនេះ គឺប្រសិនជាលោកអង្គជំនុំជម្រះអាចនឹងផ្តល់ជូនមកយើងខ្ញុំ ក៏ដូចភាគីដទៃទៀត ដើម្បីជាផលប្រយោជន៍នៃការសួរតទល់ជាមួយនឹងសាក្សីផ្សេងទៀត នៅសប្តាហ៍ក្រោយ។

[១៣:៣៥:៤២]

ដូច្នេះ យើងខ្ញុំគាំទ្រទៅដល់សំណើសុំរបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន ដោយស្នើសុំនូវការខ្សែអាត់ថតសំឡេង ក៏ដូចជាប្រតិចារឹកនៃសាក្សីពីព្រឹកមិញនេះ។ ហើយការកត់សម្គាល់ទូទៅផងដែរ គឺថាខ្ញុំចង់ដឹង ថាតើយើងខ្ញុំអាចលើកឡើងនូវទ្ទឹករណ៍ ក៏ដូចជាសារណារបស់យើងខ្ញុំទាក់ទងទៅនឹងសាក្សី មួយចំនួនក្រោយៗមកទៀត។ ដូចថា ខ្ញុំយល់ឃើញថាអង្គជំនុំជម្រះបានជម្រាបមកភាគីទាំងអស់ថា ត្រូវតែដាក់សំណើសុំផ្សេងៗជាលាយលក្ខណ៍អក្សរទាំងអស់។ យើងមិនអាច-- យើងខ្ញុំមិនអាច

លើកឡើងនូវបញ្ហាណាមួយនៅក្នុងបន្ទប់សវនាការបានទេ ដើម្បីជាផលប្រយោជន៍នៃពេលវេលាដល់សាធារណៈ។ ដូច្នេះ គឺភាគីទាំងអស់ត្រូវតែដាក់សំណើសុំជាលាយលក្ខណ៍អក្សរ។ ដូច្នេះ បើសិនណាជាយើងខ្ញុំមានឱកាសលើកឡើងដោយផ្ទាល់មាត់ផងដែរ គឺយើងខ្ញុំចង់ដឹង ថាតើយើងខ្ញុំអាចលើកបាន ឬក៏មិនបាន? សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ត្រឹមត្រូវហើយ យើងបានសម្រេចរួចហើយ ពីព្រោះចៀសវាងនូវភាគីពាក់ព័ន្ធក្នុងរឿងក្តី ឆ្លៀតឱកាសលើកយកនូវបញ្ហាផ្សេងៗ ដែលមិនមែនស្ថិតនៅក្នុងរបៀបវារៈនៃការកំណត់យកមកលើមកធ្វើសវនាការសម្រាប់ពេលវេលានីមួយៗ យកមកធ្វើសេចក្តីថ្លែងការណ៍នៅទីនេះ។

[១៣:៣៧:១២]

អ៊ីចឹង ហើយបានជាយើងកំណត់ឲ្យមានសំណើអីផ្សេងៗ ត្រូវដាក់ជាលាយលក្ខណ៍អក្សរ។ ហើយដើម្បីបញ្ជាក់អំពីបញ្ហាសំណើរបស់លោកអម្បាញ់មិញ ដែលគាំទ្រទៅលើសំណើរបស់មេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន ដែលបានលើកឡើងពីព្រឹកមិញ អង្គជំនុំជម្រះសូមផ្តល់វេទិកា និងភារកិច្ចជូនទៅលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដែលប្រើប្រាស់ភាសាបារាំងដើម្បីឆ្លើយតប និងបញ្ជាក់ជូនដល់មេធាវីអន្តរជាតិទាំងពីរក្រុម។

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកប្រធាន ដើម្បីឆ្លើយតបទៅនឹងសំណើរបស់សហ-- មេធាវីលោក ខៀវ សំផន និងបន្ថែមលើ-- និងបន្ថែមដោយសំណើរបស់ក្រុមមេធាវី នួន ជា អង្គជំនុំជម្រះជម្រាបជូនថាយើងពុំមានការជំទាស់លើជាគោលការណ៍ ដែលថាខ្សែអាត់កិច្ចសម្ភាសន៍ស្តាប់ចម្លើយសាក្សីត្រូវធ្វើជាប្រតិចារឹកនោះទេ ហើយនិងបកប្រែនោះទេ ក៏ប៉ុន្តែអ្វីអង្គជំនុំជម្រះចង់បាននោះ គឺថាសុំឲ្យធ្វើស្នើជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់ឲ្យជាក់លាក់នូវផ្នែកដែលភាគីការពារក្តីចង់ឲ្យធ្វើប្រតិចារឹក ហើយនិងបកប្រែ។ ក៏ប៉ុន្តែទោះបីយ៉ាងក៏ដោយ អង្គជំនុំជម្រះក៏មិនបំបាត់សិទ្ធិឲ្យភាគីធ្វើសុំឲ្យធ្វើប្រតិចារឹកនោះដែរ។ ព្រោះថាមេធាវី ខៀវ សំផន បានស្រង់នូវភាពខុសគ្នាជាច្រើនរវាងប្រតិចារឹក-- រវាងខ្សែអាត់ហើយនិងកំណត់ហេតុស្តាប់ចម្លើយ។

[១៣:៣៨:១១]

ដូច្នេះ ខ្ញុំឆ្លើយតបទៅនឹងសំណើរបស់មេធាវី ខៀវ សំផន ហើយនិងមេធាវី នួន ជា ក្នុងពេលនេះតែមួយតែម្តង។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការ អញ្ជើញសាក្សី TCW-323 ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

[១៣:៣៩:៤៣]

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ ដូចសព្វមួយដង ខ្ញុំក្នុងនាមមេធាវីនាំមុខ សូមជម្រាបជូនលោកប្រធានថា ករណីសាក្សីរូបនេះ គឺមេធាវីនាំមុខសូមអនុញ្ញាតលោកប្រធាន អនុញ្ញាតផ្ទេរសិទ្ធិជូនលោកមេធាវី ឡោ ជុនធី ហើយនិងលោកមេធាវី បាណាបេ ណេគ្វី។ សូមអរគុណលោកប្រធាន។

[១៣:៤១:១៨]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

សួស្តីសាក្សី ហើយមុននឹងតាំងសំណួរ អង្គជំនុំជម្រះសូមសួរសំណួរបឋមមួយចំនួនចំពោះសាក្សី។ ហើយទីមួយ មុននឹងសួរសូមរំឭកបន្ថែមទៀតលើការណែនាំរបស់មន្ត្រីរដ្ឋបាលតុលាការដែលជម្រាបលោកអម្បាញ់មិញថា នៅពេលដែលលោកឆ្លើយតបទៅនឹងសំណួរដែលសួរដោយភាគី ឬក៏អង្គចៅក្រមនៃអង្គជំនុំជម្រះដែលនឹងតាំងសំណួរចំពោះលោក លោកបង្អង់បន្តិចរង់ចាំក្បាលមីក្រូហ្នឹងប្រតិបត្តិការ ដោយមានភ្លើងសញ្ញាក្រហមរបៀបនេះ អាចនៅក្បាលមីក្រូ ឬក៏នៅខាងជើង ខាងក្រោមនេះក៏ដូចគ្នា គឺមានភ្លើងសញ្ញាក្រហម សឹមលោក-- ទើបលោកអាចនិយាយបាន។ ពីព្រោះដើម្បីឲ្យប្រព័ន្ធនៃសំឡេងរបស់លោក ដែលលោកឆ្លើយហ្នឹងចូលក្នុងប្រព័ន្ធនៃការបកប្រែភាសា ដើម្បីឲ្យភាគីដែលពាក់ព័ន្ធទាំងអស់ប្រើប្រាស់បីភាសានៅទីនេះ គេអាចស្តាប់បានទាំងអស់គ្នាណា។

[១៣:៤២:៣០]

**ស៖** សាក្សី តើលោកឈ្មោះអ្វីដែរ?

**លោក ខឹម ងន៖**

**ឆ៖** ខឹម ងន។ ខឹម ងន បង។

**ស៖** លោកចេះអក្សរដែរទេ?

**ឆ៖** អត់បង។ អត់ចេះ។

**ស៖** អត់ចេះទេ។ ចុះអាចសរសេរឈ្មោះខ្លួនឯងបានទេ ឥឡូវ ខឹម ហ្នឹងសរសេរអាម៉េច? ងន សរសេរយ៉ាងម៉េច? លោក ខឹម ងន សូមលោកប្រកបឈ្មោះ ត្រកូលរបស់លោក ខឹម ហើយនិងប្រកបឈ្មោះរបស់លោកផ្ទាល់ គឺ ងន ហ្នឹងសរសេរយ៉ាងម៉េចទៅប្រកបអក្សរយ៉ាងម៉េច?

**ឆ៖** អក្សរ "ខ" អ្នុំង៉េ អក្សរ "ង"ៗ និង "ន"។ "ង" និង "ន" បង។

**ស៖** ចុះ ខឹម?

**ឆ៖** ដាក់ អ្អេស! ភ្លេចហើយបង។ មិនសូវចេះបងអ្អើយ! ខឹម អក្សរ "ខ" "ឹ"។

**ស៖** *(មិនបើកក្បាលមីក្រូហ្វូន)*

**ឆ៖** បាទ។ មិនសូវចេះបង។

**ស៖** "ខ" "ឹ" និង "ម" ខឹម អ៊ីចឹងមែនទេ?

**ឆ៖** ពិតមែនហើយបង។ ចេះតែច្រឡំមើលមិនបានផងនេះ។

**ស៖** លោកធ្លាប់បានរៀនអក្សរដែរទេ ពីដើមកន្លងមកនេះ?

**ឆ៖** អត់បង។ គ្រាន់តែធំចេញទៅបាត់ទៅ អាយុមិនបានប្រាំមួយដណ្ដប់ហ្នឹង។

**ស៖** លោក ខឹម ងន ក្រៅពីឈ្មោះ ងន ដែលលោកប្រើប្រាស់នេះ លោកមានប្រើឈ្មោះអ្វីផ្សេងទៀតដែរឬទេ? ជាពិសេសនៅក្នុងជំនាន់ធ្វើបដិវត្តន៍ឆ្នាំ៧0, ៧៩ នោះ? តើលោកមានប្រើឈ្មោះអ្វីផ្សេងពីឈ្មោះ ងន ហ្នឹងដែរឬទេ?

[១៣:៤៥:១៦]

**ឆ៖** អត់បង ឈ្មោះតែមួយ។

**ស៖** លោក ខឹម ងន តើលោកមានអាយុប៉ុន្មានឆ្នាំហើយ?

**ឆ៖** ៥៧ ហើយបង អាយុ៥៧ ឆ្នាំរកា វាត្រូវប៉ុណ្ណឹងយ៉ាង បើតាមមើល។

**ស៖** តើលោកមានទីលំនៅសព្វថ្ងៃនៅទីកន្លែងណា?

**ឆ៖** នៅស្រុកបូរីជលសារ ឃុំដូងខ្ពស់ ភូមិតាយឹង។

[១៣:៤៥:៥៦]

**ស៖** ខេត្តណាទៅ? ចាំៗបន្តិច! ចាំៗអង់បន្តិច ចាំភ្លើងសញ្ញាក្រហម សឹមឆ្លើយណ៎ា! ខេត្តណា?

**ឆ៖** ខេត្តតាកែវ បង។

**ស៖** លោក ងន តើលោកប្រកបមុខរបររកស៊ីធ្វើអ្វីសព្វថ្ងៃ?

**ឆ៖** សព្វថ្ងៃលក់នំត្នោតបង ហើយនិងរត់ម៉ូតូឌុបនាយអាយ ហើយធ្វើស្រែបន្តិចបន្តួចហ្នឹង។ ឥឡូវអស់ដែរដីស្រែ រលីងហើយ គេយក។

**ស៖** ឪពុកបង្កើតរបស់លោកឈ្មោះអី?

**ឆ៖** អ៊ិត បង អ៊ិត។

**ស៖** ស្អី អ៊ិត ទៅ?

**ឆ៖** ដុក អ៊ិត បង។

**ស៖** *(មិនបើកក្បាលមីក្រូហ្វូន)*

[១៣:៤៦:៤៨]

**ឆ៖** បាទ ដុក អ៊ិត។

**ស៖** ចុះម្តាយបង្កើតរបស់លោកគាត់ឈ្មោះអី?

**ឆ៖** យ៉ង ឃិន។ យ៉ង ឃិន បង។

**ស៖** ចុះប្រពន្ធរបស់លោកឈ្មោះអីដែរ?

**ឆ៖** ជា រុន។ ជា រុន បង។

**ស៖** លោកមានកូនប៉ុន្មាននាក់?

**ឆ៖** កូន១០នាក់បង កូន១០នាក់។

**ស៖** លោក ខឹម ងន តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការ ដែលបានរាយការណ៍អំពីលោកកាលពីម្សិលមិញ ហើយនិងព្រឹកមិញនេះថា តាមសមត្ថភាពដែលលោកអាចដឹង គឺលោកមិនមានញាតិលោហិត ឬក៏ញាតិពន្ធ ដូចជាឪពុកម្តាយ កូន បច្ឆាញាតិ បងប្អូនប្រុសស្រី បងប្អូនថ្លៃ ប្រពន្ធ ជាមួយនឹងភាគីដើមបណ្តឹងរដ្ឋប្បវេណី ក៏ដូចជាជនជាប់ចោទទាំងបីរូប នួន ជា, អៀង សារី, ខៀវ សំផន ទេ។ តើជាការពិតមែនដែរទេ?

[១៣:៤៨:១៤]

**ឆ៖** អត់ទេបង អត់មាន។

**ស៖** តើលោកបានស្បថហើយឬនៅមុនពេលចូលមកផ្តល់សក្ខីកម្មនេះ?

**ឆ៖** ស្បថហើយបង។

**ស៖** លោក ខឹម ងន ក្នុងនាមលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះនាពេលនេះ លោកមានសិទ្ធិបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬក៏ការស្នើសុំឲ្យលោកធ្វើសេចក្តីអត្ថាធិប្បាយណាមួយ ឬច្រើន ដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង មានន័យថា ដោយសារតែចម្លើយ ឬក៏អំណះអំណាងរបស់លោកនោះ នាំឲ្យលោកនឹងត្រូវទទួលរងការចោទប្រកាន់។ ហើយទន្ទឹមនឹងនេះដែរ គឺក្នុងនាមលោកជាសាក្សី លោកក៏មានករណីកិច្ចក្នុងកិច្ចដំណើរការសវនាការចំពោះមុខអង្គជំនុំជម្រះនេះ គឺត្រូវតែឆ្លើយតបទៅនឹងរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះតាំងសំណួរសួរលោក។ លើកលែងតែក្នុងករណី ការឆ្លើយតបនឹងសំណួរ ឬការធ្វើអត្ថាធិប្បាយណាមួយដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងប្រាប់លោកអម្បាញ់មិញនេះ។ ហើយលោកជាសាក្សីត្រូវតែការណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ មានបទពិសោធន៍ផ្ទាល់ ឬក៏បានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរ ដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរលោក។ តើលោកយល់ដែរឬទេ?

[១៣:៥០:០៨]

**ឆ៖** យល់បង។

**ស៖** ហើយឥឡូវនេះគឺលោកបានទទួលយកនូវមេធាវីប្រឹក្សាសាក្សីហើយ តាមការរៀបចំដោយអង្គជំនុំជម្រះជាមួយនឹង សហការជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញ។ ហើយជាបន្តនេះអង្គជំនុំជម្រះ សូមសួរលោកថា ដោយមានព័ត៌មានអម្បាញ់មិញនេះឃើញថា លោកមិនចេះអក្សរទេ។ អង្គជំនុំជម្រះសួរថា តើលោក ខឹម ងន កន្លងមកនេះមានដែលជួបធ្វើបទសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតទេ កាលពីឆ្នាំ ប៉ុន្មានឆ្នាំកន្លងទៅនេះ? ហើយប្រសិនដែលធ្វើ គឺធ្វើប៉ុន្មានដងដែរ?

[១៣:៥១:០៦]

**ឆ៖** ធ្វើបីដងបង។ ធ្វើបីដង។

**ស៖** លោកចាំទេថា ធ្វើបីដងហ្នឹងធ្វើនៅក្នុងឆ្នាំណា? ហើយនៅទីកន្លែងណា?

**ឆ៖** រយៈពេលដូចបីឆ្នាំហើយបង ធ្វើអប់រំនៅសាលារៀនណា៎ា សាលារៀនដូងខ្ពស់ សាលាវិទ្យាល័យដូងខ្ពស់។

**ស៖** បាទ អរគុណ។ ចុះមុនពេលដែលលោក ងន ចូលមកផ្តល់សក្ខីកម្មនាពេលនេះ តើលោកមានដែលត្រូវបានអ្នកណាមួយអាននូវកំណត់ហេតុនៃការ កិច្ចសម្ភាសន៍របស់លោក ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យស៊ើបអង្កេត ដើម្បីរំឭកការចងចាំដែរឬទេ?

**ឆ៖** បងទេវីគាត់ប្រាប់មើលឲ្យស្តាប់ពីម្សិលមិញដែរ។ គាត់ណែនាំម្សិលមិញដែរ មើលអាក្នុងនេះនោះណ៎ាបងណ៎ា។ ហើយៗ ឲ្យរំឭក។ ហើយធ្វើម៉េចបើវាមានភ្លេចភ្លាំងខ្លះបង មិនខានទេ វាភ័យដែរ។

**ស៖** ហើយតាមការដែល-- សមត្ថភាពដែលលោកៗអាចដឹងបាន តើក្រោយពេលដែលលោកស្តាប់ចុងក្រោយនេះ ហើយប្រៀបធៀបជាមួយនឹងការដែលលោកធ្វើសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតកាលពីលោកថាបីឆ្នាំមុន ពីរឬបីឆ្នាំមុននេះ តើវាមានភាពខុសគ្នាទេ ឬក៏វាស្របគ្នាទៅលើខ្លឹមសារនៃការធ្វើសម្ភាសន៍?

[១៣:៥២:៤៦]

**ឆ៖** ដូចតែគ្នាបង គាត់ណែនាំក៏ដូចអាខ្ញុំឆ្លើយនៅសាលាវិទ្យាល័យហ្នឹងដែរបងណ៎ា។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ជាកិច្ចបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីតាំងសំណួរដេញដោលចំពោះសាក្សី។ ហើយសូមរំឭកដែរថា សាក្សីរូបនេះបានឆ្លើយបញ្ជាក់ច្បាស់ហើយថាខ្លួនគាត់ហ្នឹងមិនចេះអក្សរទេ។ អ៊ីចឹងក្នុងការបង្ហាញភស្តុតាងជាឯកសារផ្សេងៗ សូមគប្បីប្រព្រឹត្តទៅឲ្យបានសមស្របទៅនឹងស្ថានភាពជាក់ស្តែង នៃកម្រិតសមត្ថភាពយល់ដឹងអំពីអក្សរសាស្ត្រនេះចំពោះសាក្សីផង។

សូមអញ្ជើញ!

**លោក ច័ន្ទ តារាស្មី៖**

បាទសូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម។ សូមគោរពលោក លោកស្រីទាំងអស់ដែលមានវត្តមាននៅក្នុងពេលសវនាការនៅពេលនេះ។

[១៣:៥៤:១៥]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ច័ន្ទ តារាវស្នី៖**

**ស៖** សួស្តីលោក ខឹម ងន។ ខ្ញុំឈ្មោះ ច័ន្ទ តារាវស្នី ជាសហព្រះរាជអាជ្ញារងជាតិ នៃសាលាក្តីនេះបាទ។ នៅពេលនេះខ្ញុំសូមអនុញ្ញាតជម្រាបសួរលោកទាក់ទិននឹងសំណួរមួយចំនួន ដែលខ្ញុំមានបំណងសូមឲ្យលោកឆ្លើយ។ ជាដំបូងនេះគឺខ្ញុំសូមសួរលោកទាក់ទិនទៅនឹងប្រវត្តិផ្ទាល់ខ្លួនលោក នាអំឡុងពេលមុនឆ្នាំ១៩៧៥។ សំណួរទីមួយដែលខ្ញុំនឹងសូមចាប់ផ្តើមនៅពេលនេះគឺ ខ្ញុំសូមសួរលោកថា តើនៅមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ តើលោកមានមុខរបរធ្វើអ្វីដែរបាទ?

**លោក ខឹម ងន៖**

**ឆ៖** អង្កាល់ហ្នឹងខ្ញុំធ្វើស្រែលោកបង។ ធ្វើស្រែ មុខរបររកស៊ីធ្វើស្រែ រត់ម៉ូតូនេះឯង កាលហ្នឹង។

**ស៖** បាទ អរគុណ។ តើលោកមានទីលំនៅនៅទីណាដែរ នៅមុនថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥?

[១៣:៥៥:០០]

**ឆ៖** អង្កាល់ហ្នឹង ខ្ញុំនៅភូមិតាយឹង បង ភូមិតាយឹង ដូងខ្ពស់ អ៎ ភូមិតាយឹង-- កាលហ្នឹងគេដាក់ស្រុកនៅបូរីជលសារ ឥឡូវគេដាក់ស្រុក*(ឮមិនច្បាស់)* ឥឡូវនេះ គេដាក់*(ឮមិនច្បាស់)* កាលពីសម័យហ្នឹងគេដាក់ កោះអណ្តែត។

**ស៖** នៅក្នុងខេត្តតាកែវបាទ?

**ឆ៖** បាទ តាកែវ។

**ស៖** អរគុណ។ តើលោករៀនដល់ថ្នាក់ណាដែរបាទ?

[១៣:៥៥:៣០]

**ឆ៖** ខ្ញុំអត់បានរៀនទេលោកបង។ គ្រាន់តែអាយុប្រហែលប្រាំប្រាំមួយដណ្តប់ គេបបួលទៅធ្វើទាហានហ្នឹងគេទៅអង្កាល់ហ្នឹង ចេញទៅពីផ្ទះហ្នឹងគេទៅ។

**ស៖** អរគុណ។ តើលោកបានចូលរួមចលនាបដិវត្តន៍ដែរឬទេ?

**ឆ៖** អង្កាល់ហ្នឹង ខ្ញុំមើលចេញពីផ្ទះ គេហៅទៅ វាធ្វើបដិវត្តន៍ហ្នឹងគេហៅខ្ញុំទៅ នៅក្នុងភូមិទេបងណា ទៅធ្វើនៅកាលនៅវានៅទ័ពស្រុក អ៎ មុនដំបូងធ្វើនៅនៃភូមិ ឈ្លបភូមិ ហើយគេដាក់បញ្ជូនទៅ

ស្រុកនៅទ័ពស្រុក។ ធ្វើទ័ពស្រុកបានប៉ុន្មានខែ ក៏គេឲ្យគេចាត់តាំងខ្ញុំមកនៅខាងក្រោយបងណ៎ា គេឲ្យចាត់តាំងខ្ញុំមកខាងក្រោយវិញ។ ខ្ញុំក៏កាលហ្នឹង កាលហ្នឹងគេអើ គេឲ្យខ្ញុំធ្វើប្រធានក្រុមដែរ អង្កាល់ហ្នឹង លោកបងណ៎ា គេឲ្យធ្វើប្រធានក្រុម ហើយគេដកខ្ញុំមករត់សំបុត្រនីរសារ ពីឃុំមកភូមិ ពីភូមិមកស្រុក អ៊ីចឹងណ៎ាអង្កាល់ហ្នឹងណ៎ា ព្រោះខ្ញុំកាលនោះនៅក្មេងដែរនោះ។ ម្ល៉ោះហើយអ៊ីចឹងហើយគេដកខ្ញុំមកនៅកន្លែងមន្ទីរស្រុកវិញ។ ដល់រយៈពេលបានប៉ុន្មានខែ គេដកខ្ញុំមកនៅធន់មន់ ខាងកើតតាកែវទៀត ខេត្តតាកែវរួមខេត្តបងណ៎ា គេឲ្យខ្ញុំនៅធ្វើការហ្នឹងដែរ។ កាលហ្នឹង ខ្ញុំ*(ឮមិនច្បាស់)* ប្រធានក្រុមដែរកាលហ្នឹង។ ដល់ហើយគេដកខ្ញុំមកដល់បែកតាកែវហើយក្នុងឆ្នាំ៧៥នេះ គេដកខ្ញុំមកភ្នំពេញវិញកាលហ្នឹងបងណ៎ា ក្នុងវង្វង់៧៥ហ្នឹងណ៎ា បានបែកទីក្រុងអស់រលីងណ៎ា។ គេដកពីភូមិភាគនែ៎ ភូមិភាគនិរតីគេដកមក៦នាក់ពួកខ្ញុំហ្នឹង ប៉ុន្តែឥឡូវគេមិនដឹងទៅណាអស់ បែកអង្កាល់មីត-- អង្កាល់លពេលយួនបុកចូល វាមីតរតាត់រតាយមិនដឹងនរណាផ្លាយឯណា នៅតែខ្ញុំទៅ មិនដឹងនៅឯណា ហើយឲ្យខ្ញុំនេះទៅនៅស្ថានទូតចិន គេចាត់ខ្ញុំអង្កាល់ហ្នឹង។ ពិបាកណាស់អង្កាល់ វាមិនទាន់អស់ កាលមករៀនសាលាបច្ចេកទេសសូវៀត ខាងកើតពោធិ៍ចិនតុង កាលហ្នឹងគេមានសាលាបង្វឹកមួយអង្កាល់ហ្នឹងអ្ហា អើគេដកខ្ញុំឲ្យរៀនហ្នឹងបានមួយអាទិត្យ ហើយបានឲ្យចុះទៅតាមក្រសួងការបរទេស ដកកម្លាំងខ្ញុំឲ្យទៅនៅតាមក្រសួងការបរទេស។ ខ្ញុំនៅហ្នឹងបានប៉ុន្មាន ហើយវៀតណាមបុកចូលទៅ វារតាត់រតាយទៅ។ ហើយឆ្លើយមិនទាន់អស់ពាក្យផង វារាងភ្លេចភ្លាំងច្រើនដែរ ធ្វើម៉េចបើមិនសូវ-- វារៀនតិចផង។

[១៣:៥៨:១៥]

**ស៖** អរគុណលោក ខឹម ងន។ លោកចាំបានទេ តើពេលនោះលោកមានអាយុប៉ុន្មានបាទ?

**ឆ៖** ខ្ញុំកាលនោះ ដូចចេញពីផ្ទះដូចអាយុប្រាំមួយដណ្តប់ ប្រាំពីរដណ្តប់ ឬក៏ប្រាំដណ្តប់អីមិនដឹងទេ វានៅក្មេងពួកម៉ាកគេហៅទៅ ទៅនឹងគេទៅប្រុយទៅបង។

**ស៖** តើលោកចូលធ្វើកងទ័ពហ្នឹង ដោយស្ម័គ្រចិត្ត ឬក៏ដោយមានការបង្ខិតបង្ខំ ឬក៏ដោយមានមូលហេតុអ្វីផ្សេងទៀតបាទ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

ចាំៗរង់ចាំបន្តិចសិន! បង្អង់បន្តិចណ៎ា! ចាំមើលភ្លើងប្រតិបត្តិការនៃក្បាលមីក្រូសិនណ៎ា កាលណាមានប្រតិបត្តិការ គឺមានភ្លើងសញ្ញាក្រហមនៅហ្នឹងណា សឹមនិយាយ។ ហើយច្បាប់តុលាការគេថា

សួរអីឆ្លើយហ្នឹង សួរឆ្លើយត្រឹមកម្រិតដែលសំណួរគេសួរបានហើយ។ ន៎ែ ចាំស្តាប់សំណួរ ហើយសួរឆ្លើយត្រឹមតែកម្រិតពាក់ព័ន្ធនឹងសំណួរ ដែលសួរបានហើយ។

**សួរដោយលោក ច័ន្ទ តារាវស្នី៖**

**ស៖** លោក ខឹម ងន ខ្ញុំសូមឲ្យលោកជួយបញ្ជាក់បន្ថែមថា តើមានមូលហេតុអ្វីបានជាលោកចូលបម្រើក្នុងជួរកងទ័ព?

**លោក ខឹម ងន៖**

**ឆ៖** អង្កាល់ហ្នឹងមានពួកម៉ាកគេហៅទៅលោកបង។ គេហៅថា តោះទៅធ្វើទ័ពជាមួយអញអ៊ំ្អា ហើយខ្ញុំក៏បានស្ម័គ្រចិត្តទៅជាមួយនឹងគេទៅ។ ដល់ទៅដើរជាមួយគេហ្នឹងទៅបានរយៈពេល អាហ្នឹងក៏ម៉ែមិនដឹងទៀត ម៉ែមឹតទៅស្រុកលើៗនោះ ខ្ញុំមកភូមិវិញ គេហៅចូល ចូលនឹងគេទៅ។

[១៤:00:00]

ស៖ អរគុណ។ លោក ខឹម ងន តើការចូលបម្រើកងទ័ពក្នុងបំណងអី? កាលនុ៎ងគេបង្កើតកងទ័ព តើបង្កើតកងទ័ពហ្នឹងក្នុងគោលបំណងអី? តើលោកមានបានដឹងអំពីមុលហេតុនៃការបង្កើតកងទ័ពនៅសម័យនុ៎ងទេបាទ មុនឆ្នាំ១៩៧៥?

**ឆ៖** អង្កាល់គេហៅខ្ញុំចូលបង គឺចំពោះខ្លួនខ្ញុំក៏មិនដឹងដូចថា រំដោះរឿងអីក៏មិនដឹង បែបចូលតាមនឹកឃើញអង្កាល់ហ្នឹងដូចសប្បាយនឹងគេទៅនឹងគេទៅ។ ដល់ពេលនេះទៅគេមានណែនាំខ្លះអីចឹងដែរណាបងណ៎ា។

**ស៖** លោក ខឹម ងន មានដែលឮពាក្យ “បដិវត្តន៍” ទេ គេប្រើពាក្យ “បដិវត្តន៍” ទេនៅមុនឆ្នាំ១៩៧៥ហ្នឹង? តើពាក្យ “បដិវត្តន៍” ហ្នឹង លោកធ្លាប់ឮគេនិយាយប្រាប់ មានន័យដូចម្តេច ពាក្យ “បដិវត្តន៍” ហ្នឹងបាទ?

**ឆ៖** អាពាក្យ “បដិវត្តន៍” ហ្នឹងគេថា ន៎ែ ដូចថាយើង គេថារំដោះអ្នកក្រយ៉ាងម៉េចទេ ខ្ញុំឮសួរគេនិយាយបង។ ខ្ញុំក៏វាមិនសូវយល់ដែរមិនសូវយល់ ប៉ុន្តែវាមិនសូវយល់ចេះតែទៅតាមគេតាមឯងទៅ។ ហើយខ្ញុំអាពាក្យ “បដិវត្តន៍” ខ្ញុំមិនសូវយល់អង្កាល់ហ្នឹង។

**ស៖** អរគុណលោក ខឹម ងន។ តើលោកដែលឮពាក្យថា “ខ្មែរក្រហម” ទេបាទ? ពាក្យ “ខ្មែរក្រហម" ហ្នឹងមានន័យដូចម្តេច?

[១៤:០១:២២]

**ឆ៖** ពាក្យ "ខ្មែរក្រហម" ហ្នឹង-- អេស! ពិបាកៗថា ខ្ញុំមិនដឹងទៀតពាក្យ "ខ្មែរក្រហម" ហ្នឹង។ ខ្ញុំក៏មិនសូវដឹងទេ ចូលទៅធ្វើនឹងគេមិនសូវដឹងទេបង។

**ស៖** អរគុណ។ តើពាក្យ "បក្សកុម្មុយនីស្តកម្ពុជា" លោកដែលឮដែរឬទេ នៅសម័យមុនឆ្នាំ ១៩៧៥?

**ឆ៖** មានឮដែរបង "បក្សកុម្មុយនីស្តកម្ពុជា" ឮសូរមានគេនិយាយដែរ ប៉ុន្តែទោះគេនិយាយ ចំពោះខ្លួនខ្ញុំក៏មិនបានយល់ដឹងថា "បក្សកុម្មុយនីស្តកម្ពុជា" ហ្នឹង ទៅមុខទៀតហ្នឹងទៅមុខម៉េចខ្ញុំអត់បានដឹង អត់បានយល់បងណ៎ា។ វាអត់សូវចេះ មិនសូវបានយល់។

**ស៖** ក្រោយពីបានចូលរួមជាមួយចលនាបដិវត្តន៍ នៅមុនឆ្នាំ១៩៧៥ តើលោកមានធ្លាប់គេបង្រៀនលោកវគ្គបណ្តុះបណ្តាលនយោបាយ ឬក៏បំពាក់បំប៉នគោលនយោបាយអ្វីមួយដែរឬទេបាទ?

[១៤:០២:៣០]

**ឆ៖** មានដែរបង មានដែរ មានគេបំពាក់បំប៉ននយោបាយដែរ ដូចឈ្មោះគេ អាឆយ អ៊ីចឹង ដូចគេប្រធានទ័ព គេបំពាក់បំប៉ននយោបាយអង្គាល់ហ្នឹងណ៎ា។ ណាមួយខ្ញុំ បំពាក់បំប៉ននយោបាយ យើងនៅក្មេងជាងគេ ចេះតែអ៊ឹៗ ប៉ុន្តែរឿងឲ្យខ្ញុំទៅនៅណា ក៏ខ្ញុំមិនប៊ានដើរដែរ ព្រោះខ្ញុំនៅក្មេង ត្រឹមតែរត់តែនីរសារ គេបំពាក់បំប៉នហៅទៅប្រជុំទៅ តែ បងឆយ ហ្នឹងគេអ្នកហៅប្រជុំ។ អស់ប៉ុណ្ណឹងបង។

**ស៖** ខ្លឹមសារនៃការប្រជុំនៅក្នុងការបង្រៀនវគ្គនយោបាយហ្នឹង តើផ្តោតទៅលើអ្វីខ្លះ? គេរៀបរាប់ គេពន្យល់លោកពីបញ្ហាអ្វីខ្លះ?

**ឆ៖** គេបំពាក់បំប៉ននយោបាយ នែ៎! គេថា ឧទាហរណ៍ គេនៅជាមួយនឹងភ្ញៀវ គេថាមិនឲ្យនិយាយ ហើយបើបាយអីសល់ ទឹកក្រូចសល់ ក៏គេមិនឲ្យខ្ញុំផឹកដែរ។ អាហ្នឹងប៉ុណ្ណឹងបងណ៎ា។

**ស៖** បាទ នៅមុនឆ្នាំ១៩៧៥ ហ្នឹង អំឡុងមុនពេលឆ្នាំ១៩៧៥ហ្នឹង លោកបានទទួលការវគ្គបណ្តុះបណ្តាលច្រើនដងដែរឬទេ? ហើយបើសិនជាមានរយៈពេលនៃការបណ្តុះបណ្តាលហ្នឹងប្រើពេលប៉ុន្មានថ្ងៃ ឬក៏ប៉ុន្មានអាទិត្យបាទ? ហើយនៅកន្លែងណា ការបណ្តុះបណ្តាលហ្នឹងបាទ?

[១៤:០៤:០០]

**ឆ៖** អាហ្នឹងនិយាយអង្គាល់ពីនៅស្រុក នៅប្រជុំនៅត្រពាំងទន្លេដែរ អាហ្នឹង ពីរបីដងហើយ គេអ្នកធំៗ អាហ្នឹងខ្ញុំក៏អត់ដែរបានចូលរួមនឹងគេដែរ។ ហើយដល់ពេលមកនៅនេះទៀតក៏ខ្ញុំបានត្រឹមតែនាយអាយនឹងគេបង នៅចំពោះឲ្យខ្ញុំចូលរួមជាមួយអ្នកធំ ជាមួយអ្នកអីអត់បានចូលរួមនឹងគេទេ ព្រោះ

វា-- អើ! គេហៅតែពួកសម្ព័ន្ធយុវកក និងបក្ខជន អង្កាល់ហ្នឹងគេមានហៅ ខ្ញុំបងណ៎ា។ ហ្នឹងគេមានហៅ បក្ខជន តែសម្ព័ន្ធយុវកក តែបើយើងយុទ្ធជន គេគ្រាន់តែដាក់យើង*(ឮមិនច្បាស់)* ក៏គេមិនហៅយើងទៅចូលប្រជុំដែរ យើងបានមកបម្រើគេក្រៅជាមួយភ្ញៀវហ្នឹងណា ហ្នឹងចំណែកខ្ញុំ។ តែប៉ុណ្ណឹង។

**ស៖** បាទ អរគុណ។ សម្ព័ន្ធយុវកកដែលលោកមានប្រសាសន៍អម្បាញ់មិញហ្នឹង ចង់និយាយថាម៉េច? មានន័យដូចម្តេចបាទ?

**ឆ៖** អាហ្នឹងជាសម្ព័ន្ធយុវកក អង្កាល់ហ្នឹង សម័យហ្នឹងគេហៅថាក្រុមស្នូលរបស់គេលោកបងណ៎ា។ ក្រុមស្នូល ក្រុមកម្លាំងពិតរបស់គេ។

[១៤:០៥:០០]

**ស៖** ហេតុអីបានជាគេបង្កើតក្រុមស្នូលនេះកើតឡើង?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

ឈប់សិន! លោក ងន ម្តងទៀត លោក ងន ចាំ រង់ចាំបង្អង់បន្តិចណ៎ា ចាំភ្លើងក្រហមមាននៅនឹងឧបករណ៍មីក្រូនិយាយ សឹមចាប់ផ្តើមនិយាយណ៎ា។ ហើយនិយាយមួយៗបានហើយ និយាយយឺតដើម្បីឱ្យអ្នកបកប្រែហ្នឹង អាចបកប្រែភាសាបាន ព្រោះលោកប្រើភាសាសាមញ្ញច្រើន ប៉ុន្តែបើនិយាយញាប់ ហើយមិនច្បាស់លាស់ នាំឱ្យការបកប្រែហ្នឹងមានការភ័ន្តច្រឡំ ឬក៏បកប្រែមិនអស់ទៅ សេចក្តីទៅនាំមានបញ្ហាកើតឡើង។

ឥឡូវមានបញ្ហាបកប្រែ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងអង្គភាពបកប្រែដើម្បីពិនិត្យលើបញ្ហាបកប្រែភាសា!

[១៤:០៦:២១]

សូមអញ្ជើញបន្ត តំណាងសហព្រះរាជអាជ្ញា!

*(មានបញ្ហាបច្ចេកទេសបកប្រែ)*

**លោក ច័ន្ទ តារាស្មី៖**

អរគុណលោកប្រធាន។ ខ្ញុំសូមអនុញ្ញាតបន្តទៅទៀតបាទ។

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** លោក ខឹម ងន ខ្ញុំសូមសួរលោកបន្តទៀត។

**ប្រធានអង្គជំនុំ៖**

បាទទេ ឥឡូវខ្ញុំលេងសុទ្ធអង់គ្លេសវិញហើយនេះ មកចេញអង់គ្លេសវិញ ហើយខ្មែរផ្សេងទៀតឃើញសើចៗ ប្រហែលជាអង់គ្លេសដូចខ្ញុំដែលមើលទៅ។

*(មីក្រូហ្វូនមិនទាន់ដំណើរការ)*

[១៤:០៧:១១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ តំណាងសហព្រះរាជអាជ្ញាជាតិ!

**លោក ច័ន្ទ តារាស្មី៖**

បាទ សូមអរគុណលោកប្រធាន ខ្ញុំសូមអនុញ្ញាតសួរបន្តទៀតបាទ។

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** លោក ខឹម ងន ខ្ញុំសូមសួរលោកបន្តទៀត។ នៅពេលដែលលោកចូលរួមជាមួយនឹងចលនាបដិវត្តន៍ នៅមុនឆ្នាំ១៩៧៥ តើមានគេតម្រូវឲ្យលោកសរសេរប្រវត្តិរូបផ្ទាល់ខ្លួនរបស់លោកដែរឬទេ?

**លោក ខឹម ងន៖**

**ឆ៖** អង្កាល់ហ្នឹងមានបងមាន កាលហ្នឹងគេឲ្យខ្ញុំសរសេរប្រវត្តិរូប កាលដែលខ្ញុំនៅជាមួយភៀរហ្នឹងណ៎ា។ គេឲ្យខ្ញុំសរសេរប្រវត្តិក្នុងមួយថ្ងៃបីដង។ ខ្ញុំលើកទីមួយ ខ្ញុំសរសេរឲ្យគេ ប៉ុនឲ្យរកអ្នកគេសរសេរឲ្យណ៎ា ឧទាហរណ៍កន្លែងហៅ ដូចពួកម៉ាកកន្លែងស្ងាត់ហ្នឹង ឲ្យគេសរសេរឲ្យស្ងាត់បន្តិចទៅឲ្យគេសរសេរឲ្យ។ ដល់ពេលសរសេរឲ្យលើកទីពីរ គេថាខុស។ ដូច្នេះលើកទីមួយក៏ខុស លើកទីពីរក៏ខុស ដល់លើកទីបី យកឲ្យវាៗថា វាៗស្ងាត់ បាត់រហូតដល់ឥឡូវហ្នឹង។

[១៤:០៨:០២]

**ស៖** បាទ ខ្លឹមសារសំខាន់នៅក្នុងប្រវត្តិរូបហ្នឹង គេផ្តោតទៅលើខ្លឹមសារអ្វីខ្លះ លោកអាចបញ្ជាក់បានទេបាទ?

**ឆ៖** ខ្ញុំយល់ឃើញអ៊ីចេះទេបង បានវាធ្វើប្រវត្តិរូបក្នុងមួយថ្ងៃបីដង ក្រែងលោវាម្យ៉ាងក្រែងបងប្អូនខ្ញុំនៅភូមិកំណើតហ្នឹង ក្រែងមានគេចាប់ គេចងយកវៃចោលណ៎ា។ បានគេថា គេធ្វើប្រវត្តិរូបខ្ញុំនេះព្រោះខ្ញុំនេះជាប់ខ្សែបណ្តាញរបស់គេមក ក្រែងឲ្យធ្វើកន្លែងហ្នឹងខ្លាំង។ ហើយដល់ហើយទៅ ដល់ពេលខ្ញុំមឹតទៅវិញ ទៅផ្ទះវិញ ហើយមែន។ គេវៃចោលបងខ្ញុំ និងជីដូនមួយខ្ញុំហ្នឹង។ បានជាគេសួរប្រវត្តិរូប

ចំពោះខ្លួនខ្ញុំបីដងហ្នឹង ហ្នឹងខ្ញុំក៏ចាប់អារម្មណ៍ខ្ញុំដែរ។ នឹងឃើញចាប់អារម្មណ៍ក្នុងខ្លួនខ្ញុំដែរណ៎ា ព្រោះធ្វើប្រវត្តិរូបក្នុងមួយថ្ងៃបីដងហើយ ចាប់អារម្មណ៍នឹកឃើញបងប្អូនមកពីនោះមក ពីភូមិកំណើតនោះ។

[១៤:០៩:00]

**ស៖** អរគុណលោក ខឹម ងន ក្រោយមក ក្រោយពេលដែលលោកចូលរួមក្នុងចលនាបដិវត្តន៍ហើយ តើលោកបានក្លាយជាសមាជិកនៅក្នុងសម្ព័ន្ធយុវជនបក្សបដិវត្តន៍ដែរឬទេ នៅអំឡុងមុនឆ្នាំ១៩៧៥?

**ឆ៖** អត់ទេបង ខ្ញុំត្រឹមតែៗយុទ្ធជន អត់មានធ្វើនេះអីអត់មានទេ ត្រឹមតែយុទ្ធជន កាលហ្នឹង។ អត់មានទេ។

**ស៖** តើលោកធ្លាប់បានក្លាយជាសមាជិកបក្សកុម្មុយនីស្តកម្ពុជាដែរឬទេ?

**ឆ៖** អត់ទេបង អត់ទេ រឿងនេះហ្នឹងអត់ទេ។ ព្រោះត្រឹមបានធ្វើដូច*(ឮមិនច្បាស់)* អំមិញហ្នឹងថាវាជាន់ដាន ថាត្រឹមបានអំមិញហ្នឹង។

**ស៖** ក្រោយពេលដែលលោកចូលរួមជាមួយនឹងបដិវត្តន៍ តើលោកធ្លាប់ទទួលនូវការបង្គំឲ្យអនុវត្តតាមវិន័យរបស់បក្សកុម្មុយនីស្តកម្ពុជាដែរឬទេ?

**ឆ៖** អង្កាល់ហ្នឹង តាមគេដែរបង អង្កាល់ហ្នឹង គេ *(ឮមិនច្បាស់)* គេឲ្យមានអ្នកដឹកនាំខ្លះដែរ ប៉ុន្តែខ្ញុំវាយុវជន មិនឡើងដល់សម្ព័ន្ធយុវកក អត់មានគេទេ។ បើពិត គេមិនបានពិតដូចគេ អត់មានទេបង គ្មានទេ។

**ស៖** បាទ លោកដែលឮ គេនិយាយអំពីវិន័យរបស់បក្សកុម្មុយនីស្តកម្ពុជាដែរឬទេ? ហើយវិន័យហ្នឹងមានន័យដូចម្តេច?

**ឆ៖** ខ្ញុំបានឮគេណែនាំអីចឹងដែរ រឿងវិន័យហ្នឹង តាំងវិន័យខាងសីលធម៌ ដល់អី ពេញទឹកពេញដី ខុសអី ខាងសីលធម៌ ខុសអីហ្នឹង បេះម្ទេសគេហ្នឹង គឺគេចេះតែហាម គេប្រជុំ គេប្រាប់ទៅណាបង។ ប៉ុណ្ណឹងបាន។

**ស៖** ចំពោះវិធានស្តីពីឥរិយាបថនៅក្នុងពេលដែលលោកធ្វើជាកងយោធានៅស្រុកកោះអណ្តែត តើវិធានស្តីពីឥរិយាបថហ្នឹងមានន័យដូចម្តេច? ផ្តោតទៅលើអ្វីជាសំខាន់បាទ?

[១៤:១១:១១]

**ឆ៖** អង្កាល់ហ្នឹង ខ្ញុំធ្វើប្រធានក្រុម ប៉ុន្តែគេយកខ្ញុំទៅធ្វើនៅឈរជើងនៅហ្នឹង ប៉ុន្តែដល់ហើយខ្ញុំក៏មិនប៊ានបញ្ជាគេដូចតែគ្នា ពីព្រោះយុទ្ធជនដូចតែគ្នា ន៎ែ!ក្រែងអ្នកបញ្ជាមក ឲ្យឃើញអ្នកបញ្ជាមក

ថា ឲ្យត្រៀមកន្លែងនេះ នៅកន្លែងនេះ។ ហ្នឹងគេមានហៅប្រជុំ តែប៉ុណ្ណឹងបង។

**ស៖** តើលោកអាចបញ្ជាក់បានទេ វិន័យរបស់បក្សកុម្មុយនីស្តកម្ពុជា។ តើវិន័យរបស់បក្សកុម្មុយនីស្តកម្ពុជាហ្នឹងមានលក្ខណៈតឹងតែង តឹងរ៉ឹងទៅលើចំណុចណាខ្លះ ដែលលោកគិតថាលំបាកក្នុងការអនុវត្ត ឬក៏មានបញ្ហាផ្សេងទៀត ដែលគេគិតថាវិន័យហ្នឹងមានបញ្ហាធ្ងន់ធ្ងរចំពោះសមាជិកនៃបក្សកុម្មុយនីស្តកម្ពុជា?

**ឆ៖** ខ្ញុំ វិន័យ បើតាមខ្ញុំយល់ តាមនេះ តាមមើលវិន័យលើនេះ ខ្ញុំក៏មិនសូវយល់ដែលបងនិយាយមួយម៉ាត់ឲ្យខ្លី មិនសូវយល់តែម្តង មិនសូវចេះខ្ញុំ មិនសូវយល់ បានតែធ្វើ មិនសូវយល់។

**ស៖** អរគុណ។ តើលោកបានដឹងទេថា អ្នកណាបង្គាប់ឲ្យគេអនុវត្តវិន័យរបស់បក្សកុម្មុយនីស្តកម្ពុជា? តើបុគ្គលណាជាអ្នកបង្គាប់ឲ្យអនុវត្តតាមវិន័យរបស់បក្សកុម្មុយនីស្តកម្ពុជា នៅមុនអំឡុងឆ្នាំ ១៩៧៥?

**ឆ៖** អង្កាល់ខ្ញុំធ្វើហ្នឹង អ្នកនិយាយ អ្នកដឹកនាំ មានតែ អាឆយ ហ្នឹងគេប្រធានក្រុម-- *(ឮមិនច្បាស់)* ប្រធានកងវរៈយើង គេអ្នកដឹកនាំ គេអ្នកជំរុញការងារ អាហ្នឹងបងណ៎ា។

[១៤:១២:៤៨]

**ស៖** អំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា តើលោកធ្លាប់ដឹងទេថា នរណាគេជាអ្នកបង្រៀនអំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា?

**ឆ៖** បើនៅភូមិភាគនិរតី អាហ្នឹងខ្ញុំក៏មិនដែលបានចូលរួមគេ ឮថាតាម៉ុកៗ បងណ៎ា! អ្នកដឹកនាំឃោសនានយោបាយនិយាយហ្នឹង រឿងទ័ព រឿងអីណ៎ាបង! តែចំពោះខ្ញុំអត់ដែលចូលទេ ចំពោះខ្ញុំបានតែម៉ានៅក្រោយ អត់មានបានដឹងអីទេ អាហ្នឹង។ ព្រោះបងប្អូនខ្ញុំ ខ្សែបណ្តាញបងប្អូនខ្ញុំ គេយកច្រើន គេយកទៅវៃចោល គេមិនសូវទុកចិត្តណ៎ា! ដូចឪពុកក្មេកខ្ញុំ យកវៃចោល គេមិនទុកចិត្តខ្ញុំ គេដកខ្ញុំក្រោមទៀត។

**ស៖** គេមិនទុកចិត្តលើរឿងអ្វីបាទ? មូលហេតុអីបានគេមិនទុកចិត្តលោក?

**ឆ៖** មិនទុកចិត្តខ្ញុំ មានមូលហេតុខ្លាច ខ្ញុំចេះដឹងរឿងអីច្រើនទៅ ក្រែងលោ គេធ្វើបាបខ្ញុំ យកខ្ញុំវៃចោលដែរ ហេតុដូច្នេះ ខ្ញុំម៉េចហ៊ាននិយាយ។ ពីព្រោះខ្ញុំថា ខ្ញុំមានខ្សែបណ្តាញហើយ។ ប៉ុណ្ណឹងបង។

[១៤:១៤:០៣]

**សៈ** នៅពេលដែលលោកធ្វើជាកងទ័ព បន្ទាប់មកលោកធ្វើជានីរសារ លោកធ្លាប់ធ្វើជាកងឈ្លប អ៊ីចឹងនៅពេលដែលលោកអនុវត្តតួនាទីរបស់លោកជាកងឈ្លប ជាកងទ័ព ឬក៏ជានីរសារ តើគេមានបង្ខំឲ្យលោកធ្វើអ្វីខ្លះ? ហើយគេហាមឃាត់មិនឲ្យលោកធ្វើអ្វីខ្លះនៅពេលនោះបាទ?

**ឆះ** អង្កាល់ហ្នឹង ខ្ញុំកាលរត់នីរសារ គេមានណែនាំដែរ គេថាបើកាលណា អញចាត់តាំងអែ្នង ទៅហើយ បើហួសម៉ោងពេលវេលា អ្អែងប្រយ័ត្នណ៎ា! គេនិយាយប្រាប់អ៊ីចឹងណ៎ា បងណ៎ា! គេប្រាប់ខ្ញុំដែរ ពីព្រោះខ្ញុំរត់នីរសារស្រុកអង្កាល់ហ្នឹង នីរសារស្រុក។ ហើយគណៈស្រុកឈ្មោះ បងសាន និងបងសៀង។ ហើយបើខ្ញុំរត់ការទៅ មិនទាន់ផែនការគេ ឬមួយលើសម៉ោងគេ មកវិញគេណែនាំ។ ប៉ុណ្ណឹងបង។

[១៤:១៥:០៥]

**សៈ** គេណែនាំលោករបៀបម៉េចបាទ គេស្តីឲ្យលោក ឬក៏ព្រមានលោកដូចម្តេច? ឬក៏គេមានវិធានការដូចម្តេចចំពោះលោក?

**ឆះ** គេស្តី និងកសាងបង គេទៅកសាងស្វាត់តែម្តង។ គេកសាងស្វាត់ គេឲ្យយើង ជួនណានេះ គេឲ្យគេទៅសម្រាកមួយថ្ងៃ ប៉ុន្តែក្នុងសម្រាកហ្នឹងមួយថ្ងៃ គេកសាងខ្ញុំ បងណ៎ា រឿងការងារហ្នឹង។ ប៉ុណ្ណឹងបង។

**សៈ** ខ្ញុំសូមសួរមួយទៀត នៅពេលដែលលោកចូលរួមចលនាបដិវត្តន៍ តើលោកមានសិទ្ធិក្នុងការចាកចេញពីចលនាបដិវត្តន៍ដែរឬទេ?

[១៤:១៥:៥៨]

**ឆះ** អង្កាល់ហ្នឹងចូលធ្វើបដិវត្តន៍ បងអើយ ចង់ចេញវិញ? ចង់ចេញហ្នឹង ចង់ដែរ ប៉ុន្តែឈានទៅ វានឹកឃើញម្យ៉ាង នឹកឃើញកាលគេណែនាំច្រើនពេក បងណ៎ា! ទាក់ទងនឹងខ្លួនខ្ញុំក៏មានរឿងដែរ ខ្ញុំប្រុងមីតទៅស្រុកវៀតណាមណោះ អង្កាល់វារករឿងខ្ញុំណ៎ះ ហើយនឹកឃើញវាររករឿងច្រើនពេក ខ្ញុំក៏ប្រុងចេញដែរ ប៉ុន្តែចេញអត់រួច។ ខ្ញុំឃើញខ្សែបណ្តាញ គេយកធ្វើបាបអីនោះ ព្រោះគេធ្វើប្រវត្តិរូបមួយថ្ងៃបីដងនោះ ប្រាប់បងតែប៉ុណ្ណឹងបង។

**សៈ** បើសិនជាលោកចង់ចាកចេញ គេហាមមិនឲ្យចេញ ឬក៏មានបញ្ហាកើតឡើង បើសិនជាលោកចេញនៅពេលនោះ? ហើយមានបញ្ហាអ្វីខ្លះដែលកើតឡើង បើសិនជាលោកចាកចេញពីជួរបដិវត្តន៍នៅក្នុងអំឡុងពេលនោះ?

**ឆ៖** ចេះតែចេញទៅបាត់ទៅ កុំឲ្យវាចាប់បាន។ ចេះតែចេញឲ្យបាត់ទៅបង កុំឲ្យចាប់បានណំា។ តែចាប់បាន ស្លាប់ហើយ អង្កាល់ហ្នឹង។ ពីព្រោះខ្ញុំវាមិនសូវចេះដែរ។

[១៤:១៧:០២]

**សៈ** នៅពេលដែលលោកបម្រើបដិវត្តន៍ តើលោកមានសិទ្ធិសេរីក្នុងការមកសួរសុខទុក្ខក្រុមគ្រួសារបានឬទេ ឬក៏គេមិនអនុញ្ញាតឲ្យលោកមក?

**ឆ៖** គេអត់ឲ្យមកទេ បង។ គេអត់ឲ្យមកទេ គេថា មកក្រោយ-- អើ! ដូចខ្ញុំចាប់អារម្មណ៍ចិត្តរបស់ខ្ញុំ ខ្ញុំថាបើមកក្រោយ ក្រែងលោវាឃើញជីវភាពខាងក្រោយវាលំបាកយ៉ាងម៉េចហ្នឹងណ៎ះ។ ហ្នឹងហើយបានគេមិនឲ្យយើងមកហ្នឹង ខ្ញុំយល់ក្នុងខួរក្បាលខ្ញុំប៉ុណ្ណឹង វាមិនសូវយល់ខ្លាំងដែរ ព្រោះខ្ញុំមិនសូវចេះ។

[១៤:១៧:៣៧]

**សៈ** អរគុណ។ តើលោកនៅពេលលោកបម្រើកងទ័ព នៅពេលលោកកងឈ្លប នៅពេលដែលលោកធ្វើនីរសារ អំឡុងពេលនោះ លោកនៅតែមានសិទ្ធិក្នុងការគោរពប្រតិបត្តិតាមសាសនារបស់ខ្លួនដែរឬទេ? ឬក៏មិនអនុញ្ញាតឲ្យលោកធ្វើដូច្នេះ?

**ឆ៖** អាហ្នឹងបើនិយាយពីហ្នឹង កាន់ព្រះពុទ្ធសាសនា វាមិនឲ្យ បិទជិតស្អុងហ្មងបង។ ស្អីក៏វាមិនឲ្យធ្វើដែរ គ្មានទេតាមមើល៍ ព្រោះថា ឥឡូវឧទាហរណ៍ថា បើលុយកាក់ វាមិនឲ្យចាយ យើងមិនទៅចាយណា អីណា វាគ្មានទេ។

**សៈ** ហេតុអ្វីបានជាគេមិនអនុញ្ញាតឲ្យគោរពប្រតិបត្តិសាសនា តើមានហេតុផលអី? តើលោកបានដឹងឮរឿងនេះទេបាទ? មូលហេតុអីបានគេមិនឲ្យគោរពប្រតិបត្តិសាសនា?

**ឆ៖** ទេ ខ្ញុំមិនសូវដឹងទេ បងអាហ្នឹង ខ្ញុំមិនសូវយល់ទេបង ធ្វើម៉េចទេ។ អារឿង គោរពហ្នឹងម៉េច មិនសូវយល់អាហ្នឹង ខ្ញុំមិនដឹង។

**សៈ** អរគុណ។ តើលោកដែលឮពាក្យថា ការតស៊ូវណ្ណៈទេ? លោកធ្លាប់ឮពាក្យហ្នឹងទេបាទ? បើឮ តើមានន័យដូចម្ដេច ប្រសិនជាបានឮ?

**ឆ៖** អង្កាល់ហ្នឹងឮដែរ បង អាការតស៊ូវណ្ណៈៗឮដែរ ប៉ុន្តែខ្ញុំក៏ឮគេថាដែរ បងណ៎ះ គេថា អ្នែងចេះតែខំតស៊ូវណ្ណៈទៅ គង់តែឃើញទេ។ ប៉ុន្តែខ្ញុំក៏មិនដឹងយល់ទៅទិសដៅណាទៀត ខ្ញុំវាអត់យល់ព្រោះខ្ញុំអត់យល់ អត់សូវយល់បង។ គេចេះតែថា ចេះតែអ្វី!ហ្នឹងគេទៅ តាមគេអ៊ីចឹងទៅ។

**ស៖** ចុះលោកធ្លាប់ឮពាក្យថា “មាគ៌ានយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា” តើលោកធ្លាប់ឮពាក្យនេះទេបាទ?

**ឆ៖** ពាក្យហ្នឹងធ្លាប់ឮដែរ បង ធ្លាប់ឮ ដឹងដែរ ឮដែរ ធ្លាប់ឮ។

**ស៖** ពាក្យហ្នឹង មានន័យដូចម្ដេចបាទ?

**ឆ៖** អាឥឡូវបើខ្ញុំនេះ វាមិនសូវយល់ មិនសូវចេះ បង ព្រោះខ្ញុំថាទៅ មិនដឹងយល់ម៉េច ខ្ញុំមិនសូវជាយល់។ ខ្ញុំលំបាកកន្លែងហ្នឹងខ្ញុំ បាទ វាខួរក្បាលតិចពេក។

**ស៖** ចុះពាក្យថា “មនោគន៌វិជ្ជា” របស់បក្សកុម្មុយនីស្តកម្ពុជា តើលោកធ្លាប់ឮទេបាទ?

[១៤:១៩:៥៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីជាតិការពារក្ដីលោក អៀង សារី!

**លោក អាង ឧត្ដម៖**

សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម សូមអធ្យាស្រ័យលោកព្រះរាជអាជ្ញា។ ខ្ញុំមិនឡើងមកជំទាស់ទេ ប៉ុន្តែខ្ញុំសូមសំណូមពរ ខ្ញុំឃើញល្បឿនសំណួរ និងល្បឿនចម្លើយរត់ស្មើគ្នា។ ខ្ញុំសំណូមពរស្នើសូមឱ្យព្រះរាជអាជ្ញាឱ្យផ្អាកសិននៅពេលដែល-- បង្អង់ខ្លះទៅនៅពេលដែលមានចម្លើយចប់ ហើយអាចសម្រួលដល់ការបកប្រែផង។ សម្រាប់យើងជាខ្មែរ អត់អីទេ ក្រែងតែបរទេសខ្លាចមានបញ្ហាខាងបកប្រែ។ សូមអធ្យាស្រ័យ ហើយសូមៗអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយម្យ៉ាងទៀត គោលដៅដែលត្រូវសួរនេះ គាត់អត់ចេះអក្សរទេ។ ហើយពាក្យពេចន៍ដែលលោកព្រាងគ្រោង សំណួរដែលតាំងសំណួរនេះ អាចជាកម្រិតខ្ពស់ណាស់ ដែលអាចនឹងឆ្លើយតបទៅនឹងសំណួរនេះបាន។ ហើយសួរមួយដង-- មួយពាក្យហើយ មួយពាក្យទៀតហ្នឹងគឺគាត់មិនបានចាប់បានអីឆ្លើយតបទាល់តែសោះ ហើយវិធីសាស្ត្រនៅតែសួរ អាចប្ដូរវិធីសាស្ត្រយ៉ាងម៉េចនៃការតាំងសំណួរគោលដៅរបៀបនេះ ធ្វើយ៉ាងម៉េចឱ្យសមស្រប។ មិនមែនសួរដើម្បីសួរទេ! សួរដើម្បីឱ្យបានផលដែលអាចយកមកពិចារណាជាប្រយោជន៍ក្នុងការស្វែងរកការពិត។

[១៤:២១:៣០]

**លោក ច័ន្ទ តារាស្មី៖**

បាទ អរគុណលោកប្រធាន។ ខ្ញុំសូមបន្តសំណួរតទៅទៀត។

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** ខ្ញុំសូមតទៅក្នុងចំណុចទីពីរធំ ទាក់ទងនឹងការសួររបស់ខ្ញុំ គឺរចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ជាតិនៅមុនខែមេសា ឆ្នាំ១៩៧៥។ ចំណុចនេះ ខ្ញុំចង់ឲ្យលោកជួយបញ្ជាក់ថា តើនៅតំបន់រំដោះនៅកម្ពុជា នៅកន្លែងដែលលោកធ្លាប់ធ្វើការងារនៅក្នុងអំឡុងមុនខែមេសា ឆ្នាំ៧៥ លោកអាចបញ្ជាក់បានទេ តំបន់រំដោះហ្នឹងមាននៅកន្លែងលោកដែរឬទេ?

**លោក ខឹម ងួន៖**

**ឆ៖** ទេ ខ្ញុំក៏មិនសូវដឹងដូច-- ដូចមិនសូវដឹងទេបង អារំដោះៗហ្នឹង ឮតែពាក្យគេថារំដោះៗ ដែរហ្នឹងអង្កាល់ហ្នឹងណ៎ះ! បាទ។

**ស៖** លោកស្គាល់ទីប្រជុំជនតាកែវទេ បាទ?

**ឆ៖** ក្នុងទីក្រុងតាកែវ ប្រជុំជនតាកែវ បងអ្វេស? ខ្ញុំស្គាល់ដែរហ្នឹង។

**ស៖** តើទីប្រជុំជនតាកែវហ្នឹង ស្ថិតនៅក្នុងភូមិភាគឈ្មោះអ្វី?

**ឆ៖** តាកែវ អង្កាល់នុ៎ងគេដាក់ដូចភូមិភាគនិរតីបង។ អង្កាល់ហ្នឹងភូមិភាគនិរតី។

**ស៖** អរគុណ។ តើលោកដឹងទេថា នរណាគេដែលនៅពីលើ តាម៉ុក?

**ឆ៖** អ្វេ! នៅលើតាម៉ុក ខ្ញុំមិន-- មិនដឹងទេបងខ្ញុំអាកន្លែងហ្នឹងវា ខ្ញុំធ្វើតែក្រោមនៅអាយមិនដឹងទេនៅលើ ដល់-- អត់ដឹងសោះខ្ញុំ លែងដឹងសោះអាលើហ្នឹង ថ្នាក់លើហ្នឹង។

**ស៖** អរគុណ។ តើថ្នាក់តំបន់ ស្រុក ឃុំ ឬក៏អនុស្រុក ខ្ញុំបញ្ជាក់ជូនម្តងទៀត អនុស្រុក តំបន់ស្រុក ឃុំ បួនថ្នាក់ហ្នឹង តើមួយណាដែលទាបជាងគេ? មួយណាដែលខ្ពស់ជាងគេបាទ?

**ឆ៖** គណៈស្រុកអង្កាល់នុ៎ងមានតែ បងសាន ហើយ បងសៀង ទេបង។ គឺចុះមកមានអង្កាល់ហ្នឹង-- នៅគណៈស្រុកមានតែ បងសាន និង បងសៀង ធំជាងគេហ្នឹង។

[១៤:២៤:២២]

**ស៖** ខ្ញុំចង់ជម្រាបសួរថា តើថ្នាក់តំបន់ ស្រុក ឃុំ ឬក៏អនុស្រុកហ្នឹង រៀបតាមលំដាប់ពីទាបទៅខ្ពស់ ឬក៏ពីខ្ពស់មកទាប តើមួយណាធំជាង? មួយណាតូចជាង? មិនចង់និយាយអំពីឈ្មោះទេ ចង់និយាយអំពីទីតាំង ទីកន្លែងបាទ។ ឧទាហរណ៍ថា ខេត្តធំជាងស្រុកអីចឹង។ តើនៅពេលនោះ នៅអំឡុង

ពេលនោះ តើតំបន់ ស្រុក ឃុំ ឬក៏អនុស្រុកហ្នឹង ប្អូនហ្នឹងមួយណាខ្ពស់ជាងមួយណា? មួយណាធំជាងមួយណា? មួយណាតូចជាងមួយណា?

**ឆ៖** អ្ហឺះ! មិនដឹងមួយណាតូច មួយណាធំទេបង ជួនកាលខ្ញុំមិនសូវដឹងដែរ ពិបាកអ៊ីចឹងៗ។ ខ្ញុំឆ្លើយប្រាប់តាមត្រង់ ខ្ញុំឡើងមិនកើត វាអ៊ីចឹង វាមិនសូវចេះ អង្កាល់ហ្នឹងវានៅមិនដឹងអី ដល់ពេលចាស់ខ្លួន វាសូវដឹងអីទៀត។ វាអត់ដឹងបង មិនដឹងអ្នកណាខ្ពស់ អ្នកណាទាប វាមិនពិបាក សួរអ៊ីចឹងខ្ញុំមិនចេះដែរ។ អត់សូវយល់ដែរខ្ញុំ។

**ស៖** បាទ ខ្ញុំសូមអរគុណ។ សំណួរបន្ទាប់ទៀត ខ្ញុំសូមសួរលោកថា នៅស្រុកកោះអណ្ដែត តើលោកធ្លាប់ឃើញ ឬក៏ដឹងឮថាមានការបាត់ខ្លួនជាញឹកញាប់ដែរឬទេ? នៅមុនខែមេសា ឆ្នាំ៧៥ តើមានប្រជាជន ឬក៏មានមនុស្សបាត់ខ្លួនជាញឹកញាប់ដែរឬទេ នៅស្រុកកោះអណ្ដែត ក្នុងអំឡុងពេលមុនខែមេសា ឆ្នាំ១៩៧៥?

[១៤:២៦:០១]

**ឆ៖** អង្កាល់ហ្នឹងខ្ញុំបានឃើញដែរបង អង្កាល់ៗហ្នឹងវាបែកពីក្រុងតាកែវ គេបញ្ជូនប្រជាជនមកក្រោយហ្នឹង ស្រុកកោះអណ្ដែតហ្នឹង។ គេបញ្ជូនប្រជាជនមកក្រោយមក ដើរទាំងខ្សែៗ ខ្ញុំនៅធ្វើទ័ពអង្កាល់ហ្នឹងនៅទ័ពស្រុក ហើយខ្ញុំក៏ដើរមកក្រោយមក គឺគេឃើញមកក្រោយបងណ៎ា មិនដឹងយកទៅណា អត់បានដឹងដែរហ្នឹង។ គេយកមកក្រោយដែរ ប៉ុន្តែខ្ញុំអត់បានតាមដានឃើញ គេយកមកក្រោយមែនហ្នឹងរឿងហ្នឹង ខ្ញុំបានឃើញអាហ្នឹងហ៎។ ព្រោះអង្កាល់ហ្នឹងយើងរ៉ៃបែក គេមិនចាំទាំងខ្សែៗមកក្រោយមក ដល់ហើយមិនដឹងគេបញ្ជូនទៅណា។ ហើយខ្ញុំគេយកមកមន្ទីរវិញមក នៅកន្លែងជាមួយឆ៊យ វិញទៅ នៅប្រធានស្រុកនោះ។ ខ្ញុំមិនដឹងដែរបង ហើយមិនសូវដឹងដែរ។ អស់ហើយបង។

**ស៖** តើនៅក្នុងពេលប្រជុំ លោកមានដែរឮគេនិយាយអំពីពាក្យថា "ខ្មាំង" ឬ "ជនក្បត់" ដែរឬទេ?

[១៤:២៧:១០]

**ឆ៖** អង្កាល់ប្រជុំវាយរង នាយអាយ ត្រឹមប្រជុំត្រឹមក្រុមត្រឹមអី គេមានគេណែនាំថា "អ្ហែង! ប្រយ័ត្នខ្មាំងបង្កប់ខ្លួនណ៎ះ"។ អាហ្នឹងគេមាននិយាយហូរហែអ៊ីចឹងដែរបង ហូរហែអ៊ីចឹងណ៎ា។ គេមានប្រាប់ មាននិយាយអ៊ីចឹងដែរ ណែនាំអ៊ីចឹងដែរ។ តែខ្ញុំចេះតែចាប់អារម្មណ៍ដែរ នឹកឃើញគេនិយាយអ៊ីចឹងនេះហ្នឹង។ តែប៉ុណ្ណឹងបង។

**ស៖** តើមនុស្សប្រភេទម៉េចទៅ បានគេចាត់ទុកថាជាខ្មាំង?

**ឆ៖** អាហ្នឹងគេចាត់ទុកថា ដូចទៅធ្វើការងារលើកភ្លឺស្រែ ហ្នឹងខ្ញុំមិនដែលចូលរួម ថាឮសួរគេនិយាយ គេប្រជុំ គេថាដូច យើងនេះវាចោទយើងនេះលួចដំឡូង លួចអីអីចឹង គេហៅ យើងចោទចារកម្មអីចឹងទៅណា។ ធ្វើស្រែភ្លឺអីចឹងទៅ ទៅបោចមិនទាន់គេអីចឹង គេចាត់ទុកថាយើងអីចឹងទៅ។ ខ្ញុំបានដឹងឮប៉ុន្នោះ ខ្ញុំថាប៉ុណ្ណឹងទៅ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំអនុញ្ញាតបន្តសំណួរទៅចំណុចធំមួយទៀត គឺទាក់ទិនចលនាជម្លៀសប្រជាជននៅទឹកដីខេត្តតាកែវបាទ ហើយសូមឱ្យលោកជួយឆ្លើយសំណួរនេះ។ សំណួរដែលចង់ដឹងចំណុចនេះ គឺទាក់ទងនឹងបញ្ហានៃការជម្លៀសប្រជាជននៅខេត្តតាកែវ ថាតើមានការជម្លៀសប្រជាជននៅក្នុងទឹកដីខេត្តតាកែវពិតប្រាកដដែរឬទេ? ហើយបើសិនជាមាន តើលោកចាំទេនៅក្នុងអំឡុងពេលណា ចាប់ពីពេលណាបាទ?

**ឆ៖** អ្ហ៎ រឿងហ្នឹងឯងកាលពីបែកក្រុងតាកែវ បងអង្កាល់ហ្នឹងវា ខ្ញុំធ្វើទាហានហ្នឹង ដល់ពេលបែកហ្នឹងទៅ វាជម្លៀសចេញ មិនដឹងចេញទៅណា មិនដឹងកំណត់ មិនដឹងថ្ងៃប៉ុន្មាន ខែប៉ុន្មាន ខ្ញុំវាភ្លេចអស់ហើយ មិនចាំហ្នឹង។ តែខ្ញុំចូល មិនចាំផង ចូលបដិវត្តន៍ ខ្ញុំមិនចាំផង ខ្លួនខ្ញុំហ្នឹង។

**ស៖** តើលោកដឹងថាមានការជម្លៀសប្រជាជនមែន ឬក៏មិនមែននៅទឹកដីខេត្តតាកែវនោះ?

[១៤:២៩:២៤]

**ឆ៖** អង្កាល់ខ្ញុំឃើញ ខ្ញុំឃើញមែនបងណ៎ះ ពិតបានខ្ញុំនិយាយ មិនពិតខ្ញុំមិននិយាយទេ វាតែប៉ុណ្ណឹង ប៉ុន្តែយកទៅណា មិនដឹងទេអាហ្នឹង។

**ស៖** បាទ អរគុណ។ តើមនុស្ស មុខសញ្ញាប្រភេទណាទៅ ដែលជាមុខសញ្ញាត្រូវគេជម្លៀសចេញពីខេត្តតាកែវនោះ?

**ឆ៖** អ្ហ៎ អង្កាល់ហ្នឹងខ្ញុំវាក៏មិនបានដឹងបង មិនបានឃើញមុខដែរ មិនដឹងមុខពួកណា គេជម្លៀសទៅហ្នឹង ខ្ញុំក៏មិនយល់ទៀតណ៎ះ។ ខ្ញុំអត់ដឹងកន្លែងហ្នឹង ខ្ញុំ បានឃើញៗ មែន តែចំពោះថ្នាក់ដឹកនាំយកទៅអត់ដឹងសោះ ព្រោះខ្ញុំឡើងមកភ្នំពេញអង្កាល់ហ្នឹង ដល់ហើយហ្នឹង ខ្ញុំអត់ដឹង។

**ស៖** តើលោកមានដែលឮគេនិយាយអំពីការរៀបចំផែនការជម្លៀសនេះដែរឬទេ? មានឮគេនិយាយថា នរណាគេថ្នាក់ណាដែលជាអ្នករៀបចំផែនការជម្លៀសប្រជាជននេះ?

**ឆ៖** អ៊ើ កន្លែងហ្នឹងបងថ្នាក់លើ ខ្ញុំវាមិនសូវ វាមិនដឹងទេ បងកន្លែងហ្នឹងបង ឲ្យតែសួរខ្ញុំអត់ដឹងសោះ។ ខ្ញុំអត់ដឹងវាកន្លែងហ្នឹងសួរបានដឹង មានតែថ្នាក់លើដែល-- ហើយខ្ញុំនៅតែខាងក្រោមគេ ម៉េចដឹងបងណ៎ា។ ត្រឹមតែវាយរងនៅឯក្រោមនៅឯអាយហ្នឹង។ អត់ដឹងបង។

**ស៖** អរគុណ។ លោក ខឹម ងន តើការជម្លៀសប្រជាជនហ្នឹងគឺ មានទាំងស្រី ទាំងប្រុស ទាំងក្មេង ទាំងចាស់ ទាំងជនជាតិអ៊ីស្លាម ចាម ឬក៏យ៉ាងម៉េចបាទ? បើសិនជាលោកដឹងសូមលោកបញ្ជាក់ចំណុចនេះបន្តិចបាទ។

**ឆ៖** ទៅមិនដឹងខ្មែរក៏ដោយ ឯណាក៏ដោយវាមិនបានមើលជាប់ ព្រោះយើងសុទ្ធតែអ្នកខ្លាចដូចគ្នា ហើយយើងទៅដកប្រាវៗចេញដដែល។ ខ្ញុំធ្វើទ័ពគេដកប្រាវៗមិនបាននៅពិនិត្យទេបងកន្លែងហ្នឹងណ៎ា។ អស់ហើយបង។

**ស៖** បាទអរគុណ។

[១៤:៣១:២០]

**ប្រធានអង្គជំនុំ៖**

លោកៗមេធាវីប្រឹក្សាសាក្សី សូមលោកជួយ រង់ចាំជួយរំឭកសាក្សីផង ដើម្បីធ្វើជាសញ្ញាឲ្យគាត់ចាប់ផ្ដើមនិយាយ ឬក៏ជាសញ្ញាកុំអាលឲ្យគាត់និយាយ ព្រោះគាត់ច្រើនលើកច្រើនសានិយាយដោយក្បាលមីក្រូមិនទាន់ធ្វើប្រតិបត្តិការនៅឡើយទេ។ នេះជាការរំខានកិច្ចដំណើរការមួយ ដែលមិនអាចកត់ត្រាបានទេ។

សូមអញ្ជើញបន្ត!

**លោក ច័ន្ទ តារារស្មី៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ច័ន្ទ តារារស្មី៖**

**ស៖** លោក ខឹម ងន ខ្ញុំសូមសួរបន្តទៀត។ បាទ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ តើនៅថ្ងៃ ១៧ ខែមេសា ឆ្នាំ១៩៧៥ នេះ លោកនៅទីកន្លែងណាដែរបាទ? លោកស្ថិតនៅទីតាំងណា?

**ឆ៖** ៧៥ បងអ្ហេះ? ៧៥ ខ្ញុំគេដកមកនៅទីក្រុងវិញហើយហ្នឹង អង្គាល់បែកអស់ហ្នឹងណ៎ះ។

[១៤:៣២:២៣]

**ស៖** ហេតុអីបានជាគេដកលោកមកភ្នំពេញបាទ?

**ធ៖** គេដកខ្ញុំមកភ្នំពេញវិញ ឲ្យការមួយតាមស្ថានទូត។ ខ្ញុំនៅជាមួយទូតចិនកាលហ្នឹង។ គេដកខ្ញុំមកហ្នឹងបងណ៎ា។

**ស៖** អរគុណ។ តើខ្មែរក្រហមកងទ័ពខ្មែរក្រហម បានរំដោះទីក្រុងខេត្តតាកែវ នៅពេលណាបាទ?

**ធ៖** អ្ហ៎ កាលរំដោះតាកែវមិនដឹងខែណាទេបង ប្រហែលជាប៉ុន្មានខែប៉ុន្មានទេខ្ញុំ វាគ្មាន វាមិនចេះអក្សរហ្នឹងគេ វាមិនបានកត់ទុកក្នុងខួក្បាល ឬកត់ទុកមិនបានចាំនឹងគេ គ្រាន់រំដោះរាល់ថ្ងៃ០៧ មកវាមិនសូវដឹងផងឥឡូវ បើគេសួរក៏មិនដឹងដែរ។ បាទ ចប់ហើយបង។

**ស៖** ក្រោយពេលមានការរំដោះទីក្រុងនៅក្នុងខេត្តតាកែវហើយ ភ្លាមនោះតើមានគេឲ្យជម្លៀសប្រជាជនចេញទីរួមខេត្តតាកែវដែរឬទេ?

**ធ៖** កាលនោះ គេជម្លៀចេញ ឲ្យចេញបង ប៉ុន្តែខ្ញុំវាបែកមកចេញ ដូចខ្ញុំនិយាយអំមិញហ្នឹងណ៎ា ខ្ញុំទៅដកចេញប្រាវៗ គេអ្នកមានអ្នកនាំដោយឡែកទៀតបងណ៎ា។ មិនបានឃើញ ប៉ុនវាមិនបានចំណាំព្រោះគេទៅដកប្រូសៗដូចគ្នាហ្នឹង។

[១៤:៣៤:០៥]

**ស៖** លោកបានឃើញដោយផ្ទាល់ភ្នែក ឬក៏លោកឃើញគេថា មានការជម្លៀសប្រជាជនចេញពីខេត្តតាកែវនោះ?

**ធ៖** ខ្ញុំឮតែពួកនោះថាទេ ព្រោះខ្ញុំមិនបានឃើញផ្ទាល់ទេបង ព្រោះខ្ញុំនៅខាងកើតអ៊ីចេះ ហើយគេនៅខាងលិច គេថាគេនាំទៅលិច ព្រោះខ្ញុំអត់បានឃើញផ្ទាល់ទេបងណ៎ា។ អត់ឃើញផ្ទាល់ទេ។

**ស៖** តើអ្នកណាដែលប្រាប់លោកអំពីការជម្លៀសនេះបាទ?

**ធ៖** អង្កាល់ហ្នឹងអាធឿន បង។ អាធឿន ឈ្មោះ ធឿន គេប្រាប់ខ្ញុំហ្នឹងណ៎ា! ឥឡូវវាងាប់បាត់ហ្នឹង។ អាហ្នឹងងាប់បាត់ហើយ។

**ស៖** ឈ្មោះ ធឿន ហ្នឹង នៅអំឡុងពេលនោះ តើ ធឿន ហ្នឹងធ្វើអ្វី? ឈ្មោះ ធឿន ធ្វើអីបាទ?

**ធ៖** អត់មានធ្វើអីទេបង យុទ្ធជនចំតែម្តង។ យុទ្ធជនដូចខ្ញុំដូចគ្នា។

**ស៖** អរគុណ។ ខ្ញុំចង់ឲ្យលោកជួយបញ្ជាក់អំពីមូលហេតុបន្តិចថា តើលោកបានដឹង ឬក៏បានឮគេថាអំពីមូលហេតុអ្វី បានជាគេជម្លៀសប្រជាជនចេញពីខេត្តតាកែវនោះ?

**ធ៖** អង្កាល់ហ្នឹង យើងវើនៅទីក្រុងតាកែវ មិនវើបែក ដល់ពេលបែក គេមិនជម្លៀសចេញបង

ណ៎ះ។ ហើយដល់ជម្លៀសមកក្រោយទៅ យើងខ្ញុំក៏មិនបានតាមដានឲ្យដឹងដូចនិយាយអម្បាញ់មិញនេះបងណ៎ះ ដូចថាមិននិយាយជាន់ដានទេ។ អង្គាល់ហ្នឹងបានជម្លៀសចេញ ដល់ពេលវ៉ៃទីក្រុងបែក គេនាំចេញមកក្រោយៗ មិនដឹងទៅណា ហើយខ្ញុំក៏គេយកមកកន្លែងវិញមក គេមានអ្នកយកដោយឡែកណាបងណារឿងហ្នឹង ហើយខ្ញុំយុទ្ធជនយើងម៉េចដឹង គេអ្នកធំគេនាំចេញ យើងអត់ដឹងទេ។ ដឹងតែនាំចេញយប់ ឬថ្ងៃប៉ុន្មានអត់ដឹងទេ។ ប៉ុន្តែពួកម៉ាក់វាប្រាប់ថា អង្គាល់ហ្នឹងគេដឹករថយន្តទៅក្រោយច្រើនណាស់ម៉េចបានដឹង បើវ៉ៃបែកហើយ។ ហើយខ្ញុំ*(ឮមិនច្បាស់)* ទៅវិញទៀតទៅ តែប៉ុណ្ណឹងបង។ ខ្ញុំអាចដឹងប៉ុណ្ណឹង។

[១៤:៣៦:១១]

**ស៖** បាទ សូមអរគុណ។ តើលោកអាចបញ្ជាក់បានទេថា ការជម្លៀសប្រជាជនចេញហ្នឹងប្រជាជនចេញពីទីរួមខេត្ត ពីទឹកដីខេត្តតាកែវហ្នឹងដោយមធ្យោបាយអ្វី? មធ្យោបាយដោយឡាន? ដោយថ្មើរជើង? ដោយកាណូត ដោយអ្វីបាទ?

**ឆ៖** អង្គាល់ហ្នឹងវ៉ៃបែក អង្គាល់ហ្នឹងអង្គាល់វាដឹកនាំទៅ អង្គាល់អាណាវាប្រាប់ អារឿន ប្រាប់ខ្ញុំ អត់មានជិះទេ ដើររហូតទេ។ ប៉ុន្តែដូចអង្គាល់ហ្នឹងដាក់ឡានត្រឹមមាណ ឬមួយបណ្តើរដាក់ត្រឹមមាណខ្ញុំអត់ដឹងទេណាបងណា ព្រោះខ្ញុំអត់ដឹងដែរ។ គ្រាន់ទៅជូនទៅជូន ប៉ុន្តែជូនដល់ត្រឹមមាណអត់ដឹង ខ្ញុំអត់ដឹងទេ ខ្ញុំនៅឯកើតនេះហ្នឹង។ ខ្ញុំអត់បានឃើញទេ ឃើញតែគេថាហ្នឹង ប៉ុន្តែពេលក្រោយគេថាដឹកអ៊ីចេះដឹក-- ពីរឿងជិះឡានខ្ញុំមិនបានដឹង អាដើរដល់ត្រឹមមាណក៏ខ្ញុំវាមិនបានដឹង ព្រោះភ្លេចភ្លាំងដែរ វាដូចជាមិនជិះឡានទេ ដើរក៏ដើរឆ្ងាយដែរ។ គេជម្លៀសទៅហ្នឹងបងណ៎ះ បាទ ប៉ុណ្ណឹង។

**ប្រធានអង្គជំនុំ៖**

លោកតំណាងអយ្យការ លោកគិតគួរថែមទៀតអំពីភាពពាក់ព័ន្ធទៅនឹងអង្គហេតុដែលបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ។ គ្រាន់នេះជាអង្គហេតុជាក់លាក់នៃការជម្លៀស។ សូមឲ្យតាំងសំណួរពាក់ព័ន្ធទៅនឹងអង្គហេតុជាក់លាក់ ដែលបានបង្ហាញនៅក្នុងដីកាដំណោះស្រាយ ទាំងទីកន្លែងទាំងពេលវេលានៃជម្លៀស ទីមួយ និងទីពីរ ក្រែងលោអាចច្រឡំគ្នា។

[១៤:៣៨:០៤]

**លោក ច័ន្ទ តារាស្មី៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមតសំណួរតទៅទៀត។

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** លោក ខឹម ងន នៅពេលដែលការជម្លៀសប្រជាជននេះ គឺមានទិដ្ឋភាពធំធេង ឬក៏តិចតួចបាទ?

**លោក ខឹម ងន៖**

**ឆ៖** អង្កាល់ហ្នឹងដូចៗមិនច្រើនផង ដូចគ្នាតិចដែរ តាមមើលបង ឮ អាធឿន និយាយថាគ្នាតិចដែរហ្នឹងណា។ ថាវែច្រើន យើងក៏មិនបាន រ៉ៃស្មាន ស្មើបណ្ដោយទៅថា ទៅដូចតិចដែរ អង្កាល់ហ្នឹង ចុះប្រជាជនខាងកើតដកមកក្រៅច្រើនហើយហ្នឹង។ ដឹកមកក្រៅច្រើន អង្កាល់ហ្នឹងដូចទាហានហ្នឹង គេដកមកក្រៅច្រើនណាស់បង នៅសល់បន្តិចបន្តួចដែរជម្លៀសចេញហ្នឹង។ ចប់ហើយបង។

**ស៖** អរគុណ។ តើលោកមានបានឃើញប្រជាជន នៅពេលដែលគេជម្លៀសហ្នឹងមានស្លាប់ ឬក៏មាន ស្ថិតក្នុងស្ថានភាពបែបណាខ្លះ?

**លោក សុន អរុណ៖**

លោកប្រធាន ខ្ញុំសូមជំទាស់។

**ប្រធានអង្គជំនុំ៖**

បាទៗ សូមអញ្ជើញលោកមេធាវី! សាក្សីកុំអាល់ទាន់ឆ្លើយ ស្ដាប់ការជំទាស់របស់មេធាវីជាតិការពារក្ដីលោក នួន ជា ជាមុនសិន។ ហើយការជំទាស់ សូមឲ្យបង្ហាញឲ្យនូវមូលហេតុឲ្យបានជាក់ច្បាស់ផង។

[១៤:៣៩:៤៤]

**លោក សុន អរុណ៖**

សូមអរគុណលោកប្រធាន។ សូមគោរពអង្គសវនាការ សូមគោរពប្រធាន។ សំណួររបស់លោកព្រះរាជអាជ្ញាទាំងប៉ុន្មាននេះ សាក្សីបានឆ្លើយរួចហើយថា គាត់អត់ដឹងទេ ឮគេថា។ អ្នកប្រាប់គាត់ហ្នឹងគឺឈ្មោះ ធឿន ហើយគាត់អត់នៅកន្លែងជម្លៀសទេ គាត់អត់បានឃើញទេ។ នៅ-- ម៉្លោះហើយ នៅតាមសួរដដែលៗ នេះជាការដឹកនាំសំណួរ។ ម៉្លោះហើយខ្ញុំសូមជំទាស់។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សេចក្ដីជំទាស់មានប្រសិទ្ធភាព។ អង្គជំនុំជម្រះមិនត្រូវការស្ដាប់ចម្លើយតបរបស់សាក្សីទៅនឹងសំណួរនេះទេ។ សាក្សីមិនបាច់ឆ្លើយតបទេ។ តំណាងសហព្រះរាជអាជ្ញាបន្តសំណួរផ្សេងទៀត ហើយ

សូមបញ្ជាក់ថា សូមឲ្យមានភាពពាក់ព័ន្ធកាន់តែស៊ីជម្រៅទៅលើអង្គហេតុដែលបានធ្វើឲ្យមានការចោទប្រកាន់។ មិនមែនឲ្យតែកើតឡើងរបៀបហ្នឹង ហើយយកមកដេញដោលទេ វាដេញដោលតែអង្គហេតុណាដែលវាកើតឡើង ហើយបង្ហាញលាតត្រដាងនៅក្នុងដីកាចោទប្រកាន់ និងដីកាដំណោះស្រាយដែលបញ្ជូនរឿងមកជំនុំជម្រះបានហើយ។

**លោក ច័ន្ទ តារាស្មី៖**

អរគុណលោកប្រធាន។

[១៤:៤១:00]

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** លោក ខឹម ងន ខ្ញុំសូមបន្តសំណួរ ខ្ញុំមានសំណួរមិនច្រើនទេ ប្រហែលជាបីបួនសំណួរទៀត ខ្ញុំបញ្ចប់ការសួររបស់ខ្ញុំចំពោះលោក។ ខ្ញុំឲ្យលោកជួយបញ្ជាក់បន្តិចថា លោកមានបានឮគេនិយាយទេ ឬក៏លោកបានដឹងដោយព័ត៌មានពេលក្រោយណាមួយថា ការជម្លៀសប្រជាជនហ្នឹងគឺឆ្ពោះទៅគោលដៅណា? ពីខេត្តតាកែវហ្នឹងបាទ។

**លោក ខឹម ងន៖**

**ឆ៖** អត់ដឹងទេបង ដល់ពេលក្រោម អត់ដឹងទេអាហ្នឹង ព្រោះខ្ញុំ ដកខ្ញុំមកនេះហើយហ្នឹង។ ពេលបែកមកដល់មកភ្នំពេញនេះអត់ដឹងទេអាហ្នឹង។ អត់ដឹងទេបង។

**ស៖** បាទ តើនៅពេលដែលអំឡុងពេលជម្លៀសប្រជាជនហ្នឹង ក្នុងទឹកដីខេត្តតាកែវ លោកមានឃើញប្រតិកម្មពីខាងណាចំពោះសកម្មភាពនៃការជម្លៀសដែរឬទេ? ឬក៏លោកធ្លាប់ឮមានគេនិយាយថាមានការតវ៉ាជម្លៀសហ្នឹងដោយប្រជជាន ឬក៏ដោយអ្នកណាផ្សេងទៀតដែរឬទេ?

[១៤:៤២:០២]

**ឆ៖** អ្ហ៎ ជម្លៀសកាលហ្នឹង ដូចរើបែក ដល់រើបែកចាប់ទាញមកក្រោយអ៊ីចឹងមកណ៎ា មិនដឹងដល់ពេលយើងបង្កើត មិនដឹងពីណាអ្នកដឹកនាំយោធាវាអត់ដឹងអាហ្នឹង កន្លែងហ្នឹងបង។ វាអ៊ីចឹង ហើយខ្ញុំទៅនោះទៅ ខ្ញុំដកមកក្រោយដែរហ្នឹង ទៅដោយឡែកទៅ។

**លោក ច័ន្ទ តារាស្មី៖**

បាទ លោកប្រធាន ខ្ញុំមានតែបីសំណួរទៀតមុននឹងបញ្ចប់ការសួររបស់ខ្ញុំចំពោះលោក ខឹម ងន បាទ។ សូមអនុញ្ញាតបន្តសំណួរ។

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** លោក ខឹម ងន ខ្ញុំសូមឲ្យលោកជួយបញ្ជាក់បន្តិចថា មុនពេលដែលគេជម្លៀសប្រជាជន ឬក៏ក្នុងពេលដែលគេជម្លៀសប្រជាជនទៅ តើពួកគេមានបានឲ្យជនដែលត្រូវជម្លៀសដូចជាប្រជាជនត្រូវជម្លៀសតាមផ្លូវហ្នឹង គេតម្រូវឲ្យគាត់សរសេរប្រវត្តិរូប ឬក៏អត់ទេ? តើលោកមានបានឮគេថាបញ្ហានេះទេ ឬក៏លោកធ្លាប់ឃើញផ្ទាល់ឬយ៉ាងណាបាទ? មានគេសេរសេរ តម្រូវឲ្យប្រជាជនហ្នឹងសរសេរប្រវត្តិរូបទេចំពោះបុគ្គលដែលត្រូវគេជម្លៀសចេញពីទឹកដីខេត្តតាកែវនោះ?

[១៤:៤៣:០១]

**លោក ខឹម ងន៖**

**ឆ៖** អាហ្នឹង ខ្ញុំអត់ដឹងទេបងកន្លែងហ្នឹង អត់ដឹងបងអាហ្នឹង។ ថាអត់ដឹង មិនមែនចេះតែថាព្រោះខ្ញុំសម្បថហើយៗ។

**ស៖** សំណួរទីពីររបស់ខ្ញុំសូមអនុញ្ញាតសួរសំណួរទីពីរ ជាសំណួរបន្ទាត់ចុងក្រោយមុននឹងបញ្ចប់។ បាទ សូមសួរថា តើលោកបានឃើញ ឬក៏បានជួបបុគ្គលដែលគេជម្លៀសមកពីទីក្រុងភ្នំពេញ ហើយមករស់នៅខេត្តតាកែវ ឬក៏នៅស្រុកកោះអណ្ដែត ដែរឬទេ? លោកមានបានជួបទេ ពេលដែលគេជម្លៀសពីទីក្រុងភ្នំពេញ ទៅរស់នៅក្នុងទឹកដីខេត្តតាកែវ ឬក៏នៅក្នុងស្រុកកោះអណ្ដែត។ តើលោកមានបានជួបប្រជាជននោះដែរឬទេ?

**ឆ៖** អាហ្នឹង ខ្ញុំអង្កាល់មកនៅភ្នំពេញ អត់មានបានទៅវិញទេបង នៅធ្វើការភ្នំពេញរហូតទៅដល់វៀតណាមបុកចូលមកហ្នឹង។ តែមកក្រោយ ខ្ញុំអត់បានដឹងទេ ព្រោះខ្ញុំនៅធ្វើការណេះហើយ អត់បានដឹងក្នុងរង្វង់ឆ្នាំហ្នឹង។ អត់ដឹងទេ អាហ្នឹង។

**ស៖** បាទ សូមសួរអនុញ្ញាតសួរសំណួរចុងក្រោយលោកប្រធាន។ សូមលោក ខឹម ងន បញ្ជាក់ចុងក្រោយថា តើស្ថានភាពនៃការជម្លៀសប្រជាជន បើសិនជាលោកបានដឹងបានឮ សូមលោកបញ្ជាក់។ តែបើសិនជាលោកមិនបានដឹងបានឮទេ ក៏មិនបាច់ឆ្លើយទេ។ តើស្ថានភាពនៃការរស់នៅរបស់ប្រជាជនដែលត្រូវជាជម្លៀសហ្នឹងស្ថិតក្នុងស្ថានភាពដូចម្ដេចបាទ?

[១៤:៤៤:២៦]

**ឆ៖** វាអត់ដឹងបង កន្លែងហ្នឹងអត់បានឃើញទេ អត់ដឹងទេបង មិនប៊ានថាទេ។ ចប់ហើយបង។

**លោក ច័ន្ទ តារាវស្នី៖**

បាទ សូមអរគុណលោកប្រធាន ដោយសារតែពេលវេលារបស់ខ្ញុំមានកម្រិត អ៊ីចឹងខ្ញុំសូមបញ្ចប់ការសួររបស់ខ្ញុំចំពោះលោក ខឹម ងន តែប៉ុណ្ណេះ ហើយលោក ខឹម ងន ខ្ញុំក៏សូមអរគុណចំពោះលោកដែលបានឆ្លើយសំណួររបស់ខ្ញុំនៅអំឡុងពេលប្រហែលជាសាមសិប ទៅសែសិបនាទីកន្លងមកនេះ។ ហើយខ្ញុំសូមអនុញ្ញាតពីលោកប្រធានជូនវេទិកានេះជូនទៅលោក វ៉ាងសង់ ដែលជាសហការីរបស់ខ្ញុំបន្តសំណួរបន្តទៀតបាទ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ប៉ុន្តែឥឡូវនេះដល់ពេលម៉ោងសមល្មមសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបីប្រាំនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកសមរម្យនូវបន្ទប់រង់ចាំរបស់ សម្រាប់សាក្សីដល់សាក្សី និងមេធាវីប្រឹក្សារបស់គាត់ ហើយនិងឲ្យអញ្ជើញគាត់មកកន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងបី និងប្រាំនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៥នាទី ដល់ម៉ោង ១៥:០៦ នាទី)*

[១៥:០៥:៥៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ ហើយសូមរំឭកដល់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិថា ស្ថានភាពនៃកម្រិតយល់ដឹងរបស់សាក្សីរូបនេះមានកម្រិតទាបណាស់។ ហេតុដូច្នេះ សូមឲ្យលោកតំណាងសហព្រះរាជអាជ្ញារៀបចំនូវសំណួរសាមញ្ញហើយនិងខ្លី ហើយដើម្បីបានងាយយល់ ហើយនិងអាចឆ្លើយតបបាន។ ហើយសំខាន់ សូមពិនិត្យផងដែរ

លើភាពពាក់ព័ន្ធនៃចម្លើយរបស់គាត់ដែលធ្លាប់ឆ្លើយនៅក្នុងអំឡុងពេលដំណើរការចំពោះមុខ ផ្តល់សក្ខីកម្មចំពោះមុខអ្នកស៊ើបអង្កេត ដើម្បីបង្កើនល្បឿននៃដំណើរការពិភាក្សាដេញដោលស្តាប់សក្ខីកម្មសាក្សីរូបនេះ។

[១៥:០៧:០៨]

**លោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្មាឯល៖**

សូមអរគុណច្រើនលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម ជម្រាបសួរលោកសាក្សី។ ដូចដែលលោកបានធ្វើអម្បាញ់មិញនេះ ខ្ញុំសូមឲ្យលោកឆ្លើយឲ្យបានច្បាស់លាស់ទៅនឹងសំណួរទៅនឹងសំណួរដែលខ្ញុំនឹងចោទសួរ។ ហើយសុំឲ្យលោកចាំពេលបន្តិច ដើម្បីឲ្យមានការបកប្រែទៅជាភាសាបារាំង យើងត្រូវការពេលដើម្បីបកប្រែ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្មាឯល៖**

**ស៖** ខ្ញុំមានចំណុចតូចមួយពាក់ព័ន្ធទៅនឹងការជម្លៀសទៅតាកែវ។ គឺថាដើម្បីកំណត់អំពីវិធីនៃប្រតិបត្តិការនៃការជម្លៀសនៅក្នុងប្រទេស។ យើងត្រូវពិនិត្យមើលថា តើវាមានភាពដូចគ្នាយ៉ាងម៉េចទៅនឹងការជម្លៀសទីក្រុងភ្នំពេញ។ ខ្ញុំសូមអានចម្លើយរបស់លោកសាក្សីនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ដែលមានលេខយោង D280-- D208/18 នេះគឺជាសម្រង់នៃទំព័រទី៣ នៅគ្រប់ទំព័រជាភាសាខ្មែរ បារាំង និងអង់គ្លេស គឺនៅទំព័រ៣ទាំងអស់។

សំណួរមួយចំនួនត្រូវបានសួរដោយអ្នកស៊ើបអង្កេតទៅកាន់សាក្សី។ សំណួរដំបូងសួរថា “នៅពេលដែលរំដោះទីក្រុងតាកែវ តើលោកបានឃើញព្រឹត្តិការណ៍អ្វីខ្លះ? ចម្លើយ៖ នៅពេលរំដោះ តាកែវប្រជាជនត្រូវបានជម្លៀសទៅកាន់ខាងសមរភូមិក្រោយ។ ហើយបន្ទាប់មកគេមានដឹកតាមឡានទៅកាន់ខាងសមរភូមិក្រោយ ខ្ញុំឃើញមានមនុស្សស្លាប់នៅក្នុងទីក្រុង ខ្ញុំមិនដឹងថា តើជាយោធា ឬក៏ជាប្រជាជននោះទេ។ ហើយបន្ទាប់មកទៀត មានសួរសំណួរ៖ តើអ្នកណាជាអ្នកបញ្ជាឲ្យប្រជាជនចេញពីក្រុង? ចម្លើយរបស់សាក្សីគឺ៖ អ្នកដឹកនាំស្រុកដែលចេញពបញ្ជាឲ្យប្រជាជនចាកចេញ។ ប្រសិនបើអ្នកណារឹងទទឹងនោះ គឺថាគេឲ្យបាញ់អ្នកនោះចោល”។ សូមបញ្ចប់ការដកស្រង់។

លោកសាក្សី តើលោកបានស្តាប់ឮនូវការអានចម្លើយរបស់លោកនៅចំពោះសហចៅក្រមស៊ើបអង្កេតដែរឬទេ? តើលោកនៅរក្សាថា លោកនៅបាននិយាយចម្លើយបែបនេះទេ?

[១៥:០៩:៥២]

**លោក ខឹម ងន៖**

**ឆ៖** អត់ដឹងផង អាហ្នឹងមិនដឹងម៉េច។ អត់ស្ទូវច្បាស់ សូមសួរម្តងទៀតមើល៍!

**លោក ម៉ម រិទ្ធា៖**

ជាបឋម ខ្ញុំបាទសូមគោរពលោកប្រធាន សូមគោរពលោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។ ដោយសារការយល់ដឹងរបស់កូនក្តីរបស់ខ្ញុំមានកម្រិត។ ដូច្នេះ សំណួរដែលសហព្រះរាជអាជ្ញាចោទសួរ ខ្ញុំបាទចង់ពន្យល់កូនក្តីខ្ញុំបាទ សាក្សី ដើម្បីឲ្យគាត់មានលទ្ធភាពអាចឆ្លើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

មិនអាចធ្វើដូច្នេះបានទេ បាទ ព្រោះសាក្សី-- មេធាវីប្រឹក្សា គឺប្រឹក្សាតែពាក់ព័ន្ធទៅនឹងសំណួរដាក់បន្ទុកលើខ្លួនឯងទេ។ អរគុណណាស់ ដែលមានចិត្តដូច្នេះ ប៉ុន្តែកិច្ចដំណើរការនីតិវិធីនេះ មិនអាចប្រព្រឹត្តទៅដូច្នេះបានទេ។

លោកតំណាងសហព្រះរាជអាជ្ញាតាំងសំណួរសាជាថ្មីម្តងទៀត ហើយតាមការស្តាប់របស់យើងខ្ញុំលើការ-- អត្តសញ្ញាណឯកសារ ដូចជាមានការភ័ន្តច្រឡំ។ D280/18 មិនមែន 208/18 ទេ។ ទំនងឬក៏មានឯកសារផ្សេងពីនេះ? សូមលោកបញ្ជាក់ជាមុនលើអត្តសញ្ញាណឯកសារដែលលោកសំអាងទៅលើ ពីព្រោះវាពាក់ព័ន្ធជាមួយនឹងប្រតិចារឹកដែលនឹងយោងទៅដល់ក្នុងការប្រើប្រាស់រៀបចំសាលក្រម។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន ពិតណាស់ គឺឯកសារលេខ D280/18 គឺខ្ញុំបានផ្តល់លេខកូដខុសអម្បាញ់មិញនេះធ្វើឲ្យខ្ញុំភ័ន្តច្រឡំ។ ខ្ញុំនឹងសួរសំណួរឡើងវិញ ធ្វើម៉េចឲ្យងាយស្រួលឲ្យសាក្សីស្តាប់បាន។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សី អម្បាញ់មិញនេះ ខ្ញុំអានចម្លើយរបស់លោក នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត។ ផ្នែកដំបូងនៃចម្លើយនោះ គឺលោកបញ្ជាក់ថា៖ "ទាហាន លន់ នល់ ដែលចុះចាញ់នោះគេចាប់ចងទាំងអស់ រួចហើយដឹកតាមឡានមកក្រោយ"។ គឺនៅពេលដែលបែកតាកែវនោះ។ តើលោកនៅតែរក្សាចម្លើយដែលលោកបានឆ្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតពាក់ព័ន្ធនឹងទាហាន លន់ នល់ នេះ ដែរឬទេ?

**លោក ខឹម ងន ៖**

**ឆ៖** អត់ទេបង។ ខ្ញុំបាទអត់ឃើញទេ អត់ទេហ្នឹង បាទអត់ឃើញ។ អស់ៗហើយ។

[១៥:១៣:១១]

**ស៖** តើលោកនៅតែរក្សាចម្លើយដែលលោកឆ្លើយកាលពីបីឆ្នាំមុននោះ គឺថាលោកបានឃើញមានមនុស្សស្លាប់នៅតាមផ្លូវក្នុងក្រុង ប៉ុន្តែលោកមិនដឹងទេថា ជាទាហាន ឬក៏ជាប្រជាជននោះ។ អ៊ីចឹងលោកនៅតែរក្សាចម្លើយនេះដដែលឬ?

**ឆ៖** អូ! អង្កាល់ហ្នឹង ខ្ញុំបានឃើញមែន អង្កាល់ហ្នឹង អាក្នុងសំណួរឆ្លើយមុន។ ពូ ខ្ញុំភ្លេចអាហ្នឹងធ្វើម៉េចវាពេលភ្លេច។ អាហ្នឹងបានឃើញ អង្កាល់រំដោះ កាលហ្នឹងវាដឹកៗមកថយក្រោយ មកច្រើនដែរ ប៉ុន្តែចំពោះខ្លួន វាដូចខ្ញុំឆ្លើយលើកមុន អត់បានដឹងទេ អាហ្នឹង ប៉ុន្តែខ្ញុំបានឃើញ តែអ្នកណាគេបញ្ជាឲ្យទៅទៀត ក៏ខ្ញុំវាមិនបានចាប់អារម្មណ៍ដែរ រឿងហ្នឹង។ អស់ហើយ ពូ។

**ស៖** ហើយនិងចំណុចក្រោយ ដែលលោកបានឆ្លើយទៅសហចៅក្រមស៊ើបអង្កេត គឺថាស្រុកជាអ្នកចេញបញ្ជាឲ្យប្រជាជនចេញ ហើយប្រសិនបើអ្នកណារឹងទទឹងនោះ គេបញ្ជាឲ្យបាញ់ចោល។ តើលោកនៅរក្សាចម្លើយទេ ថាប្រសិនជាអ្នកណារឹងទទឹងនោះ គេនឹងបាញ់ចោល?

**ឆ៖** អង្កាល់ហ្នឹង គេ-- ដល់ហើយបើគេបញ្ជាឲ្យទៅ ដូចហើយថា បើយើងមិនទៅ គេបាញ់ចោទមែនបង កាលហ្នឹងខ្ញុំនិយាយអ៊ីចឹង។ អាហ្នឹង គេដឹកនាំ អ្នកដឹកនាំ ប្រធានគេអាហ្នឹង ហើយខ្ញុំក៏មិនសួរយល់ដែរ វា-- អស់ហើយបង អស់យោបល់ហើយ។ វាមិនសួរយល់ផងខ្ញុំ។

[១៥:១៤:៥៤]

**ស៖** តើលោកបានឃើញទេ? ឃើញគេបាញ់ចោលទេ? ឬក៏គ្រាន់តែលោកឮគេនិយាយទេ? លោកបាននិយាយថា លោកបានឃើញមនុស្សស្លាប់។ អ៊ីចឹងតើលោកឃើញមានអ្នកណារឹងទទឹងចំពោះការជម្លៀសទេ?

**ឆ៖** អង្កាល់ហ្នឹងមានអាពួកម៉ាកខ្ញុំគេប្រាប់ គេថា គេជម្លៀសដូចគេ ពួកហៅថាទ័ពធំគេ គេនាំមកក្រោយមក ហើយពួកខ្ញុំដកចេញមក ហើយដល់ហើយគេហ្នឹង ពួកម៉ាកប្រាប់ថា ឥឡូវអ្អែងមើល គេយកមនុស្សទៅវ៉ៃចោលច្រើនណាស់ យកទៅក្រោយច្រើនណាស់ មិនថាវ៉ៃចោល យកទៅក្រោយ។ ហើយខ្ញុំបានឮបានដឹងតែប៉ុណ្ណឹង ហើយឲ្យខ្ញុំ-- ឥឡូវហ្នឹងមិនបានយល់ទេបង។ អស់ហើយ។

**ស៖** ឥឡូវនេះ ខ្ញុំចូលទៅប្រធានបទមួយទៀត គឺពាក់ព័ន្ធនឹងការងាររបស់លោកនៅក្រសួងការបរទេស។ បន្ទាប់ពីការរំដោះតាកែវ តើរយៈពេលប៉ុន្មានដែលលោកមកដល់ភ្នំពេញ?

[១៥:១៦:០២]

**ធ៖** មកភ្នំពេញខ្ទង់ខែ-- អ៎! ឆ្នាំមួយពាន់ប្រាំបួយរយ-- មើល៍ ជិតចូល៧០ អង្កាល់បែកភ្នំពេញ ហើយបានរយៈពេលប្រហែលកន្លះខែលោកបង។ គេឲ្យមក ខ្ញុំមករៀននៅសាលាបច្ចេកទេសសូវៀតនេះ។ ដល់ហើយ គេរៀនចប់ហើយ គេឲ្យចែកការងារទៅនៅតាមស្ថានទូត ហើយខ្ញុំគេចាត់តាំងទៅនៅផ្ទះលេខ៧ ហ្នឹងទៅបង។ នៅជាមួយភ្ញៀវចិន។

**ស៖** តើគេបានពន្យល់លោកទេ ហេតុអីបានជាគេជ្រើសរើសយកលោកឲ្យមកភ្នំពេញនុំង?

**ធ៖** ដល់កន្លែងរៀនសូត្រ គេពន្យល់ដែរបង គេប្រាប់ដែរ គេណែនាំដែរណ៎ា គេប្រជុំ។ ឈ្មោះអ្នកប្រជុំហ្នឹងមានតែ បងហុង ទេអ្នកគេហៅទៅប្រជុំ ព្រោះនៅជាមួយភ្ញៀវ គេថាណែនាំកុំនិយាយប៉ះពាល់ខាងផ្នែកនយោបាយ។ ហើយខ្ញុំយុទ្ធជនទាំងអស់នេះក៏ស្ដាប់គេហ្នឹងដែរ ម៉េចទៀតក៏ខ្ញុំមិនដឹងដែរ តែខ្ញុំនៅជាមួយចិន ខ្ញុំភ្ញៀវចិន ជូនភ្ញៀវដើរលេងអ៊ីចឹងទៅ អ្នកបម្រើទេ។ បាទ ចប់ហើយបង។

[១៥:១៧:៣៣]

**ស៖** សូមអរគុណ។ ខ្ញុំសូមឲ្យលោកឆ្លើយឲ្យជាក់លាក់ទៅនឹងចម្លើយរបស់-- ទៅនឹងសំណួររបស់ខ្ញុំ កុំឲ្យទៅលឿនពេក ខ្ញុំនឹងត្រឡប់មកក្រោយមកវិញ។ លោកនិយាយពីការរៀនសូត្រ គឺថាមានរយៈពេលប្រហែលមួយអាទិត្យ។ តើការរៀនសូត្រហ្នឹងប្រព្រឹត្តទៅនៅកន្លែងណា? ហើយមានប៉ុន្មាននាក់បានចូលរួមក្នុងការរៀនសូត្រនុំង?

**ធ៖** អារៀនសូត្រនុំង វា-- មើលនៅក្នុងមន្ទីរហ្នឹងវាមានប្រាំមួយនាក់លោកពូ រៀនមានប្រាំមួយនាក់។ ដល់ហើយអ៊ីចឹងគេណែនាំយើងគ្រប់បញ្ហាទាំងអស់ ការងារដឹកនាំរស់នៅជាមួយគេហ្នឹង ជាមួយភ្ញៀវបរទេសហ្នឹង។ ហើយដល់ហើយវា អាមួយនោះវាបើកឡានជូនភ្ញៀវទៅ មានគ្រោះថ្នាក់អ៊ីចឹងទៅគេចាប់។ គេថា គេមិនថាមិនចាប់ គេថាដកទៅថយក្រោយ។ អាហ្នឹងដូចខ្ញុំឆ្លើយមុនហ្នឹង ដូចៗនៅក្នុងនេះនោះ គេចាប់ដកថយក្រោយមក ដល់ហើយមិនដឹងយកទៅណា វាអត់ដឹងដែរ។ ដល់ចំពោះខ្លួនខ្ញុំទៀត គេយកខ្ញុំនេះមកដាំស្ពៃនៅក្រុងតាខ្មៅអ៊ីចឹងមក រយៈពេលចំនួនបីខែ បានគេយកខ្ញុំហ្នឹងវិញ មកនៅជាមួយភ្ញៀវវិញ។

[១៥:១៨:៥៤]

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំចង់និយាយអំពីការរៀនសូត្ររយៈពេលមួយសប្ដាហ៍ សូមឲ្យលោកនិយាយតែត្រឹមអាពេល រយៈពេលមួយសប្ដាហ៍នៃការរៀនសូត្រហ្នឹងបានហើយ។ លោកបាននិយាយថា គឺថាមានរបៀប គេបង្រៀនអំពីរបៀបនាំភ្ញៀវ។ ចុះពាក់ព័ន្ធទៅនឹងវិន័យ ឬក៏វិធានជាធរមាន

ដែលត្រូវអនុវត្តនៅក្រសួងការបរទេសនោះ តើយ៉ាងម៉េចដែរ?

**ឆ៖** គេណែនាំវិន័យក្នុងការដើរហើរ ក្នុងការហូបចុកគ្រប់បញ្ហាទាំងអស់លោកពូ។ អស់ហើយ។

**ស៖** តើលោកអាចធ្វើអ្វីបានខ្លះជាមួយភ្ញៀវ គេអនុញ្ញាតឲ្យលោកនិយាយអីខ្លះជាមួយភ្ញៀវ? ហើយអ្វីខ្លះដែលគេមិនឲ្យលោកនិយាយជាមួយភ្ញៀវ ឬក៏ធ្វើអ្វីខ្លះជាមួយភ្ញៀវនោះ?

**ឆ៖** ជាមួយភ្ញៀវគេបិទសិទ្ធិមិនឲ្យនិយាយ គេខ្លាចប៉ះពាល់នយោបាយ។ ហើយទំនេរទៅណា គេណែនាំឲ្យខ្ញុំដើរសេរី ប៉ុណ្ណឹងលោកពូ។

**ស៖** នៅពេលដែលលោកនិយាយអំពីភ្ញៀវ លោកចង់និយាយសំដៅទៅដល់ជនបរទេស ឬក៏មានជនជាតិខ្មែរដែរ ដែលធ្វើដំណើរនៅក្នុងប្រទេស?

[១៥:២០:៥៣]

**ឆ៖** មាន១ លោកពូមាន ដូចភ្ញៀវអ្នកនៅបម្រើទៅជាមួយខ្មែរហ្នឹងមាន ជាមួយជនជាតិហ្នឹងណា។ អ្នកបើកឡានអីចឹងទៅ អ្នកបម្រើគេយកទៅជាមួយខ្លះអីចឹងទៅ ទៅដល់តាកែវដល់អីអីចឹង ដល់កំពតអីចឹងទៅ វាមាន *(ឮមិនច្បាស់)* ។ ចប់ហើយ។

**ស៖** នៅពេលដែលគេបង្រៀននោះ តើគេនិយាយអ្វីខ្លះប្រាប់លោក គេនិយាយថា បើសិនយើងនិយាយប៉ះពាល់ដល់នយោបាយអីអីចឹង តើមានទណ្ឌកម្ម ឬក៏មានផលវិបាកអីចំពោះលោកទេ បើសិនបើលោកនិយាយប៉ះពាល់នយោបាយជាមួយភ្ញៀវនោះ?

**ឆ៖** បើយើងនិយាយប៉ះពាល់ជាមួយនឹងភ្ញៀវ គេដកយើងមកក្រោយ ខ្លះអីចឹងជួនណាគេណែនាំយើងទៅលោកពូ។ បើយើងខុស គេណែនាំយើង ជួនណាគេដកយើងមិនប្រាប់ ថាឥឡូវដកសិទ្ធិមកក្រោយសិន។ ដកដឹងដកដល់ត្រឹមមាណអត់ប្រាប់យើងអាហ្នឹង។ អាអ្នកនៅនេះអត់ដឹងទៀត។ ចប់ហើយ។

**ស៖** តើលោកចង់មានន័យថាម៉េចដកយកមកក្រោយហ្នឹង? សូមបញ្ជាក់ឲ្យបានច្បាស់បន្តិចមើល៍ តើមានន័យថាម៉េចដែរ អាដកមកក្រោយហ្នឹង?

**ឆ៖** ដក ផ្លាស់កន្លែងហ្នឹង នៅកន្លែងណា មិនដឹងគេដូរដាក់កន្លែងណាទៀត ព្រោះអត់ដឹងកន្លែងហ្នឹងណា ព្រោះខ្ញុំវាមិនដឹងដែរ ដកទៅវាបាត់ខ្លួនទៅ មិនដឹងទៅណា ហើយខ្ញុំនៅកន្លែងនៅទៅគេណែនាំរៀនទៅ។ តែប៉ុណ្ណឹងលោកពូ។ ដកអត់ដឹង។ កាលនោះ គេដក គេមានប្រាប់យើង គេមិនប្រាប់ទេ ផ្លាស់កន្លែងមួយ គេអត់ប្រាប់យើងអាហ្នឹង។

**សៈ** តើនៅពេលធ្វើដំណើរជាមួយភ្ញៀវ ធ្លាប់មានភ្ញៀវណាមួយសួរសំណួរទៅលោកទេ ហើយមានអីកើតឡើងដែរ?

[១៥:២៣:១១]

**ឆៈ** គេប្រាប់ដែរ បើទៅជាមួយភ្ញៀវឆ្ងាយ គេថា មិនឲ្យនិយាយជាមួយភ្ញៀវ ហើយភ្ញៀវក៏មិនសូវប៉ានទាក់ទងជាមួយនឹងយើងប៉ុន្មានដែរ។ ដូចជូនទូតវៀតណាមទៅហូបនេះអីចឹង អត់សល់បន្តិចបន្តួច គេអត់ឲ្យហូបដែលទេណា។ ហ្នឹងគេបិទអត់ឲ្យហូបទេអាហ្នឹង។ ចប់ហើយ។

**សៈ** នៅពេលកំពុងបំពេញការងារជាមួយភ្ញៀវ តើលោកមានធ្លាប់មានការភ័យខ្លាច ក្នុងការរំលោភទៅនឹងការហាមឃាត់ទេ ហើយនិយាយប៉ះពាល់ទៅដល់នយោបាយអីទេ លោកមានធ្លាប់អីចឹងទេ?

**ឆៈ** ខ្ញុំនៅជាមួយភ្ញៀវ មិនសូវប៉ាននិយាយដែរ មិនសូវប៉ាននិយាយ ក្រែងប៉ះពាល់។ ហើយខ្ញុំនៅហ្នឹងវាខុសខ្លួនដែរ កាលហ្នឹងអើវាថាមេអាអ្នកដឹកនាំនោះ ដូចជានេះគេថា អ្នែងខុសខាងសីលធម៌ គេហៅមកកសាងទៅ ភ្ញៀវទៅជាមួយភ្ញៀវទៅ។ វាខុស គេចោទថាយើងខុសទៅ ព្រោះខ្ញុំដឹងខ្លួនធ្វើប្រវត្តិរូបមួយថ្ងៃបីដងនៅជាមួយគេនេះ គេសង្ស័យដែរបានខ្ញុំឈប់ហ្នឹងណ៎ា។ គេយកមកក្រោយមកដាំស្ពៃ ខ្ញុំ។ អស់ហើយបង។

**សៈ** តើប្រហែលជាប៉ុន្មានខែដែរ ឬក៏ប៉ុន្មានឆ្នាំដែរ? ខ្ញុំដឹងថា លោមមានបញ្ហាក្នុងការរំឭកចងចាំពីថ្ងៃខែ មានន័យថា តើលោកធ្វើការនៅក្រសួងការបរទេសខាងផ្នែក ស្ថានទូត ឬក៏ខាងផ្នែកជូនភ្ញៀវហ្នឹងប៉ុន្មានខែ ប៉ុន្មានឆ្នាំដែរ? លោកចាំទេ?

**ឆៈ** អូ! យើងអើ! ដូចៗចិតសិប ចិតសិបប្រាំមួយ បងអ្នេស! ខ្ញុំមិនសូវភ្លេចដែរ ភ្លេចដែរមិនសូវចាំមិនចាប់អារម្មណ៍ចេះតែនៅៗអីចឹងទៅ វាណាមួយមិនសូវចេះអីចឹងបង។ មិនដឹង៧៦ ដល់ពាក់កណ្ដាល--ចុង៧៥ ប៉ុន្តែខ្ទង់៧៦ហើយ ព្រោះខែប្រាំមួយ យើងដកទូតវៀតណាមពីភ្នំពេញវិញ ខែប្រាំមួយ មិនដឹងថ្ងៃប៉ុន្មានដកចេញហ្នឹង។ ចប់ហើយពូ។

**សៈ** អរគុណ។ គឺមានន័យថាប៉ុន្មានឆ្នាំដែរ ដែលលោកនៅបំពេញការងារហ្នឹងមុននឹងគេបញ្ជូនលោកទៅខាងក្រោយ ទៅខាងតាខ្មៅនោះ?

**ឆៈ** ជិត នៅជិតមួយឆ្នាំពូ។ ជិតមួយឆ្នាំនៅនុ៎ង។ គឺចុង៧៥ វាចូល៧៦នោះ។ ជិតមួយឆ្នាំ។ ចប់ហើយ។

[១៥:២៦:៣០]

**ស៖** ហើយបន្ទាប់ពីបញ្ជូនទៅតាខ្មៅ តើលោកមានត្រឡប់មកក្រសួងការបរទេសវិញទេ?

**ឆ៖** មកវិញ ពូមកវិញ។ មកវិញនៅហ្នឹងបានរយៈពេលប៉ុន្មានខែ មើលវាបីខែ បួនខែមិនដឹងទេ។ បានវៀតណាមវាចូល ដូចបីបួនខែតាមមើល។ ដូចមិនសូវចាំដែរខ្ញុំ។ ចប់ហើយ។

**ស៖** សូមអរគុណ។ នៅពេលដែលលោកធ្វើការនៅស្ថានទូតចិន តើផ្ទះដែលឯកអគ្គរដ្ឋទូតចិនរស់នៅនុ៎ងគេហៅអ្វីដែរ?

**ឆ៖** ផ្ទះទូតចិននៅ អង្កាល់ហ្នឹងគាត់នៅផ្ទះលេខ៧ ប៉ុន្តែគាត់នៅច្រើនកន្លែងណាស់។ នៅក្បែរចំការមននេះផង ប៉ុន្តែអង្កាល់ហ្នឹងក៏មិនបានមើលលេខផ្ទះ ចំការមននៅមួយកន្លែងដែរអង្កាល់ហ្នឹងវាមានទូតកម្មករផង ទូតគេរត់ការផង អាចមិនដឹងណ៎ះ។ ទូតគេពីរបីកន្លែងទូតហ្នឹង ទូតណាៗ ប៉ុន្តែអាច- - ដែលខ្ញុំស្គាល់មិនដឹងប៉ុន្មានទូត មានបួន-ប្រាំ-ប្រាំមួយទូតអង្កាល់ជំនាន់ហ្នឹងដាក់ទូតនៅភ្នំពេញហ្នឹង។ អស់ហើយ។

[១៥:២៨:០៥]

**ស៖** សូមអរគុណ។ នៅពេលដែលលោកនៅផ្ទះលេខ៧ តើលោកធ្លាប់ចូលរួមការប្រជុំការងារនៅហ្នឹងកន្លែងនោះទេ?

**ឆ៖** ខ្ញុំធ្លាប់ប្រជុំដែរ ប៉ុន្តែប្រជុំតែអ្នកនៅតែមន្ទីរហ្នឹងទេណាពូ នៅប្រាំ-ប្រាំមួយនាក់ហ្នឹង។ តែបងហុង គេជាអ្នកនាំអាតប្រជុំ អត់ពី បងហុង,ទៅ អាភឿង គេអ្នកនាំប្រជុំទៅ។ តែគេនិយាយពីរឿងផ្សេងៗអីចឹង រឿងណែនាំខាងផ្នែកនយោបាយ រស់នៅជាមួយភ្ញៀវអីចឹងទៅ។

**ស៖** តើលោកអាចប្រាប់បានទេថា អ្នកណាដែលឈ្មោះ ហុង ហ្នឹង? តើគាត់មានឈ្មោះអីផ្សេងទៀតទេ?

[១៥:២៨:៥៧]

**ឆ៖** ទេ អង្កាល់ខ្ញុំដឹងឈ្មោះតែមួយ តែប្រែក៏ខ្ញុំមិនដឹងទេលោកពូ។ បើគេប្រែឈ្មោះក៏ខ្ញុំមិនដឹង ប៉ុន្តែអាឈ្មោះដែលនៅក្នុងមន្ទីរ ដែលខ្ញុំស្គាល់ជាមួយនឹងគ្នានឹងគេហៅតែ បងហុងៗ។ ខ្ញុំដឹងប៉ុណ្ណឹង។

**ស៖** តើលោកដឹងថា ឈ្មោះ ហុង នេះកាន់មុខងារអីនៅក្រសួងការបរទេស?

**ឆ៖** អង្កាល់ហ្នឹងគេប្រធានមន្ទីរ ចុះពី បងហុង ហើយគឺ អាភឿង មួយទៀត គេអ្នកខាងចាត់ចែងការងារអ្នកបើកបរឡានហ្នឹង ដឹកភ្ញៀវហ្នឹង។ មានតែ បងហុង និងអាភឿងហ្នឹងទេ។ អស់យោបល់។

**ស៖** សូមអរគុណ។ តើនៅផ្ទះលេខប្រាំពីរ ឬក៏នៅក្រសួងការបរទេស? លោកមានធ្លាប់ចូលក្នុងកិច្ចប្រជុំទិតៀន ឬក៏ស្វ័យទិតៀនទេ?

**ឆ៖** ធ្លាប់ដែរអាហ្នឹង ធ្លាប់ ប៉ុន្តែប្រជុំនៅក្នុងមន្ទីរហ្នឹង គេទិតៀនយើងដែរ ធ្វើអីចេះខុស ធ្វើអីចុះត្រូវ ប៉ះពាល់នយោបាយ គេមានណែនាំយើងដែរណ៎ា ក្នុងការរស់នៅជាមួយគេហ្នឹង ជាមួយភ្ញៀវហ្នឹង។ ប៉ុន្តែជាមួយភ្ញៀវ យើងមិនដែលប្រជុំជាមួយអត់ទេ ពួកអ្នកធ្វើការខ្មែរហ្នឹងណ៎ា ប៉ុន្តែត្រឹមតែម៉ាចូលបម្រើបាយ បម្រើអីហ្នឹងលោកពូ។ ចប់ហើយ។

**ស៖** តើអ្នកចូលរួមក្នុងកិច្ចប្រជុំរិះគន់ ទិតៀន និងស្វ័យទិតៀន ក្នុងនោះមានលោកដែរនោះ តើខ្លាចអ្នកផ្សេងត្រូវបានរិះគន់ ឬក៏រាយការណ៍អីទេ?

**ឆ៖** ខ្លាចដែរ អាមួយនោះឈ្មោះ ជ្រឹង គេរាយការណ៍ គេដកមកក្រោយ ខ្ញុំនិយាយលើកមុនហ្នឹង គេដកមកក្រោយបាត់មកអាហ្នឹង មិនដឹងទៅណា គេអត់ប្រាប់។ អាអ្នករស់នៅជាមួយគ្នារាយការណ៍ បើមិន អាភឿង ក៏ បងហុង ដែរ។ ព្រោះគេអ្នករាយការណ៍ហ្នឹង។ អស់យោបល់បង។

[១៥:៣១:២៧]

**ស៖** សូមអរគុណ។ យើងនឹងត្រឡប់មកនិយាយពីឈ្មោះ ជឹង នេះនៅពេលក្រោយ។ តើក្រៅពីកិច្ចប្រជុំនៅផ្ទះលេខ៧ តើលោកធ្លាប់ចូលកិច្ច-- ចូលរួមកិច្ចប្រជុំធំៗនៅក្រសួងការបរទេសដែរឬទេ? ឧទាហរណ៍ដូចជា មានជាប្រជុំជាមួយហ្នឹងបុគ្គលិករបស់ផ្ទះផ្សេងទៀត ឬក៏បុគ្គលិកផ្នែកផ្សេងទៀត តើធ្លាប់មានទេ?

**ឆ៖** ចំពោះខ្លួនខ្ញុំអត់ដែលប្រជុំទេ អត់ដែលចូលរួមទេ អាហ្នឹងត្រឹមថាប្រជុំកន្លែងស្ថានទូតផ្ទះលេខ៧ ហ្នឹង ប្រជុំសមាជិកមានហ្នឹងនាយអាយ បើចំពោះអ្នកធំ តែខ្ញុំទៅចូលរួមដូចអត់ដែរទេ ព្រោះយើងមិនយុទ្ធជនអត់បានជាមួយគេទេ។ គេអត់ទេ។ ក្រោមលក្ខខណ្ឌ លាក់ការណ៍របស់គេលោកពូអាហ្នឹងណ៎ា។ លាក់ការណ៍របស់គេ។ ចប់ហើយ។

**ស៖** តើគេហៅអគាររបស់ក្រសួងការបរទេសហ្នឹង គេហៅអីដែរ តើមានឈ្មោះលេខកូដអីទេ?

**ឆ៖** អ្ហេ! អាលេខកូដអគារហ្នឹង ខ្ញុំមិនស្គាល់ទេពូ បានម៉ាដឹងកាលហ្នឹង បានម៉ាដឹងរស់នៅជាមួយគេ បានម៉ានេះដឹង ប៉ុនឲ្យឈ្មោះអីអត់ដឹង អត់យល់ខ្ញុំកន្លែងហ្នឹង។ ហើយនៅជាមួយភ្ញៀវនៅបានរឿងអគារលេខប៉ុន្មានៗអត់បានមើល តែចំពោះផ្ទះលេខ៧ ខ្ញុំ គេប្រាប់ថានេះផ្ទះលេខ៧ ព្រោះបង់លេខពីមុខ ឃើញនៅហ្នឹង។ គេថាអីចឹងណ៎ះ។

[១៥:៣៣:១២]

**ស៖** ប្រហែលជាខ្ញុំនិយាយមិនសូវច្បាស់ ខ្ញុំចង់សំដៅលើមន្ទីរសំខាន់របស់ក្រសួងការបរទេស។ លោកស្គាល់ទេ ស្គាល់លេខកូដទេ មន្ទីរហ្នឹងហៅមន្ទីរអីដែរ?

**ឆ៖** អាហ្នឹងគេដាក់ក្រសួងការបរទេសតែម្តង អាហ្នឹង តែអំពី ប-១ គេដាក់ ប៉ុន្តែដល់ពេលចែកក្រសួង គេក្រសួងការបរទេសនៅតាមផ្ទះភ្ញៀវ។ អាកន្លែងប-១ ហ្នឹងមានកន្លែងរៀបចំផ្ទះសម្បែងហ្នឹង ទីក្រុងភ្នំពេញអត់មានមនុស្សនៅកាលហ្នឹងៗ។ ហ្នឹងគេចាត់ចែងអ៊ីចឹងបង អ៎! លោកពូ។

**ស៖** ខ្ញុំសូមត្រឡប់មកក្រោយវិញ តើលោកធ្លាប់ចូលរួមកិច្ចប្រជុំរួមនៅ ប-១ ទេ?

**ឆ៖** ប-១ ខ្ញុំអត់ដែលធ្លាប់ប្រជុំទេ អត់ដែលចូលមកទេអាហ្នឹង។ អត់ដែលទេ អារឿងខ្ញុំមិនដែល ខ្ញុំមិនប៉ាន់ថាទេ មិនប៉ាន វាអត់មាន អត់ចូលមកសោះអាហ្នឹង។ មន្ទីរគេ មន្ទីរហ្នឹងគេអតីតយុទ្ធជនហ្នឹងណា ហើយនិងកម្លាំងគេចាត់ចែង គេប្រជុំហ្នឹងលោកពូ តែខ្ញុំអត់ដែលមកហ្នឹងសោះ។ ប្រឡោះផ្ទះហ្នឹងមួយ ព្រោះមិនសូវប៉ានដើរផង។ ចប់ពូ។

[១៥:៣៤:៤០]

**ស៖** នៅពេលប្រជុំដែលលោកបានចូលរួមនៅផ្ទះលេខ៧ តើគេមាននិយាយអំពីគោលជំហរនយោបាយ ដែលត្រូវប្រកាន់យកទេ?

**ឆ៖** គេមានដែរ គេបំពាក់បំប៉នខាងផ្នែកនយោបាយដែរហ្នឹង ពង្រឹងគោលជំហរនយោបាយដែរ។ ការអប់រំ រស់នៅជាមួយភ្ញៀវហ្នឹង គេមិនឲ្យនិយាយអីៗហ្នឹង ដូចនិយាយសារមុនអ៊ីចឹង។ ចប់ពូ។

**ស៖** នៅពេលប្រជុំនោះ តើគេមាននិយាយប្រាប់លោកអំពីខ្មាំង ឬក៏ពីជនក្បត់ទេ?

**ឆ៖** អង្កាល់ហ្នឹងគេប្រាប់ដែរ គេថាប្រយ័ត្នអី ថាប្រយ័ត្នមានអ្នកបង្កប់ក្នុងក្រុម សេ.អ៊ី.អាហ្នឹង គេថាអ៊ីចឹងណា។ ប៉ុន្តែខ្ញុំវាមិន-- អង្កាល់ហ្នឹងវានៅតូច វាមិនសូវវា វាអត់សូវយល់ វាថាខ្មាំងៗក៏នឹកឃើញក្នុងចិត្ត ខ្មាំងៗ ហ្នឹងខ្មាំងហើយ មានតែតាមដានគ្នា រំអុកគ្នាប៉ុណ្ណឹង។ ខ្ញុំយល់ប៉ុណ្ណឹងខ្លួនខ្ញុំចប់ហើយ។

[១៥:៣៦:០៦]

**ស៖** ដូច្នេះ ក្នុងអំឡុងពេលដែលលោកធ្វើការនៅក្រសួងការបរទេស តើលោកមានអារម្មណ៍ថាមានការតាមដានពីសំណាក់មិត្តរួមការងាររបស់លោកទេ?

**ឆ៖** នៅក្នុងធ្វើការ នៅក្រុមជាមួយនឹងគ្នាហ្នឹង គេមានបង្កប់នៅអ្នកស៊ើបការណ៍គេ ប៉ុន្តែគេអត់ប្រាប់យើង។ ដូចខ្ញុំយុទ្ធជនអ៊ីចឹង ហើយគេបក្ខជន និងសម្ព័ន្ធយុវកក គេក្រុមស្នូលរបស់គេ គេមានរបស់លោកពូណា តែចំពោះរឿងយុទ្ធជន អាចគេប្រើទេ ហើយនិងគេណែនាំយើង និងគេធ្វើការយើង និយាយមិនស្រួល គេរាយការណ៍យើងអ៊ីចឹង។ ចប់។

**ស៖** ប្រសិនបើអ្នកណាម្នាក់នៅក្នុងក្រុមរបស់លោក ហើយពិនិត្យឃើញថា មានអ្នកណាប្រព្រឹត្តកំហុសនោះ តើពួកគាត់ត្រូវមានកាតព្វកិច្ចនៅក្នុងការរាយការណ៍នៅក្នុងពេលប្រជុំ ឬក៏រាយការណ៍ជូនទៅមេទេ?

**ឆ៖** អាហ្នឹងមាន លោកពូមាន ព្រោះមានវាមានផ្ទៃក្នុង វាមានរាយការណ៍ថ្នាក់ធំ ថ្នាក់លើ ហើយអាហ្នឹង បើវាមិនស្អប់យើង ក៏យើងនិយាយជាមួយភ្ញៀវ។ ឧទាហរណ៍ គេនៅជាមួយភ្ញៀវចិនហ្នឹងទៅ វាមានផ្ទៃក្នុងរបស់គេ គេអ្នកការ អ្នកធ្វើការនៅជាមួយក្រុមស្នូលរបស់គេ គេរាយការណ៍ប្រាប់ថ្នាក់លើអ៊ីចឹងទៅណា។ តែចំពោះខ្ញុំ យុទ្ធជន គេអត់ដឹង។ ឧបមាថាមកប្រជុំ ប្រជុំម្នាក់ឯងហ្នឹង។ ជីវភាពគ្នាឯងបីថ្ងៃ ប្រជុំម្ដងប៉ុណ្ណឹង។ ហើយកសាងក៏ដោយ គេរាយការណ៍សម្ងាត់ឡើងទៅ វាតាមដានគេមិនបានទេ ពីព្រោះយើងយុទ្ធជន។ មានតែគេថ្នាក់ធំ គេអ្នកក្ដោបក្ដាប់លើទៀត។ ហើយខ្ញុំវាមិនបានស្គាល់ទេ អាអ្នកធំហ្នឹង។ ឮសូរតែសំឡេងដែរហ្នឹង។ ចប់ហើយលោកពូ។

[១៥:៣៨:០៤]

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំសូមត្រឡប់មកនិយាយអំពីប្រវត្តិរូបរបស់លោកដែលលោកត្រូវសរសេរក្នុងអំឡុងពេលដែលលោកនៅក្រសួងការបរទេស ហើយនិងក្នុងអំឡុងពេលដែលលោកនៅតាកែវ។ តើលោកអាចជម្រាបបានទេ? អម្បាញ់មិញ លោកនិយាយថា លោកសរសេរប្រវត្តិរូបបីថ្ងៃ--បីដងក្នុងមួយថ្ងៃ។ លោកនិយាយអំពីប្រវត្តិរូបដែលលោកសរសេរនៅតាកែវ ឬក៏ជាប្រវត្តិរូបដែលលោកសរសេរនៅក្រសួងការបរទេស?

**ឆ៖** ប្រវត្តិរូបខ្ញុំសរសេរនៅក្រសួងការបរទេស។ គេឲ្យខ្ញុំសរសេរនៅក្រសួងការបរទេសហ្នឹង គេតាមដានខ្ញុំ ហើយខ្ញុំនឹកឃើញក្នុងចិត្ត ចាប់អារម្មណ៍ដែរ ចាប់អារម្មណ៍ដឹងថា កន្លែងដែលការប្រជុំជីវភាពគេកសាងខ្ញុំ ស្អែកឡើងគេឲ្យខ្ញុំធ្វើប្រវត្តិរូបក្នុងមួយថ្ងៃបីដង លើកទីមួយ គេអត់យកទេ។ លើកទីពីរ គេអត់យកទៀត។ ដល់តែលើកទីបី វាបាត់ទៅ។ អាហ្នឹងគេឲ្យខ្ញុំធ្វើអ៊ីចឹងណា ប៉ុន្តែខ្ញុំចាប់អារម្មណ៍ដែរ ទើបមកក្រោយ បែបបងប្អូនខ្ញុំ វាទម្លាយសាមុននោះថា បែបវាមានគ្រោះថ្នាក់អីហើយ បានគេពិនិត្យ

ប្រវត្តិរូបខ្លាំង លោកពូ! បាទ សូមចប់ប៉ុណ្ណឹង។

[១៥:៣៩:៣៨]

**សៈ** នៅក្រសួងការបរទេស តើអ្នកណាជាអ្នកឱ្យលោកជាអ្នកសរសេរប្រវត្តិរូប?

**ឆៈ** បងហុង ចំហ្នងពូ! ចប់ហើយ! បងហុង ហ្នង។

**សៈ** តើគាត់មានមកពន្យល់លោកទេ ថាត្រូវធ្វើប្រវត្តិរូបហ្នឹងឡើងវិញ គាត់មានបានពន្យល់មូលហេតុទេ តើមានព័ត៌មានអីដែលខ្លះនៅក្នុងប្រវត្តិរូបដែលលោកបានសរសេរហ្នឹងឬទេ?

**ឆៈ** ធ្វើលើកទីមួយ យកឱ្យគេ គេពន្យល់ដែរ គេថាអ៊ីចេះខុសហើយ។ ដល់លើកទីពីរ ខុសទៀត វាពេលដល់លើកទីបី ឱ្យអាពួកម៉ាកខ្ញុំធ្វើឱ្យទៅ យកទៅស្ងាត់ទៅ។ ចប់ត្រឹមហ្នឹងពូ។

**សៈ** តើលោកបានសរសេរអ្វីខ្លះនៅក្នុងជីវប្រវត្តិរូបរបស់លោក បន្ទាប់ពីមានការរិះគន់នៅក្នុងពេលប្រជុំនោះ?

**ឆៈ** សរសេរប្រវត្តិរូប ប្រវត្តិពីភូមិកំណើតរបស់ខ្ញុំ ហើយនិងអាយុខ្ញុំ ពីភូមិកំណើត និងឪពុកម្ដាយ និងបង-- អំ បងប្អូន។ កាលហ្នឹង អត់ទាន់មានប្រពន្ធទេ សរសេរពីប្រវត្តិ ដាក់ក្នុងប្រវត្តិរូបហ្នឹង ដាក់ពីបងប្អូន និងឪពុកម្ដាយ ភូមិកំណើត ឃុំ ស្រុក អី ខ្ញុំដាក់តែប៉ុណ្ណឹង ហើយគេយកទៅ គេថានៅខុសទៀត។ សូមអស់ប៉ុណ្ណឹងបង។

[១៥:៤១:៣៣]

**សៈ** តើពេលដែលលោកជួបអ្នកស៊ើបអង្កេតនៃសហចៅក្រមស៊ើបអង្កេតនោះ តើគេមានបានអានឯកសារមួយ ដែលជាជីវប្រវត្តិរបស់លោក កាលពីសម័យនោះដែរឬទេ?

**ឆៈ** អត់ ពូ អត់សោះ។ ពីសម័យ អត់មានអ្នកណាអី-- ឯកសារអីឱ្យអាន អត់ គ្មាន។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯលៈ**

បាទ លោកប្រធាន ខ្ញុំដឹងថាសាក្សីមិនចេះអានអក្សរទេ ក៏ប៉ុន្តែខ្ញុំគ្រាន់តែចង់អានផ្នែកមួយចំនួននៃប្រវត្តិរូបរបស់គាត់ ដែលមានលេខឯកសារ IS19.72 មានតែមួយទំព័រទេ ដែលមានលេខ ERN ជាភាសាខ្មែរ 00019490, ជាភាសាអង់គ្លេស 007977 ហើយជាភាសាបារាំង មិនទាន់មានការបកប្រែនៅឡើយទេ។ សូមតុលាការអនុញ្ញាតឱ្យខ្ញុំអានសម្រង់មួយចំនួន ពីព្រោះថាខ្ញុំមិនអាចបង្ហាញគាត់ទេ ប៉ុន្តែយើងអាចបញ្ចាំងលើអេក្រង់ ដើម្បីឱ្យភាគី ហើយនិងសាធារណជនអាចឃើញបាន។

សូមអនុញ្ញាតពីលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ឯកសារហ្នឹង មានចំណងជើងថាម៉េចទៅ?

**លោក វ៉ាំងសង់ វ៉ាយដ៏ ដេស្មាឯល៖**

បាទ នេះគឺជាប្រវត្តិរូបរបស់លោក ខឹម ងន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត សូមអញ្ជើញ!

[១៥:៤៣:៤២]

**លោក វ៉ាំងសង់ វ៉ាយដ៏ ដេស្មាឯល៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមអានវគ្គមួយចំនួននៃជីវប្រវត្តិរបស់លោក ហើយលោកនឹង-- សូមនិយាយប្រាប់ខ្ញុំ បើថាជាប្រវត្តិរូបរបស់លោក ឬក៏មិនមែនទេនោះ។ គឺជាជីវប្រវត្តិផ្ទាល់ខ្លួនរបស់លោក ខ្ញុំសូមអានជាភាសាអង់គ្លេស ពីព្រោះថាមិនមានជាសំណៅជាភាសាបារាំងទេ។

(អានជាភាសាអង់គ្លេស៖) បាទ មានឈ្មោះ ខឹម ងន អាយុ១៩ឆ្នាំ ភូមិតាយឹង ឃុំអង្គខ្នុរ ស្រុកកោះអណ្តែត ខេត្តតាកែវ។ បាទបន្តទៅ-- បន្ទាប់ទៀត គឺវណ្ណៈភាព បាទ កសិករក្រ ចំណេះវិជ្ជា គឺថ្នាក់ទី១០។ ចូលធ្វើបដិវត្តន៍នៅពាក់កណ្តាលឆ្នាំ១៩៧៣។ ភារកិច្ចអង្គការប្រគល់ឲ្យ ទីមួយ ជាឈ្លបឃុំអង្គខ្នុរ។ (បញ្ចប់ការអានភាសាអង់គ្លេស)

បាទ លោកប្រធាន មានបញ្ហាបកប្រែ ដោយសារ-- ដូចជាប្រើមីក្រូខុសគ្នានៅក្នុងន៎ៃ បន្ទប់បកប្រែ។

**ប្រធានអង្គជំនុំ៖**

ឥឡូវមានបញ្ហាបកប្រែ មន្ត្រីរដ្ឋបាលតុលាការពិនិត្យ និងសម្របសម្រួលលើ-- ជាមួយអង្គភាពបកប្រែភាសា។

*(មានបញ្ហាបច្ចេកទេសបកប្រែ)*

[១៥:៤៥:៤១]

សូម១អញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ អាចបន្តបានហើយ!

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៏ ដេស្មាឯល៖**

**ស៖** បាទខ្ញុំមិនដឹងថា ចាប់ផ្តើមពីកន្លែងណាវិញទេ តែនិយាយដោយខ្លី១--

(និយាយភាសាអង់គ្លេស៖) ខ្ញុំអាយុ១៩ឆ្នាំ ភូមិតាយឹង ឃុំអង្គខ្នុរ ស្រុកកោះអណ្ដែត ខេត្តតាកែវ។ វណ្ណភាពកសិករក្រ ចំណេះវិជ្ជាថ្នាក់ទី១០។ ចូលធ្វើបដិវត្តន៍ពាក់កណ្ដាលឆ្នាំ១៩៧៣។ ភារកិច្ចអង្គការប្រគល់ឲ្យទីមួយ ជាឈ្លបឃុំអង្គខ្នុរ។ ទីពីរ ធ្វើការនៅមន្ទីរស្រុកកោះអណ្ដែត"។ បាទខ្ញុំនឹងសូមបញ្ជាក់ឡើងវិញ៖ "គឺថាជា ឈ្លបឃុំអង្គខ្នុរ។ ទីពីរ ធ្វើការនៅកោះ-- មន្ទីរស្រុកកោះអណ្ដែត។ ទីបីនៅមន្ទីរនគរបាលស្រុក។ សីលធម៌រស់នៅស្អាតស្អំ សកម្មភាពមធ្យមៗ។ ទិន្នាការនយោបាយមុនៗថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ គ្មានជំពាក់ជំពិនជាមួយខ្មាំងទេ"។ (បញ្ចប់និយាយភាសាអង់គ្លេស)

[១៥:៤៧:៣៤]

បាទ នេះជាផ្នែកទីមួយនៃប្រវត្តិរូបរបស់លោក តើលោកទទួលស្គាល់ថានេះពិតជាប្រវត្តិរូបរបស់លោកដែរឬទេ លោកសាក្សី?

**លោក ខឹម ងន៖**

**ឆ៖** ពិតហើយបង អង្កាល់គេសរសេរឲ្យ ខ្ញុំវាមិនដឹង គេអ្នកចេះគេអ្នករកគេសរសេរឲ្យណ៎ះ។ ប៉ុណ្ណឹង។

**ស៖** បាទ មានចំណុចផ្សេងៗទៀតដែលយើងចាប់អារម្មណ៍នៅក្នុងប្រវត្តិរូបរបស់គាត់នេះ គឺថាមានចំណុចបួនចំណុច គឺថាទាក់ទងទៅនឹងឋានៈសង្គមរបស់គាត់ គឺថាមានសរសេរថា គាត់ជាកសិករ-- លោកជាកសិករក្រ។ ហើយបើយើងយោងទៅលើអ្វីដែលសរសេរនោះ គឺថាមានសរសេរផងដែរ ថាឪពុក-- ជាកសិករក្រ ឪពុកម្ដាយក៏អ៊ីចឹងដែរ។ តើនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យនោះ ជាការសំខាន់ឬ ក្នុងការមានឋានៈជា ឋានៈកសិករក្រីក្រ ដើម្បីឲ្យគេទុកចិត្តយើងបាន? អ៊ីចឹងមែនទេ?

**ឆ៖** អ៊ីចឹងហើយពូ អ៊ីចឹងហើយរឿងហ្នឹង បើយើងមិនដាក់ក្រឲ្យគេ គេម៉េចនឹងជឿយើង យើងក្រមែនអង្កាល់ហ្នឹង។ គ្មានអីទេ ចប់ហើយ។

[១៥:៤៩:០៨]

**ស៖** ចំណុចមួយទៀត ទាក់ទងទៅនឹងសីលធម៌រស់នៅ គឺថាស្អាតស្អំ ហើយលោកនិយាយថាឪពុកម្ដាយរបស់លោកក៏ដូចគ្នាដែរ។ តើសីលធម៌រស់នៅស្អាតស្អំនោះមានន័យយ៉ាងម៉េចដែរ នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង?

**ឆ៖** អ្អែ អង្កាល់ហ្នឹងគេថា ខ្ញុំក៏មិនសូវយល់ មិនចេះ អាហ្នឹងគេដាក់ៗអ៊ីចឹងតាមគេទៅលោកពូ។ ប្រជាធិបតេយ្យថាម៉េច រកគេសរសេរឲ្យ ដាក់ៗតាមគេទៅ ធ្វើម៉េចបើខ្ញុំអត់ចេះ មិនយល់។

**ស៖** បន្ទាប់មកទៀតគឺថា លោកនិយាយអំពីសកម្មភាព ដែលមានសរសេរថា "មធ្យម"។ តើនៅពេលដែលយើងនិយាយអំពីសកម្មភាពរបស់ខ្លួននោះ យើងត្រូវនិយាយអ្វីខ្លះ? ហេតុអ្វីបានជាលោកប្រាប់ សរសេរនៅក្នុងប្រវត្តិរូបរបស់លោកថា សកម្មភាពរបស់លោក "មធ្យម"?

**ឆ៖** អង្កាល់ហ្នឹងឲ្យ អាភឿង១ គេធ្វើឲ្យគេថា ផ្អែងដាក់ទី១០ ទៅ ប៉ុន្តែខ្ញុំវាអត់អក្សរ គេឲ្យដាក់ទៅក៏ដាក់តាមគេទៅ។ អង្កាល់ហ្នឹងប្រវត្តិហ្នឹង ចុះវាអាចថា គេឲ្យដាក់ៗតាមគេទៅ។ ហើយគេចង់ទាក់ធ្វើខ្ញុំវានៅក្មេង ឲ្យខ្ញុំធ្វើការជាមួយគេមួយ។ ហើយគេដាក់ខ្ញុំធ្វើប្រធានក្រុមកាលហ្នឹង។ ប៉ុណ្ណឹងហើយខ្ញុំមិនចេះអក្សរ ដាក់ឲ្យធ្វើខ្ញុំមិនចេះ សួរមេក្រុមទៀតហ្នឹង កាលហ្នឹងពេលធ្វើប្រវត្តិរូបមាននរណានៅជិត មេភូមិនៅជិតគ្មានទេ មានអ្នកធ្វើឲ្យតាមកាលហ្នឹង។

[១៥:៥១:១២]

**ស៖** សូមអរគុណ។ ហើយនៅចំណុចក្រោយមួយទៀត គឺនិន្នាននយោបាយ។ លោកបានសរសេរថា លោកពុំមានជាប់ពាក់ព័ន្ធជាមួយខ្មាំងទេ ហើយលោកចំពោះឪពុកម្តាយរបស់លោកនោះក៏លោកនិយាយដូចគ្នាអ៊ីចឹងដែរ ថាមិនមានជាប់ពាក់ព័ន្ធនឹងខ្មាំងទេ។ តើហេតុអីក៏ថា ជាការសំខាន់ក្នុងការនិយាយប្រាប់ថា យើងពុំមានការជាប់ពាក់ព័ន្ធ ជាមួយខ្មាំងនោះ?

**ឆ៖** អង្កាល់ហ្នឹងខ្ញុំដាក់ឲ្យរួម អង្កាល់ហ្នឹងអត់ទាន់មានទេពូ ដល់តែពេលដែលខ្ញុំចេញទៅធ្វើការមកនៅភ្នំពេញនេះ អង្កាល់នៅហ្នឹង ខ្ញុំដាក់អត់មានពូអ៊្ហា ដល់ពេលខ្ញុំមកធ្វើមកនៅជាមួយភៀវបរទេសនៅទីក្រុងភ្នំពេញគេឲ្យធ្វើប្រវត្តិរូប ក៏ខ្ញុំសង្ស័យ អាហ្នឹងបានគេចាត់ទុកខ្ញុំ អ៊ីចឹងបានខ្ញុំធ្វើប្រវត្តិរូប ភ័យហ្នឹងណា។ កាលធ្វើប្រវត្តិរូបគេធ្វើល្អហើយ ចង់ថាឲ្យបានទៅនៅហ្នឹងគេ បានគេដកប្រវត្តិរូបល្អទៅហ្នឹង។ គេដកទាំងប្រាំមួយនាក់ហ្នឹង ទៅនៅក្រសួងការបរទេសហ្នឹង។ ដល់ពេលទៅវាដល់ពេល៧៦, ៧៥ អ៊ីចឹងអ្ហា ក្នុងរង្វង់ហ្នឹងហើយ ដែលគេពិនិត្យខ្លាំង។ គេធ្វើល្អៗតាំងពីមុន ដល់ពេលគេធ្វើចុងក្រោយ គេចាត់ទុកយើងថាខុសនោះឃើញទេនែ៎។ ទាល់តែតាមដានទៀតលោកពូ កន្លែងហ្នឹង។ ចប់ហើយ។

[១៥:៥២:៥១]

**ស៖** ក៏ប៉ុន្តែប្រវត្តិរូប ដែលខ្ញុំអានជូនលោកអម្បាញ់មិញនេះ មានសរសេរម៉្យាងគឺថា លោកគឺជាកសិករក្រីក្រ មានសីលធម៌ រស់នៅល្អ ហើយពុំមានជាប់ជំពាក់ជំពិនជាមួយសត្រូវ ហើយលោកមានកម្រិតសកម្មភាពមធ្យម។ តើពាក្យថា "ប្រវត្តិរូបល្អ"នោះគឺថា អ៊ីចឹង ឬក៏យ៉ាងម៉េច? ឬក៏ថា-- តើ--

ហើយម្យ៉ាងទៀត តើមានគេធ្លាប់និយាយប្រាប់លោក អំពីៗខ្លឹមសារនៃពាក្យដែលហៅថា "ប្រវត្តិរូបបរិសុទ្ធ ស្អាតស្អំ" បាទ។ តើមានគេនិយាយអ៊ីចឹងប្រាប់លោកដែរឬទេ?

**ឆ៖** គេមាននិយាយដែរ គេប្រាប់ សរសេរប្រវត្តិរូបគេថា ដាក់ប្រវត្តិរូបដែលល្អទៅលោកពូអាហ្នឹង។ ថាយើងដាក់ទៅ អត់មានទាក់ទាមអីទេ ចេះតែដាក់ទៅ។ តែខ្ញុំវាមិនចេះ ដាក់ម៉េចក៏ដាក់ទៅគឺអ្ហី ហ្នឹងគេទៅ បានធ្វើការជាមួយគេហ្នឹង ព្រោះខ្ញុំវាមិនសូវនឹងគេវាមិនចេះ។ អស់ហើយលោកពូ។

**សៈ** បាទ ខ្ញុំសូមបំភ្លឺចំណុចមួយ។ រយៈពេលដែលប្រវត្តិរូបនេះបានធ្វើឡើងនោះ ហើយមានសរសេរ តាមការពិតទៅគឺថា មានការងារផ្សេងៗនៅតាកែវ នៅស្រុកកោះអណ្ដែត ក៏ប៉ុន្តែនៅក្នុងប្រវត្តិរូបហ្នឹង មិនបាននិយាយអំពីការងាររបស់លោកនៅក្រសួងការបរទេសទេ។ តើគឺជាប្រវត្តិរូបដែលលោកបានសរសេរមុននឹងពេលចេញទៅភ្នំពេញ ឬក៏ពេលទៅដល់ភ្នំពេញ ឬក៏ក្រោយពេលដែលលោកធ្វើការនៅក្រសួងការបរទេសហើយ?

[១៥:៥៤:៤៩]

**ឆ៖** ប្រវត្តិរូបធ្វើលើកទីមួយ ធ្វើតាំងពីនៅតំបន់ៗនៅស្រុកនោះ លើកទីមួយលោកពូណ៎ះ។ ដល់ពេលលើកទីពីរ ធ្វើនៅក្រសួងការបរទេសនេះ។ ក្នុងប្រវត្តិរូប លើកទីមួយគេដាក់ខ្ញុំ គេដាក់យកល្អដាក់កសិករ រួចខ្ញុំ គេដាក់ម៉េចគេដាក់ទៅខ្ញុំអត់ចេះ ខ្ញុំអត់ដឹង នឹកឃើញអ៊ីចឹង។ ដល់ពេលខ្ញុំឡើងមកភ្នំពេញធ្វើប្រវត្តិរូបមួយសាទៀត ដល់ពេលឆ្នាំ៧៦ហ្នឹង វា-- អើ វារស់នៅតាម-- ដាំបាយតាមសហករណ៍ សហអីហ្នឹង វាធម្មតា ក្រែងលោវាមានបងប្អូនខ្ញុំយកវ៉ៃចោលអ៊ីចឹង វាឃើញធ្វើប្រវត្តិរូបមួយសាទៀត។ អង្កាល់លើកដំបូង លើកនៅតំបន់វាធ្វើប្រវត្តិរូបមួយខ្ញុំហ្នឹង ដល់ពេលទៅដល់ក្រសួងការបទេសខ្ញុំធ្វើមួយទៀត។ អាហ្នឹងគេ-- អាហ្នឹងគេកំណត់ធ្វើតែម្ដង បើខ្ញុំធ្វើនៅភ្នំពេញ ធ្វើពីរបីដងណោះ។ អាហ្នឹងខ្ញុំដែលខ្ញុំធ្វើមុនលើកទីពីរលើកទីបីប្រវត្តិរូប ប៉ុន្តែធ្វើអាលើកនេះ តាមមើលខ្ញុំវាយការណ៍ហ្នឹងវា-- អើ បែបធ្វើតាំងពីលើកទីមួយអាហ្នឹង អង្កាល់ពីមុនដំបូងចូលអាហ្នឹង ចូលមកឃុំ មកភូមិ ហើយឡើងមកស្រុកហ្នឹងណ៎ា។ ចប់ហើយពូ។

**សៈ** បាទ សូមអរគុណ។ ទាក់ទងទៅនឹងប្រវត្តិរូបទីពីរ ដែលមិនមែនជាប្រវត្តិរូបនេះទេ ប៉ុន្តែប្រវត្តិរូបនេះបានសរសេរនៅក្រសួងការបរទេស លោកបាននិយាយថា "ប្រាកដជាពេលដែល-- ក្រោយពេលដែលបងប្អូនរបស់លោកហ្នឹងជួបការលំបាក" តើលោកអាចពន្យល់បានទេថាពាក្យថា "មានការលំបាក" របស់ក្រុមគ្រួសាររបស់លោកនៅសហករណ៍នោះ មានន័យថាយ៉ាងម៉េច "ការលំបាក" នុ៎ង?

[១៥:៥៦:៣៧]

**ឆ៖** លំបាកហ្នឹង នឹកឃើញថាម៉ែ ក៏គេមិនដែលមកលេង ហើយចំពោះខ្លួនខ្ញុំដែលនៅធ្វើការនោះ គេមិនឲ្យទៅលេងផ្ទះ។ តែប៉ុណ្ណឹងពូ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវី!

**លោក ម៉ៃខល កាណាវាស៖**

អរគុណលោកប្រធាន។ សូមទោសដែលខ្ញុំធ្វើការរំខាន។ សាក្សីរូបនេះគាត់សង្ស័យថា ប្រហែលជាមានបញ្ហាជាមួយក្រុមគ្រួសាររបស់គាត់។ ហើយខ្ញុំគិតថាសំណួរដែលសួរនេះ គឺកំណត់អំពីចរិតលក្ខណៈនៃសក្ខីកម្មរបស់សាក្សី។ សាក្សីមិនបាននិយាយថា គាត់មានបញ្ហានោះទេ។ ហើយគាត់-- ដោយសារហេតុដូច្នេះឯងទើបបាន-- គាត់សង្ស័យថាបញ្ហាគ្រួសាររបស់គាត់នឹងមានបញ្ហា ទើបគេស្នើសុំឲ្យគាត់សរសេរប្រវត្តិរូប។ ហើយការសួរសំណួរបែបនេះ គឺដោយសហព្រះរាជអាជ្ញា គឺខ្ញុំយល់ឃើញថា គឺជាសំណួរនាំមុខហើយលោកប្រធាន។ សូមអរគុណ។

[១៥:៥៧:១៦]

**លោក វាំងសង់ វ៉ាយឌ៍ ដេស្មាឯល៖**

បាទ ខ្ញុំសូមចូលទៅសំណួរថ្មីមួយទៀតលោកប្រធាន។

**សួរដោយលោក វាំងសង់ វ៉ាយឌ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សី លោកនិយាយថាគឺ ហុង ដែលសុំឲ្យលោកសរសេរប្រវត្តិរូបនេះ ហើយតើគាត់មានបានប្រាប់លោកពីមូលហេតុនៃការដែលគាត់ឲ្យលោកសរសេរប្រវត្តិរូបនេះដែរឬទេ?

**លោក ខឹម ងន៖**

**ឆ៖** អាហ្នឹងគាត់ប្រាប់ដែរ ប្រាប់ថា ម៉ោងប្រាំពីរពេលព្រឹកគាត់ប្រាប់ថា មើល៍ អ្អែង! សរសេរប្រវត្តិរូបមួយទៅ សរសេរប្រវត្តិរូបឲ្យអញ។ អាហ្នឹងគាត់បាននិយាយអ៊ីចឹង។ ចប់ហើយពូ។

**ស៖** លោកសាក្សី តើលោកដឹងថា អ្នកណាជាមេ ឬក៏មេផ្ទាល់របស់ ហុង ដែរឬទេ?

**ឆ៖** អាមេថ្នាក់លើ ខ្ញុំអត់ដឹងទេ តែបើខ្ញុំនៅក្រសួងការបរទេសដឹងតែ បងហុង បញ្ជាឲ្យខ្ញុំធ្វើប្រវត្តិរូប។ មានតែ បងហុង ហ្នឹងបញ្ជាឲ្យធ្វើប្រវត្តិរូប។ ចប់ហើយ។

[១៥:៥៨:៣១]

**ស៖** តើនៅពេលដែលលោកធ្វើការនៅក្រសួងការបរទេស តើលោកដឹងថា អ្នកណាជារដ្ឋមន្ត្រីក្រសួងការបរទេសដែរឬទេ? ហើយលោកស្គាល់ឈ្មោះគាត់ដែរឬទេ?

**ឆ៖** អ្ហ៎ អង្កាល់ហ្នឹង ខ្ញុំដូចមិនដឹងទេលោក ឮ ខ្ញុំដឹងតែ បងហុង តែហ្នុង ដែល(ឮមិនច្បាស់) គេទៅប្រជុំ ខ្ញុំអត់ដឹងទេ អាហ្នឹងអត់ដឹង។ មានតែ បងហុង បញ្ជាឲ្យខ្ញុំដើរទៅណាប្រជុំជាមួយភ្ញៀវ មានតែ បងហុង ហ្នឹង។ បងហុង ទៅប្រជុំអីចឹងមិនដឹងទៅណាគេអត់ប្រាប់ខ្ញុំទេហ្នឹង។

**ស៖** តើលោកដឹងថានៅក្រសួងការបរទេស ដឹងអំពីផ្នែកមួយចំនួនដែលជាមន្ទីរនៃក្រសួងនេះដែរទេ? ហើយក្រៅពីផ្នែកទទួលភ្ញៀវនោះ តើមានផ្នែកអ្វីផ្សេងទៀតដែរឬទេ ដែលលោកប្រហែលជាលោកអាចធ្លាប់ស្តាប់គេនិយាយកាលនៅសម័យនោះ។

**ឆ៖** អ្ហ៎ វាមានច្រើនផ្នែក តែថ្នាក់លើគេថា-- អ្ហេ ដូច អឿង គេតែងនិយាយ ប៉ុន្តែបង ខ្ញុំភ្លេចអស់ហើយ មិនដឹងពីណាពីណីទេ ធ្វើម៉េចវាភ្លេចអាហ្នឹង មិនបានចាំអស់ ប៉ុន្តែខ្ញុំដូចនឹកឃើញចាំ មិត្តរឿង ហើយនិង ហុង តែម្តង តែថ្នាក់លើវាមានដែរ ប៉ុនមិនដឹងអ្នកណាគេបញ្ជាមកទៀត ខ្ញុំមិនបានចាប់អារម្មណ៍ថាចាំហ្នឹងណា។ ព្រោះខ្ញុំវាមិនបានទៅផ្ទះទៅ វាភ្លេចនឹកឃើញកាលហ្នឹង ខ្ញុំមិនបាននឹកឃើញអីទេ។ នៅក្មេង គេហៅមក មិនហ៊ាននិយាយ គេនិយាយក៏មិនសួរយកត្រចៀកឮទៀត។ ចប់ហើយបង។

[១៦:០១:០៣]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ តំណាងសហព្រះរាជអាជ្ញា អរគុណសាក្សី។

កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះដល់ពេលសមល្មមត្រូវសម្រាកហើយ អង្គជំនុំជម្រះសាលាដំបូងប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ទី១១ ខែមិថុនា ឆ្នាំ២០១២ ដោយចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ការធ្វើសវនាការនៅថ្ងៃចន្ទដើមសប្តាហ៍ក្រោយនេះនឹងបន្តស្តាប់សក្ខីកម្មសាក្សីឈ្មោះ សៅ សារុន ដែលនឹងតាំងសំណួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញា។

លោក ខឹម ងន ដំណើរការសវនាការពិភាក្សាដេញដោលស្តាប់សក្ខីកម្មរបស់លោកនៅមិនទាន់ចប់នៅឡើយទេ ដែលអង្គជំនុំជម្រះត្រូវតែបន្តធ្វើនៅថ្ងៃចន្ទ ទី១១ ខែមិថុនា ឆ្នាំ២០១២ គឺថ្ងៃចន្ទដើមសប្តាហ៍ក្រោយនេះ។ ដូច្នេះ អង្គជំនុំជម្រះកោះអញ្ជើញលោកមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃចន្ទ ទី១១

ខែមិថុនា ឆ្នាំ២០១២ ទៀត ដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ ហើយដូចគ្នានេះដែរអង្គជំនុំជម្រះ ក៏សូមអញ្ជើញមេធាវីប្រឹក្សាសាក្សីចូលរួមប្រឹក្សាសាក្សីនៅក្នុងកិច្ចដំណើរការសវនាការស្ដាប់សក្ខីកម្មសាក្សីរូបនេះ។

ហើយទន្ទឹមនឹងនេះអង្គជំនុំជម្រះក៏សូមជម្រាបផងដែរថា ចំពោះសាក្សីឈ្មោះ ខឹម ងន នេះគឺជាសាក្សីបម្រុង ដោយសារថ្ងៃចន្ទនេះ យើងនឹងបន្តស្ដាប់សាក្ខីកម្មសាក្សីឈ្មោះ សៅ សារុន ប៉ុន្តែដោយសារអង្គជំនុំជម្រះបានជម្រាបជូនភាគី និងសាធារណជនរួចហើយថា ដោយស្ថានភាពសុខភាពរបស់សាក្សី សៅ សារុន មានបញ្ហា ដោយគាត់ចាស់ ហើយមានជំងឺជាប់ខ្លួន។ អ៊ីចឹងគឺមានសាក្សីបម្រុងក្នុងករណីជាយថាហេតុដែលមិនអាចដំណើរការបានស្ដាប់សក្ខីកម្មសាក្សី សៅ សារុន នោះ យើងនឹងបន្តស្ដាប់សក្ខីកម្មសាក្សី ខឹម ងន ផ្លាស់គ្នា។

[១៦:០២:៥៩]

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងអង្គភាពគាំពារសាក្សីនិងអ្នកជំនាញក្នុងការបញ្ជូនលោក ខឹម ងន ត្រឡប់ទៅកន្លែងដែលគាត់ស្នាក់នៅវិញ ហើយនិងឲ្យនាំគាត់មកកាន់បរិវេណនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺនៅបន្ទប់រង់ចាំសម្រាប់សាក្សី នៅថ្ងៃចន្ទ ទី១១ ខែមិថុនា ឆ្នាំ២០១២ ដើម្បីត្រៀមលក្ខណៈជាសាក្សីបម្រុង។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងបីរូបទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ ហើយនិងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកកាន់បន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃចន្ទ ទី១១ ខែមិថុនា ឆ្នាំ២០១២ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០៤ នាទី)*